# ការលើកកម្ពស់ការចូលរួមក្នុងការងារនយោបាយ
# របស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា

ម៉ាហ្គារីតា ម៉ាហ្វី និង ហុង ស៊ីនាត

ការលើកកំពស់ការចូលរួមក្នុងការងារនយោបាយរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា

និពន្ធដោយៈ
ម៉ាហ្គារីតា ម៉ាហ្វី
ហុង ស៊ីនាត

រូបភាពដោយៈ
ម៉ាហ្គារីតា ម៉ាហ្វី

ពិនិត្យផ្ទៀងផ្ទាត់ដោយៈ
អាំង សុខរីន

បោះពុម្ពដោយៈ
រោងពុម្ព (JSRC) STC
ភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទៈ (៨៥៥) ០១២ ៩៧៤ ៥៦៧
អ៊ីម៉ែលៈ stc_jsrc@yahoo.com

ចងក្រងក្នុងឆ្នាំ ២០០៩ ក្រោមការគាំទ្រពី

**មូលនិធិ ហេនរេចបូល ប្រទេសកម្ពុជា (HBF)**
ផ្ទះលេខ ៣៤ ផ្លូវ ២២២ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ប្រអប់សំបុត្រលេខ ១៤៣៦ ភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទៈ (០២៣) ២១០ ៩៣៥
អ៊ីម៉ែលៈ phnompenh@hbfasia.org/www.boell-southeastasia.org

**កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ**
**ក្រសួងមហាផ្ទៃ** (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)
មហាវិថីព្រះនរោត្តម ភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទៈ (៨៥៥) ០២៣ ៧២៦ ០៣៦
ទូរសារៈ (៨៥៥) ០២៣ ២១២ ៧៨៣

**គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ**
ផ្ទះលេខ ៦ ផ្លូវ ២១ សង្កាត់ ទន្លេបាសាក់ ១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទៈ (៨៥៥) ១២ ៨៣៨ ៤៦៤
ទូរសារៈ (៨៥៥) ២៣ ២១៣ ១០៨

ទស្សនៈនៅក្នុងការសិក្សានេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយទោះជាក្នុងកាលៈទេសៈណាក៏ដោយឯកសារនេះមិនមែនជាការឆ្លុះបញ្ចាំងអំពីតួនាទីរបស់អង្គការទាំងឡាយដែលគាំទ្រឡើយ ។

© Heinrich Böll Stiftung 2009

# មាតិកា


**សេចក្តីថ្លៃអំណរគុណ** ........ ii
**សេចក្តីសង្ខេប** ........ iii
**សេចក្តីផ្តើម** ........ **១**
　　គោលដៅ និងវិសាលភាពនៃការសិក្សា ........ ១
**វិធីសាស្រ្ត** ........ ២
**ការចូលរួមរបស់ស្រ្តីជនជាតិដើមភាគតិច នៅក្នុងជួរអាជ្ញាធរប្រពៃណី និង អាជ្ញាធរមូលដ្ឋានជាផ្លូវការ** ........ **៣**
　　ស្រ្តីជនជាតិដើមភាគតិច និង អាជ្ញាធរប្រពៃណី ........ ៣
　　ក្រុមប្រឹក្សាឃុំនៅក្នុងបរិបទជនជាតិដើមភាគតិច ........ ៦
　　តួនាទីរបស់ក្រុមប្រឹក្សាឃុំ ........ ៦
　　ស្រ្តីនៅក្នុងក្រុមប្រឹក្សាឃុំ តាមតំបន់ជនជាតិដើមភាគតិច ........ ៩
　　តើស្រ្តីនៅក្នុងសហគមន៍ យល់ឃើញយ៉ាងណាចំពោះក្រុមប្រឹក្សាឃុំជាស្រ្តី? ........ ៩
　　ឆន្ទៈរបស់ស្រ្តីក្នុងសហគមន៍ នៅក្នុងការចូលរួមជាមួយនឹងក្រុមប្រឹក្សាឃុំ ........ ១០
　　បទពិសោធន៍របស់ស្រ្តីជនជាតិដើមភាគតិច ដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ ........ ១១
　　សមាជិកក្រុមប្រឹក្សាឃុំជាស្រ្តី មានតួនាទីជា "អ្នកទទួលបន្ទុកផ្នែកយេនឌ័រ" ........ ១៣
　　ការអោយតម្លៃស្រ្តីទាបនៅក្នុងក្រុមប្រឹក្សាឃុំ ........ ១៥
**ឧបសគ្គដែលរារាំងស្រ្តីជនជាតិដើមភាគតិចមិនអោយចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំ** ........ **១៦**
　　ឧបសគ្គ ដែលមើលឃើញដោយអ្នកដែលមានការពាក់ព័ន្ធ ........ ១៦
　　ឧបសគ្គ ដែលមើលឃើញដោយស្រ្តីក្នុងសហគមន៍ ........ ១៨
　　ឧបសគ្គ ដែលមើលឃើញដោយក្រុមប្រឹក្សាឃុំជាស្រ្តី ........ ២០
**ឧបសគ្គដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គម និងការផ្លាស់ប្តូរវប្បធម៌** ........ **២២**
　　ការងាររបស់ស្រ្តី ........ ២២
　　ជីវិតគ្រួសារ ........ ២៣
　　ជីវិតសង្គម ........ ២៤
　　អំពើហិង្សាលើស្រ្តី ........ ២៤
　　កង្វះខាតសេវាកម្ម ........ ២៦
**ស្រ្តីនៅក្នុងនយោបាយៈ កម្លាំងចលករដែលធ្វើឱ្យមានការផ្លាស់ប្តូរ** ........ **២៨**
　　សមាជិកក្រុមប្រឹក្សាឃុំជាស្រ្តីៈ ជាការធានាអោយមានអភិបាលកិច្ចល្អមែនទេ? ........ ២៨
　　ការផ្លាស់ប្តូរនយោបាយ ........ ២៩
　　ការធ្វើឱ្យកាន់តែប្រសើរនូវស្ថានភាពរបស់ស្រ្តីៈ ឧទាហរណ៍ ពីការប្រឆាំងអំពើហិង្សាលើស្រ្តី ........ ៣៣
**សេចក្តីសន្និដ្ឋាន** ........ ៣៥
**អនុសាសន៍** ........ ៣៨
**ឯកសារយោង** ........ ៤៤
**ឧបសម្ព័ន្ធ** ........ ៤៦

# សេចក្តីថ្លែងអំណរគុណ

យើងសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះស្ត្រីទាំងអស់មកពីខេត្តរតនៈគីរី មណ្ឌលគីរី ក្រចេះ និងស្ទឹងត្រែង ដែលបានលះបង់ពេលវេលាចូលរួមពិភាក្សាជាមួយក្រុមស្រាវជ្រាវយើង។ យើងក៏សូមសំដែងការដឹងគុណជាអនេកចំពោះអ្នកផ្តល់ព័ត៌មានទាំងអស់ រួមមាន ក្រុមប្រឹក្សាឃុំ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរាជការ។ យើងអរគុណចំពោះ អ្នកបកប្រែ និងមគ្គុទេសក៍ ទាំងអស់ លើការងារដ៏មានតម្លៃរបស់ពួកគេ។ យើងខ្ញុំក៏សូមអរគុណជាពិសេសចំពោះសមាគមខ្មែរលើ (Highlanders Association) ដែលបានអញ្ជើញក្រុមការងារយើងខ្ញុំ អោយចូលរួមក្នុងសិក្ខាសាលានៅខេត្តរតនគីរី និងសូមថ្លែងអំណរគុណដល់បុគ្គលិក NTFP នៅខេត្តរតនគីរី ក្រុមឃ្លាំមើលសិទ្ធិមនុស្សនៅខេត្តមណ្ឌលគីរី និង សមាគមខ្មែរដើម្បីអភិវឌ្ឍន៍ជនបទកម្ពុជា (KAFDOC) នៅខេត្តក្រចេះ ដែលបានជួយជ្រោមជ្រែងពួកយើងក្នុងការស្វែងរកអ្នកបកប្រែភាសា និងជួយសម្រួល ដល់ដំណើរទស្សនកិច្ចរបស់ក្រុមការងារយើងខ្ញុំទៅកាន់សហគមន៏ផងដែរ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់មន្ទីរកិច្ចការនារីខេត្តមណ្ឌលគីរី ខេត្តរតនគីរី និង ខេត្តស្ទឹងត្រែងចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្រដ៏សកម្មនៅក្នុងការរៀបចំកិច្ចប្រជុំជាមួយសមាជិកក្រុមប្រឹក្សា ឃុំ ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកទាំងអស់គ្នា ដែលបានចូលរួមក្នុងការផ្តល់ជាមតិយោបល់ និងសំណូមពរដ៏មានតម្លៃចំពោះការកែសម្រួលអត្ថបទចុងក្រោយនេះ ។



ស្ត្រីជនជាតិដើមភាគតិចចូលរួមសិក្ខាសាលាក្នុងខេត្តក្រចេះ

# សេចក្តីសង្ខេប

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានផ្តួចផ្តើមឡើងដោយ មូលនិធិ ហែនរេចបូល (HBF) កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (ARDP) នៃទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស អាល្លឺម៉ង់ និងគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) ដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរឡើងនូវឧបសគ្គ បញ្ហាប្រឈម និងកាលានុវត្តភាព ដើម្បីឱ្យស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា បានចូលរួមនៅក្នុងបរិយាកាសសង្គមកាន់តែមានប្រសិទ្ធភាព និងស្មើភាពគ្នា ។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមបណ្តាខេត្តភាគឦសានមួយចំនួន ដូចជាខេត្តមណ្ឌលគីរី រតនៈគីរី ស្ទឹងត្រែង និងក្រចេះ ហើយមានការចូលរួមពីក្រុមស្ត្រីជនជាតិដើមភាគតិចផ្សេងៗគ្នា ព្រមទាំងស្ត្រីជនជាតិខ្មែរ និងឡាវផងដែរ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្ត្រ ដែលទទួលបានមកពីការសិក្សាអំពីស្ត្រី ការស្រាវជ្រាវបែបសកម្មភាពនិងការសិក្សាអំពីជនជាតិដើមភាគតិច ហើយរួមបញ្ចូលនូវកិច្ចពិភាក្សាមួយចំនួនដែល ទាក់ទងទៅនឹងបទពិសោធន៍ ចំណេះដឹង និងចក្ខុវិស័យរបស់ស្ត្រី ព្រមទាំងកិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍ ផ្សេងទៀតផងដែរ ។

កិច្ចពិភាក្សាជាមួយស្ត្រីផ្តោតសំខាន់លើរបៀបថាតើការផ្លាស់ប្តូរសង្គម-សេដ្ឋកិច្ច ដែលបច្ចុប្បន្នសហគមន៍តាមមូលដ្ឋានកំពុងប្រឈមមុខមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើជីវិតរបស់ស្ត្រីទាំងនោះដោយរបៀបណា។ សម្រាប់ស្ត្រី ភាគច្រើន ការបែងចែកនូវទំនួលខុសត្រូវរវាងស្ត្រី និងបុរស គឺពុំសូវមានតុល្យភាពឡើយ ដែលជាកត្តាបណ្តាល ឱ្យស្ត្រីត្រូវទទួលរ៉ាប់រងបន្ទុកការងារកាន់តែខ្លាំងឡើងដើម្បីធានាដល់ជីវភាពរស់នៅរបស់គ្រួសារ។ សាមគ្គីភាពនៅក្នុងចំណោមអ្នកភូមិកាន់តែមានការថយចុះ ហើយការធ្វើចំណូលស្រុកទៅក្នុងសហគមន៍យ៉ាងសម្បើមនៃប្រជាជនមកពីតំបន់ខាងក្រៅ គឺកំពុងតែធ្វើឱ្យបាត់បង់នូវអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចផងដែរ។ យោងតាមទស្សនៈរបស់ស្ត្រី បុរសងាយទាក់ទាញដោយសម្ភារៈឬស្លុងអារម្មណ៍ទៅនឹងអាកប្បកិរិយាមិនល្អ ដូចជាការប្រើប្រាស់ជាតិស្រវឹងច្រើនជ្រុលជាដើម។ ឥទ្ធិពលដែលពិភពខាងក្រៅកំពុងមានចំពោះសហគមន៍ទាំងនេះមានការកើនឡើង ហើយបង្កើតឡើងនូវគុណតម្លៃដែលលំអៀងទៅខាងបុរស។

ស្ត្រីជនជាតិដើមភាគតិច ពឹងផ្អែកទៅលើអាជ្ញាធរប្រពៃណីរបស់ខ្លួន ហើយមើលឃើញអាជ្ញាធរប្រពៃណីទាំងនោះថា ជាសសរទ្រូងនៃសង្គមជាតិរបស់ខ្លួន។ ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់សង្គមជាតិ ពោលគឺដើរតួនាទីជាចាស់ព្រឹទ្ធាចារ្យ មេដឹកនាំសាសនាគ្រូព្យាបាលជំងឺ អ្នកមើលជំងឺ ឆ្មប ឬជាអ្នកថែរក្សាកេរតំណែលបុព្វបុរស។ តួនាទីទាំងនេះ កំពុងតែមានការធ្លាក់ចុះកាន់តែខ្លាំងឡើងៗ ហើយមិនអាចជំនួសមកវិញតាមរយៈការចូលរួមរបស់ស្ត្រីនៅក្នុងអាជ្ញាធរផ្លូវការ ដូចជាក្រុមប្រឹក្សាឃុំបានឡើយ បើទោះបីជាការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ ត្រូវបានស្ត្រីជនជាតិដើម ភាគតិចមើលឃើញថាជាប្រការមួយដ៏សំខាន់យ៉ាងណាក៏ដោយ។ ស្ត្រីមើលឃើញសមាជិកក្រុមប្រឹក្សាដែលជាស្ត្រីថាជាកត្តាជួយសម្របសម្រួលមួយសំរាប់ពួកគេ នៅពេលដែលពួកគេត្រូវដោះស្រាយជាមួយអាជ្ញាធរ និងចាត់ទុកសមាជិកក្រុមប្រឹក្សា ដែលជាស្ត្រីថាជាសមាជិកដែលមានប្រសិទ្ធភាព និងមានភាពស្មោះត្រង់។ មានស្ត្រីជាច្រើន

ដែលមានបំណងចង់ឈរឈ្មោះ ធ្វើជាបេក្ខនារី ហើយគិតថាការចូលរួមរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាឃុំ នឹងអាចជួយកែលម្អស្ថានភាពទូទៅរបស់ស្ត្រីបាន ។

ស្ត្រីជនជាតិដើមភាគតិចដែលជាប់ឆ្នោតនៅក្នុងក្រុមប្រឹក្សាឃុំ បានបញ្ចេញនូវទស្សនៈ ផ្សេងៗគ្នា។ ក្នុងចំណោមស្ត្រីដែលជាប់ឆ្នោតទាំងនេះស្ត្រីមួយចំនួនបានជួបប្រទះនូវបញ្ហាខ្វះសិទ្ធិអំណាច និងការអោយតម្លៃទាបទៅលើពួកគេ។ នៅក្នុងករណីខ្លះទៀតសមាជិកក្រុមប្រឹក្សាដែលជាស្ត្រីមានមុខងារកម្រិតត្រឹមតែមើលលើ "បញ្ហាយេនឌ័រ" ប៉ុណ្ណោះ ហើយមិនដែលទទួលបានការអញ្ជើញឱ្យទៅដោះស្រាយបញ្ហាអភិបាលកិច្ចដទៃទៀតឡើយ។ ជាញឹកញាប់ ពាក្យ "យេនឌ័រ" គឺរៀបរាប់អំពីសេវាកម្មទូទៅ ដូចជាការថែទាំសុខភាព ឬការគាំពារកុមារជាដើម ប៉ុន្តែមិនបានផ្តោតលើការរើសអើងពាក់ព័ន្ធនឹងយេនឌ័រ និងភាពចាំបាច់ក្នុងការដោះស្រាយបញ្ហានេះឡើយ។ សមាជិកក្រុមប្រឹក្សាឃុំដែលជាស្ត្រី ត្រូវតែតស៊ូពុះពារនៅគ្រប់ជំហានទាំងអស់ក្នុងដំណើរការនេះ ដើម្បីទទួលបានមុខតំណែងមួយនៅក្នុងបញ្ជីដែលអាចឱ្យខ្លួនជាប់ឆ្នោតដើម្បីមានតួនាទីមួយនៅក្នុងក្រុមប្រឹក្សាឃុំ និងទទួលបានការគាំទ្រពីសំណាក់ស្វាមីនៅក្នុងអាណត្តិរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាឃុំ ដែលជាស្ត្រីភាគច្រើន អះអាងថាបានប្រើប្រាស់នូវរបៀបនៃភាពជាអ្នកដឹកនាំរបស់ខ្លួនប្រកបដោយគុណភាពខុសគ្នាពីរបៀបដឹកនាំរបស់សហសេវិកជាបុរស និងឆ្លុះឱ្យឃើញនូវទស្សនៈ ដែលស្ត្រីនៅក្នុងសហគមន៍យល់ឃើញពីស្ត្រីក្រុមប្រឹក្សាឃុំទាំងនោះថា: ពួកគេមានតម្លាភាពជាងក្រុមប្រឹក្សាឃុំជាបុរស និងផ្តោតខ្លាំងទៅលើប្រជាជន មានការអត់អោន និងមានការប្រឆាំងអំពើពុករលួយ។

សម្រាប់ស្ត្រីនៅក្នុងសហគមន៍ជនជាតិដើម ឧបសគ្គដ៏ចម្បងដែលរារាំងដល់ការជាប់ឆ្នោតរបស់ពួកគេនៅក្នុងក្រុមប្រឹក្សាឃុំ គឺអតុល្យភាពនៃអំណាច ដែលធ្វើឱ្យពួកគេស្ថិតក្នុងស្ថានភាពទន់ខ្សោយមួយ បើប្រៀបធៀបទៅនឹងបុរស។ គេមើលការខ្វះសមត្ថភាពរបស់ស្ត្រីទាំងនោះ ដូចជាការខ្វះជំនាញក្នុងការសរសេរភាសាខ្មែរជាជាងរកពីមូលហេតុនៃអតុល្យភាពនេះ។ ភាគីពាក់ព័ន្ធភាគច្រើនដែលបានផ្តល់សម្ភាសន៍សម្រាប់ការសិក្សាស្រាវជ្រាវនេះ បានយល់ឃើញថាបញ្ហាកង្វះសមត្ថភាពនេះ គឺជាមូលហេតុចម្បងដែលបណ្តាលឱ្យមានការផាត់ចោលស្ត្រីជនជាតិដើមភាគតិច ហើយពួកគាត់មានការទោរទន់ទៅរកការយល់ដឹងអំពីបញ្ហានេះក្នុងការងាររបស់គាត់ ដោយមិនគិតអំពីបញ្ហានៃការរើសអើងយេនឌ័រឡើយ ។ ជាពិសេស នៅក្នុងករណីរបស់ស្ត្រីជនជាតិដើមភាគតិច កង្វះចំណេះដឹងក្នុងការប្រើប្រាស់ភាសាមួយដែលមិនមែនជាភាសាកំណើតរបស់ខ្លួនតែងតែធ្វើអោយមានការយល់ច្រឡំជាមួយនឹងកង្វះការអប់រំទូទៅ ដែលធ្វើអោយស្ត្រីទាំងនេះស្ថិតនៅក្នុងស្ថានភាពមួយ ដែលមិនគួរអោយចង់បាន ពោលគឺត្រូវបានចាត់ទុកថាជាមនុស្សអវិជ្ជា គ្មានជំនាញ ឬមានចំណេះដឹងតិចតួច ។

ក្នុងនាមជាស្ត្រីជនជាតិដើមជាសមាជិកក្រុមប្រឹក្សាឃុំ បានបញ្ចេញទស្សនៈអំពីបញ្ហាប្រឈម និងឧបសគ្គរបស់ពួកគេយ៉ាងច្រើនក្នុងការចូលរួមពេញលេញនៅក្នុងឆាកនយោបាយ។ ក្នុងចំណោមកត្តាដែលអាចជួយដល់ស្ត្រីក្នុងការទទួលបាននូវមុខតំណែងទាំងនេះ មានដូចជា ការជួយជ្រោមជ្រែងពីសំណាក់ក្រុមគ្រួសារ និងសហគមន៍ កម្រិតនៃប្រាក់ចំណូលមួយចំនួនដើម្បីអោយស្ត្រីមានពេលវេលាចូលរួមនៅក្នុងសកម្មភាពនយោបាយ ការគាំទ្រពីសំណាក់ បណ្តាគណបក្សនយោបាយផ្សេងៗ ឆន្ទៈក្នុងការដោះស្រាយបញ្ហានៅក្នុងសហគមន៍ ភាពក្លាហាន និងការត្រៀមខ្លួន ដើម្បីប្រឈមមុខ នឹងការប្រឆាំងពីសំណាក់ក្រុមប្រឹក្សាឃុំដែល មានបុរសភាគច្រើនជាសមាជិកជាដើម ។

ក្នុងសហគមន៍មួយចំនួនក្នុងខេត្តស្ទឹងត្រែង និងក្រចេះ ដែលនៅទីនោះមាន ក្រុមជនជាតិខ្មែរភាគច្រើនរស់នៅ ស្ត្រីបានទទួលនូវតំណែងដ៏សំខាន់នៅក្នុងក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋាន ។ ស្ត្រីនៅទីនោះបង្ហាញគំនិតថ្មីមួយទៀត ដែលថានៅពេលដែលពួកគាត់ទទួលបាននូវសិទ្ធិអំណាចហើយនោះ ពួកគេអាចមានឥទ្ធិពលលើដំណើរការអភិបាលកិច្ចដូចជាជួយលើកកម្ពស់នូវវិធីសាស្ត្រដឹកនាំមួយដោយផ្អែកលើការពិគ្រោះយោបល់ និងការពិភាក្សាដោយផ្តោតលើតម្រូវការសហគមន៍ និងប្តេជ្ញាក្នុងការកាត់បន្ថយការរើសអើងពាក់ព័ន្ធនឹងយេនឌ័រ ដែលចំណុចទាំងនេះសុទ្ធតែផ្តល់ជា អត្ថប្រយោជន៍ដល់សហគមន៍ទាំងមូល ។

ក្នុងចំណោមអនុសាសន៍ទាំងឡាយ ដែលបានពិពណ៌នាលម្អិតនៅក្នុងការសិក្សាស្រាវជ្រាវនេះ រួមមានដូចខាងក្រោម :

- ទទួលស្គាល់នូវចំណេះដឹង ការយល់ដឹង និងតម្រូវការរបស់ស្ត្រីជនជាតិដើមភាគតិច ។
- ផ្សារភ្ជាប់កម្មវិធីយេនឌ័រទៅនឹងស្ថានភាពបច្ចុប្បន្ន ដែលសហគមន៍ជនជាតិដើមភាគតិចកំពុងជួបប្រទះ ។
- ចៀសវាងការចម្លងវិធីសាស្ត្រដ៏មានឥទ្ធិពល ដែលមិនបានពិចារណាអំពីតម្រូវការចក្ខុវិស័យ និងមធ្យោបាយ ធ្វើការងាររបស់ជនជាតិដើមភាគតិច ។
- គាំទ្រស្ត្រីជនជាតិដើមភាគតិចដែលមានឆន្ទៈ ក្នុងការចូលរួមក្នុងកិច្ចការនយោបាយ ដោយមិនរឹតត្បិតអំណាចដល់ពួកគេ តាមរយៈគម្រោងអប់រំមួយចំនួនដែលមិនទទួលស្គាល់ចំណេះដឹង អត្តសញ្ញាណឋានៈ និងតួនាទី នៅក្នុងសង្គមរបស់ពួកគេឡើយ ។
- ពិនិត្យឡើងវិញចំពោះបញ្ហាយេនឌ័រ នៅក្នុងបរិបទនៃអាជ្ញាធរមូលដ្ឋាន ដើម្បីជួយអោយសមាជិកក្រុមប្រឹក្សា ដែលជាស្ត្រី អាចដោះស្រាយកិច្ចការទាំងអស់ដែលទាក់ទងទៅនឹងតួនាទីរបស់ពួកគេ ហើយនៅពេលជាមួយគ្នា នោះផងដែរ ជួយគាំទ្រដល់តម្រូវការក្នុងការចាត់វិធានការប្រឆាំងនឹងការរើសអើងយេនឌ័រទៀតផង ។
- ពិនិត្យមើលឡើងវិញនូវការសន្មត់ និងតម្រូវការទាំងឡាយ ដែលរារាំងដល់ការចូលរួមរបស់ស្ត្រីជនជាតិដើម ភាគតិចនៅក្នុងក្រុមប្រឹក្សាឃុំ ដែលជាបឋមគឺភាពមានកម្រិតនៃចំណេះដឹងផ្នែកភាសា ។
- ពិនិត្យមើលនូវយន្តការផ្សេងៗដែលអាចធានាដល់ភាពជាតំណាងនៃស្ត្រីជនជាតិដើមភាគតិច ក្នុងឆាកនយោបាយ ដូចជារក្សាទុកចំនួនអាសនៈ ឬកូតា ។
- គាំទ្រដល់សិទ្ធិរបស់ជនជាតិដើមភាគតិចជុំវិញបញ្ហាដីធ្លី និងធនធានផ្សេងៗ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច នៅក្នុងបរិយាកាសសង្គម ។
- បង្ហាញនូវគោលនយោបាយ ដោយលើកជាឧទាហរណ៍ល្អៗ ដែលបានមកពីស្ថានភាពនានា ដែលស្ត្រីទទួលបានមុខតំណែងក្នុងការសម្រេចចិត្ត ហើយត្រូវបានទទួលស្គាល់ថាជាអ្នកដឹកនាំដែលមានការកោតសរសើរនៅក្នុង សហគមន៍របស់ខ្លួន ។



ស្ត្រីជនជាតិដើមភាគតិចចូលរួមសិក្ខាសាលាក្នុងខេត្តក្រចេះ

**ទោះបីជាមានការរីកចំរើននៅក្នុងទសវត្សមុនក៏ដោយ** ស្ត្រីខ្មែរនៅមិនទាន់បានចូលរួមក្នុងឆាកនយោបាយឱ្យបានទូលំទូលាយនៅឡើយទេ។ នៅតាមបណ្តាខេត្ត ភាគឥសាន ដូចជា ខេត្តរតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង និង ក្រចេះ ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច នៅក្នុងកិច្ចការនយោបាយជាផ្លូវការនៅមានការលំបាកច្រើនជាងស្ត្រីខ្មែរ។ ដើម្បីលើកកម្ពស់ អោយមានការ ចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងការសម្រេចចិត្តក្នុងមូលដ្ឋានប្រកបដោយជោគជ័យ ជាការចាំបាច់ គេត្រូវស្វែងយល់អោយបានច្រើនជាងមុនអំពីការយល់ដឹង និង បំណងប្រាថ្នា របស់ស្ត្រីទាំងនោះ។

សហគមន៍ជនជាតិដើមភាគតិចកំពុងតែទទួលរងនូវការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដែលការផ្លាស់ប្តូរបែបនេះ ប៉ះពាល់ដល់របៀបរបបរស់នៅ សេដ្ឋកិច្ច សង្គម និង វប្បធម៌របស់ពួកគេ។ ការផ្លាស់ប្តូរមួយចំនួនប៉ះពាល់ដល់ បុរសផង ដល់ស្ត្រីផង ប៉ុន្តែការផ្លាស់ប្តូរខ្លះប៉ះពាល់តែស្ត្រី ឬ បុរស ដែលការផ្លាស់ប្តូរបែបនេះមានផលប៉ះពាល់យ៉ាងខ្លាំងមកលើជីវិតរបស់ស្ត្រីជនជាតិដើមភាគតិច។ សមត្ថភាព ចូលរួមក្នុងការងារនយោបាយ របស់ស្ត្រីជនជាតិដើមភាគតិច និងដើម្បីធ្វើជាតំណាងសហគមន៍របស់ពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការផ្លាស់ប្តូរទាំងនេះ។

## គោលដៅ និង វិសាលភាពនៃការសិក្សានេះ

ការសិក្សានេះ មានគោលបំណង ធ្វើការស្វែងយល់ស៊ីជំរៅអំពីៈ

- រចនាសម្ព័ន្ធអភិបាលកិច្ចបែបប្រពៃណី ដំណើរការធ្វើការសម្រេចចិត្ត និង តួនាទីជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍ជនជាតិដើមភាគិតិច
- ការផ្លាស់ប្តូរថ្មីៗ នៃរចនាសម្ព័ន្ធបែបប្រពៃណីទាំងនេះ ក៏ដូចជាកត្តានានាដែលជាមូលហេតុនៃការផ្លាស់ប្តូរទាំងនេះ
- បញ្ហាប្រឈម និង ឧបសគ្គនានា ដែលស្ត្រីជនជាតិដើមភាគតិចជួបប្រទះនៅក្នុងការលើកពីរបៀបវារៈនយោបាយរបស់ពួកគេ និង ការចូលរួមក្នុងអភិបាលកិច្ចប្រកបដោយជោគជ័យ
- ឧបសគ្គ ក្នុងការចូលរួមការងារនយោបាយជាផ្លូវការ។

លើសពីនេះ ការសិក្សានេះនឹងលើកឡើងជាអនុសាសន៍ជាក់លាក់ពីរបៀបលើកកម្ពស់ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងការងារនយោបាយ។

ការស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងខេត្តចំនួន ៤ នៅភាគឥសាននៃប្រទេស គឺខេត្តរតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ។

## វិធីសាស្ត្រ

ការសិក្សានេះ ត្រូវបានធ្វើឡើងដោយរួមបញ្ចូលគ្នានូវទិដ្ឋភាពនៃការស្រាវជ្រាវចំនួន៣: ការស្រាវជ្រាវបែបសកម្មភាព ការសិក្សាអំពីស្ត្រី និងការស្រាវជ្រាវអំពីជនជាតិដើមភាគតិច ដូចមានសង្ខេបខាងក្រោមនេះ:

**ការស្រាវជ្រាវសកម្មភាព:** បង្កើតចំណេះដឹង ដោយមានការចូលរួមពីគ្រប់អ្នកដែលមានការពាក់ព័ន្ធ។ ការស្រាវជ្រាវ បែបសកម្មភាព បង្កើតអោយមាននូវសកម្មភាព ដែលសមស្របជាមួយនឹងបរិបទ និងមានគោលបំណងផ្តល់អំណាច ទៅ អោយអ្នកដែលមានការពាក់ព័ន្ធ តាមរយៈការរួមគ្នាវិភាគ និង ឆ្លុះបញ្ចាំង។

**ការសិក្សាអំពីស្ត្រី:** បង្កើតអោយមាននូវវិធីថ្មីៗ ដោយលុបបំបាត់ការសន្មតថាវិទ្យាសាស្ត្រមានលក្ខណៈអព្យាក្រឹតភាព និងបង្ហាញពីភាពលំអៀងរបស់វា ចំណេះដឹងមិនមានលក្ខណៈអព្យាក្រឹតឡើយ ចំណេះដឹងត្រូវបានបង្កើតឡើងនៅក្នុងបរិបទបិតុនិយម ដែលគេប្រៀបធៀបបទពិសោធន៍ ដែលស្ត្រីមានជាមួយនឹងបុរស ដែលជាគំរូ។ តាមរយៈការចាត់ ទុកស្ត្រីជាចំនុចចាប់ផ្តើម យើងអាចរកឃើញនូវទំនាក់ទំនងសង្គម ដែលរើសអើង និងមិនផ្តល់អំណាច ទៅអោយស្ត្រី។

**ការស្រាវជ្រាវអំពីជនជាតិដើមភាគតិច:** មិនទទួលស្គាល់បញ្ញត្តិរបស់លោកខាងលិច លើចំណេះដឹង និងវិទ្យាសាស្ត្រ និងអះអាងថា វិទ្យាសាស្ត្រឆ្លុះបញ្ចាំងពីភាពលំអៀងរបស់វប្បធម៌ធំគ្របដណ្តប់លើវប្បធម៌តូចៗ ដែលបង្កើតវា បើទោះបីជាមានការអះអាងថាវិទ្យាសាស្ត្រមានភាពអព្យាក្រឹត្យ និងភាពមិនលំអៀងក៏ដោយ។ ជនជាតិដើមភាគតិច ជានិច្ចជាកាលត្រូវបានគេពណ៌នា សិក្សា វាស់វែង និងបកស្រាយដោយប្រៀបធៀបជាមួយនឹងគំរូមួយ ដែលបានកំណត់ជាមុនដោយវប្បធម៌ធំ និង វិទ្យាសាស្ត្រ របស់លោកខាងលិច។

គោលការណ៍ណែនាំមួយចំនួនបានផ្តល់ឱ្យដោយផ្ទាល់ក្នុងពេលពិភាក្សា (មើលឧបសម្ព័ន្ធ)។ ការសិក្សានេះ ធ្វើឡើងដោយធ្វើការពិភាក្សាជាមួយនឹងក្រុមស្ត្រី តាមភូមិផ្សេងៗពីគ្នានៅក្នុងខេត្តមណ្ឌលគីរី រតនៈគីរី ស្ទឹងត្រែង និងក្រចេះ ក្នុងខែ ឧសភា មិថុនា និង កក្កដា ឆ្នាំ ២០០៨(មើលឧបសម្ព័ន្ធ)។ ក្រៅពីនេះក៏មានការសំភាសន៍ជាមួយអ្នកដែលមានការពាក់ព័ន្ធនានាផ្សេងទៀត ដូចជា មន្ទីរកិច្ចការនារី និង អង្គការក្រៅរដ្ឋាភិបាលផងដែរ។ ការពិភាក្សា ត្រូវបានរៀបចំឡើងជុំវិញបញ្ហា ដែលពាក់ព័ន្ធជាមួយនឹងការចូលរួមរបស់ស្ត្រីនៅក្នុងការងារនយោបាយ ហើយស្ត្រីអាចរៀបរាប់អំពីបទពិសោធន៍ ក្តីកង្វល់ និង ចក្ខុវិស័យនាពេលអនាគត ទៅតាមអាទិភាពរបស់ខ្លួនដោយសេរី។

ឯកសារនេះសង្ខេបតែលើទិដ្ឋភាពដំបូងនៃគំរោងស្រាវជ្រាវ ដែលមានបន្តដោយជំហានផ្សេងទៀត ដូចជា ការជួបជុំ ការប្រមូលផ្តុំ និងសិក្ខាសាលា ដែលស្ត្រីពាក់ព័ន្ធចូលរួមបន្តស្វែងរកមូលហេតុ និងដំណោះស្រាយ។

# ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច នៅក្នុងរដ្ឋអាជ្ញាធរព្រៃឈើ និង អាជ្ញាធរមូលដ្ឋានជាផ្លូវការ

## ស្ត្រីជនជាតិដើមភាគតិច និង អាជ្ញាធរប្រពៃណី

អាជ្ញាធរប្រពៃណី តំណាងដោយចាស់ទុំនៅក្នុងសហគមន៍ ដែលជ្រើសតាំងដោយសមាជិកសហគមន៍ ដោយសារតែពួកគេមានសមត្ថភាព មើលថែសុខុមាលភាពរបស់អ្នកភូមិ ដើម្បីដោះស្រាយជម្លោះ ដែលកើតឡើងនៅក្នុងសហគមន៍ ឬ ជម្លោះរវាងសហគមន៍នៅជិតខាងគ្នា និងដើម្បីធានាការបន្ត និរន្តរភាពនៃសង្គម ជនជាតិដើមភាគតិច ។

ចាស់ទុំមានតួនាទី រក្សានូវទំនាក់ទំនងគ្នាទៅវិញទៅមក និង ការបំពេញមុខងាររបស់សហគមន៍ ដែលជាមូលដ្ឋានគ្រឹះ នៃជីវិតសង្គមរបស់ជនជាតិដើមភាគតិច ។ លើសពីនេះទៅទៀត ពួកគេធានាអោយសហគមន៍ធ្វើ សមាហរណកម្មយ៉ាងរិជ្ជមាន ចូលទៅក្នុងពិភពស័ក្តិសិទ្ធិ ដែលគ្រប់គ្រងដែនដីរបស់ជនជាតិដើមភាគតិច ។

បើតាមស្ត្រីជាច្រើននាក់លើកឡើង ការផ្លាស់ប្តូរ ដែលកំពុងកើតមានទាំងនេះ កំពុងធ្វើអោយអន្តរាយដល់ប្រព័ន្ធអភិបាលកិច្ច របស់សហគមន៍ជនជាតិដើមភាគតិច ដែលពឹងអាស្រ័យលើចាស់ទុំ។ គុណតម្លៃថ្មីៗ ដែលកើតចេញពីលុយកាក់ ទ្រព្យសម្បត្តិ និងបច្ចេកវិទ្យាកំពុងប៉ះពាល់ដល់របៀបរស់នៅបែបប្រពៃណី ដែលពឹងផ្អែកលើការសន្សំសំចៃ ការប្រឹងប្រែងរួមគ្នា សាមគ្គីភាព និង ការគោរពវិញ្ញាណស័ក្តិសិទ្ធិ និងចាស់ទុំ ។ ក្មេងៗជំនាន់ក្រោយ ពិបាកប្រកាន់ខ្ជាប់ទៅតាមប្រពៃណី ។ ការបំផ្លិចបំផ្លាញបរិស្ថានធម្មជាតិយ៉ាងឆាប់រហ័ស ធ្វើអោយខូចខាតដល់ជំនឿ និង អត្តសញ្ញាណវប្បធម៌របស់ជនជាតិដើមភាគតិច ។ ការវាយលុកពីវប្បធម៌ពីខាងក្រៅតាមរយៈប្រព័ន្ធផ្សព្វផ្សាយកំពុងលុបបំបាត់បន្តិចម្តងៗនូវគុណតម្លៃ និងអត្តសញ្ញាណរបស់ជនជាតិដើមភាគតិច ។

អាជ្ញាធរប្រពៃណី ទទួលខុសត្រូវលើការថែរក្សានូវការរស់នៅចុះសំរុងគ្នានៅក្នុងសង្គមតាមរយៈការប្រើប្រាស់ច្បាប់ដែលជាទំនៀមទម្លាប់ ។ ច្បាប់ទាំងនេះមួយចំនួន ក៏ដោះស្រាយជម្លោះនៅក្នុងគ្រួសារជម្លោះ រវាងប្តី និងប្រពន្ធ ធានាអោយមានការការពារស្ត្រីអោយជៀសផុតពីអំពើហិង្សា និងការរើសអើងផងដែរ ។ អាជ្ញាធរប្រពៃណី រួមទាំងស្ត្រីដែលមានតួនាទីផ្សេងៗនៅក្នុងអាជ្ញាធរនេះផងដែរនោះ ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការផ្តល់ឋានៈមួយអោយស្ត្រីនៅក្នុងសហគមន៍ ។

*យុវវ័យមិនយល់ ពួកគេគិតតែពីលុយ សូម្បីតែប្រជុំ យុវវ័យនឹងមិនមកចូលរួមឡើយ ប្រសិនបើអ្នកមិនអោយលុយពួកគេ! ពួកគេមិនយល់ ពួកគេមិនស្តាប់ មនុស្សចាស់ពួកគេមិនគោរពមនុស្សចាស់ ។ ហើយមនុស្សចាស់អត់មានគំនិតដោះស្រាយបញ្ហានេះ ឬប្រឈមជាមួយនឹង យុវវ័យឡើយ ។ ឥលូវនេះ ពិបាកណាស់សម្រាប់សហគមន៍របស់យើង ។*

*ស្ត្រីជនជាតិទំពួន នៅរ៉ុនសែ*

ការបាត់បង់ការគោរពចំពោះ ចាស់ទុំ និង ចំពោះអាជ្ញាធរប្រពៃណីរបស់ពួកគេ គឺជាការបាត់បង់មួយ សម្រាប់ស្ត្រីជនជាតិដើមភាគតិច និង ជាហានិភ័យ ដែលធ្វើអោយអន្តរាយ ធ្ងន់ធ្ងរដល់តួនាទីរបស់ពួកគេ។

*អាជ្ញាធរប្រពៃណី គឺសំខាន់ជាងអ្វីៗទាំងអស់! សំខាន់ជាងមេភូមិសំខាន់ជាងក្រុមប្រឹក្សាឃុំ ។ ប្រសិនបើគ្មានចាស់ទុំទេ សង្គមនេះមិនអាចដំណើរការបានឡើយ ។ នៅពេលដែលចាស់ទុំមួយចំនួនទទួលមរណៈភាព ជាធម្មតាយើងតែងតែជួបជុំគ្នា ដើម្បីជ្រើសរើសចាស់ទុំថ្មី ។ នេះគឺជាជម្រើសដ៏មានសារៈសំខាន់មួយ ។ ក្នុងករណីជាច្រើន ចាស់ទុំគឺមកពីគ្រួសារ ដែលធ្លាប់ធ្វើជាចាស់ទុំ ឪពុក ឬ ជីតារបស់ពួកគេក៏ធ្លាប់ធ្វើជាចាស់ទុំដែរ ។ នេះជាតួនាទីមួយយ៉ាងសំខាន់ ។*

*ស្ត្រីជនជាតិដើមភាគតិច ដែលជាសមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្ត រតនៈគិរី*

ស្ត្រីជនជាតិដើមភាគតិច យល់ឃើញថា ចាស់ទុំគឺជារចនាសម្ព័ន្ធដែលមិនអាចជំនួសបាននៅក្នុងសង្គមរបស់ពួក គេ។

ប្រព័ន្ធច្បាប់របស់ជនជាតិដើមភាគតិច គឺ មានភាពស្មុគស្មាញ ហើយគ្របដណ្តប់លើផ្នែកជាច្រើន។ ចាស់ព្រឹទ្ធាចារ្យមានតួនាទី ធានាអោយបានការអនុលោមយ៉ាងយុត្តិធម៌បំផុតទៅតាមច្បាប់ទាំងនេះ ហើយការអនុវត្តច្បាប់ទាំងនេះមានគោលបំណងរក្សាអោយសង្គមមានភាពចុះសំរុងគ្នា និងមានដំណើការល្អ។ លើសពីនេះទៅទៀត ចាស់ទុំក៏មានតួនាទីជាទីប្រឹក្សាផងដែរ នៅពេលដែលសហគមន៍ធ្វើការសម្រេចចិត្តលើការគ្រប់គ្រងធនធាន ទំនាក់ទំនងជាមួយសហគមន៍ ដទៃទៀត ឬ ពេលមានវិបត្តិជាដើម។

អ្នកផ្តល់ការសំភាសន៍ភាគច្រើន អះអាងថា អាជ្ញាធរប្រពៃណីមានតែបុរសប៉ុណ្ណោះ ដោយសារតែស្ត្រីជនជាតិដើមភាគតិចគ្មានសិទ្ធិធ្វើជាចាស់ព្រឹទ្ធាចារ្យឡើយ ។ ប៉ុន្តែស្ត្រីនៅតាមភូមិនិយាយប្រាប់យើងផ្សេងទៅវិញ ។

ទម្រង់មួយនៃអាជ្ញាធរជាស្ត្រី នៅក្នុងភូមិ មានទំនាក់ទំនងជាមួយនឹងជីវិតដែលមានវិញ្ញាណស័ក្តិសិទ្ធិសណ្ឋិត ជាអ្នករៀបចំពិធីសាសនា និងជាអ្នកមើលជំងឺ។ ចាស់ទុំជាស្ត្រីផ្សេងទៀត គឺជាឆ្មបបុរាណ។ នៅក្នុងពេល ពិភាក្សាគ្នា ស្ត្រីទាំងនេះនិយាយតិចតួច និងតែពីចំនុចដែលពាក់ព័ន្ធប៉ុណ្ណោះ ហើយត្រូវបានស្ត្រីដទៃទៀតគោរពខ្លាំង និង ត្រងត្រាប់ស្តាប់អ្វីដែលពួក គេនិយាយ។

លើសពីនេះទៅទៀត តួនាទីរបស់ស្ត្រី ដែលទាក់ទិនជាមួយនឹងជំនាញ និងចំណេះដឹងជាក់លាក់ត្រូវបានលើកឡើងក្នុងការពិភាក្សានេះ។

ការផ្លាស់ប្តូរនានា ដែលកំពុងកើតមានឡើង នៅក្នុងសង្គមរបស់ជនជាតិដើមភាគតិច នៅក្រោមសំពាធ "ការអភិវឌ្ឍសេដ្ឋកិច្ច" កំពុងធ្វើអោយចុះខ្សោយនូវជំនឿ និង ការគោរពលើគ្រប់ពិភពប្រពៃណី និង ពិភពអារក្ស អ្នកតា។ ទាំងនេះហើយ ដែលនឹងកាត់បន្ថយសារៈសំខាន់របស់អ្នកដឹកនាំជាស្ត្រី និងរួមចំណែក ធ្វើអោយ ឋានៈរបស់ស្ត្រីជនជាតិដើមភាគតិចចុះខ្សោយ។

*ចាស់ទុំ អាចជាស្ត្រីក៏បាន បុរសក៏បាន ឥលូវនេះ យើងមានស្ត្រីជាចាស់ទុំ ២ ឬ ៣ នាក់ ។ ពួកគេធ្វើការងារដូចគ្នានឹងបុរសដែរ ។ យើងមិនមានបំណងចង់បានតែប្រុស ឬ តែស្រីនោះទេ ។ យើងទៅជួបចាស់ទុំនៅពេលដែលយើងមានបញ្ហា ឬ ជម្លោះ ។ ប្រសិនបើមានស្ត្រី យើងអាចនិយាយជាមួយស្ត្រី ប្រសិនបើមានបុរស យើងនិយាយជាមួយបុរស ។ យើងគ្មានបញ្ហាអ្វីនោះទេ យើងពិភាក្សាទាំងអស់គ្នា ។ ចាស់ទុំគួរពូកែនិយាយជាធម្មតា ពួកគេបញ្ចៀសមិនអោយជម្លោះកើតមានឡើង ពួកគេគោរពអ្នកដទៃពួកគេគិតអំពីអនាគត ពួកគេមានការអប់រំ ពួកគេមានចំណេះដឹងខ្ពស់ ពួកគេមានគតិបណ្ឌិត និងបទពិសោធន៏ ។ នៅពេលដែលចាស់ទុំម្នាក់ស្លាប់ គាត់នឹងតែងតាំងចាស់ទុំថ្មី ។ ចាស់ទុំថ្មីត្រូវជ្រើសរើស ដោយចាស់ទុំ ដែលជិតស្លាប់ ឬ ដែលចាស់ជរា ។*

*ស្ត្រីជនជាតិព្នង រស់នៅក្នុងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី*

ស្ត្រីដើរតួនាទីយ៉ាងសំខាន់ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ហើយជានិច្ចជាកាលមិនត្រូវបានអ្នកសង្កេតពីខាងក្រៅមើលឃើញ ឬយល់អោយបានពេញលេញនោះទេ។ នៅពេលដែលបរិយាកាសវប្បធម៌របស់ អ្នកសង្កេតដែលមកពីក្រៅ គឺជាវប្បធម៌មួយដែលការចូលរួមរបស់ស្ត្រីក្នុងកិច្ចការសាធារណៈដូចជា ពួកគេមានតួនាទីជាមេដឹកនាំសាសនា អ្នកមើលជំងឺ ឆ្មប ឬ អ្នកដែលមានចំណេះដឹង និងជំនាញ មិនត្រូវបានគេចាត់ទុក ថាជារឿងសមស្រប ឬ នៅពេលដែលចក្ខុវិស័យរើសអើង របស់សង្កេតទាំងនេះមានភាពលំអៀង ការចូលរួមរបស់ស្ត្រី នៅតែគេមិនមើលឃើញ និងមិនអោយតម្លៃ ។[១]

## សង្ខេប

- អាជ្ញាធរប្រពៃណី ត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌចម្បងមួយ សម្រាប់វត្តមានរបស់សហគមន៏ជនជាតិ ដើមភាគតិច
- ស្ត្រី ដើរតួនាទីផ្សេងៗគ្នាជាច្រើន ជាអាជ្ញាធរ និង មានកិត្តិនាម នៅក្នុងសហគមន៏: ជាចាស់ព្រឹទ្ធាចារ្យ មេដឹកនាំសាសនា អ្នកមើលជំងឺផ្សំថ្នាំ ឆ្មប និង អ្នកដែលមានចំណេះដឹង
- ជារឿយៗ តួនាទីរបស់ស្ត្រី ត្រូវបានបន្ទាប ដោយអ្នកសង្កេតខាងក្រៅ ដែលលំអៀងដោយសារបុរេវិនិច្ឆ័យយេនឌ័រ និង ជនជាតិ

១."តើស្ត្រីរបស់អ្នកនៅទីណា?" នេះគឺជាសំនួរ ដែលមេដឹកនាំឆេរ៉ូឃី (Cherokee :ជនជាតិដើមភាគតិច នៃអាមេរិកភាគខាងជើង) សួរទៅកាន់ជនជាតិអង់គ្លេស នៅក្នុងកិច្ចប្រជុំមួយ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព។ ស្ត្រីឆេរ៉ូឃី មិនដូចជនជាតិអង់គ្លេសទេពួកគេមានតួនាទីយ៉ាងសំខាន់ជាអ្នកផ្តល់ប្រឹក្សា និង ជាអ្នកធ្វើការសំរេចចិត្ត នៅក្នុងសហគមន៏របស់ពួកគេ (Gonzales P. nig Rodriguez R.១៩៩៨) ។ ស្ថាប័ននានា ដែលដាក់ គំនាបមកលើជនជាតិដើមភាគតិច ដោយមិនទទួលស្គាល់តួនាទី អំណាច ចំណេះដឹង និង កិត្តិនាមរបស់ពួកគេ នឹងធ្វើអោយអន្តរាយដល់ សិទ្ធិ និង ឋានៈរបស់ស្ត្រីជនជាតិដើមភាគតិច ។

## ក្រុមប្រឹក្សាឃុំនៅក្នុងបរិបទជនជាតិដើមភាគតិច

ភាគច្រើននៅក្នុងប្រវត្តិសាស្ត្ររបស់ជនជាតិដើមភាគតិច សង្គមរបស់ពួកគេមានភាពឯករាជ្យពីជាតិខ្មែរ ដូច្នេះ ពួកគេមិនទទួលរងអភិបាលកិច្ចតាមបែបមជ្ឈការនោះឡើយ ។ ស្ថានភាពឯករាជ្យភាពរបស់ពួកគេត្រូវបានបញ្ជាក់ដោយ ការដោះដូរ សួយសាអាករជាទៀងទាត់ រវាងកុលសម្ព័ន្ធជនជាតិដើមភាគតិចជាមួយនឹង ព្រះរាជាណាចក្រខ្មែរនៅក្នុង សតវត្សរ៍មុនៗ (Ironside & Baird, 2003) ។

**សហគមន៍ជនជាតិដើមភាគតិច គឺជាអង្គភាពវិមជ្ឈការ។** ប្រព័ន្ធអភិបាលកិច្ចរបស់ពួកគេមានមូលដ្ឋាននៅថ្នាក់ភូមិដោយសហគមន៍ ដែលមានចាស់ទុំជាអ្នកដឹកនាំធ្វើការសម្រេចចិត្ត ដោយផ្អែកលើការពិគ្រោះយោបល់ ការពិភាក្សា និងការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ ។ នេះមានការបញ្ជាក់កាន់តែច្បាស់បន្ថែមទៀត ដោយកន្លែងរូបវ័ន្តមួយគឺ សាលាភូមិ ដែលមានទីតាំងនៅចំកណ្តាលភូមិ ជាទីសម្រាប់សហគមនជួបជុំគ្នា ។ នេះពន្យល់ពីភាពខុសប្លែកគ្នាយ៉ាងខ្លាំងមួយនៅក្នុងភូមិ និងនៅក្នុងសហគមន៍ បើទោះបីមានភាពដូចគ្នាខាងវប្បធម៌ ភាសា និង ប្រព័ន្ធជំនឿ ដែលកំណត់លក្ខណៈរបស់ក្រុមជនជាតិនីមួយៗក៏ដោយ ។

**តាមពិតទៅ ដំណើរការវិមជ្ឈការ ដែលបានអនុវត្តនៅតាមតំបន់ជនជាតិដើមភាគតិច មិនបានគិតពីចំរុះភាព និងអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចនោះទេ។** ភាសាមូលដ្ឋាន របាយភូមិសាស្ត្ររបស់ក្រុមជនជាតិភាគតិច ទំនាក់ទំនងពិសេសរវាងភូមិមួយជាមួយនឹងភូមិមួយទៀត តួនាទីរបស់អាជ្ញាធរជាប្រពៃណី គឺសុទ្ធតែជាទិដ្ឋភាពនៃរចនាសម្ព័ន្ធសង្គមជនជាតិដើមភាគតិច ដែលមិនត្រូវបានរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាឃុំជាក់ស្តែងយកមកគិតគូរពិចារណា ។ ជាពិសេស ភាសាខ្មែរ ដែលជាភាសាការងារតែមួយគត់ គឺជាឧបសគ្គចម្បងមួយរារាំងមិនអោយជនជាតិដើមភាគតិច ជាពិសេស ស្ត្រី មិនអាចចូលរួមនៅក្នុងការងារនយោបាយបាន ។

*យើងទៅជួបក្រុមប្រឹក្សាឃុំ អោយគេជួយដោះស្រាយ បញ្ហាដីធ្លី ជម្លោះដីធ្លី ឬ ជម្លោះពាក់ព័ន្ធនឹងការចិញ្ចឹម ។ ជាធម្មតា ពួកគេស្តាប់ប្រជាពលរដ្ឋ ហើយអ្នកដែលធ្វើខុសត្រូវបង់លុយ និង រកអ្វីមកផឹកដើម្បីមានសន្តិភាព ។*

***ស្ត្រីជនជាតិព្នង នៅពេជ្រដា ខេត្តមណ្ឌលគិរី***

## តួនាទីរបស់ក្រុមប្រឹក្សាឃុំ

ក្រុមប្រឹក្សាឃុំ ត្រូវបានគេមើលឃើញថាមានទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលកណ្តាល ចូលរួមនៅក្នុងការសម្រេចចិត្តដែលហួសពីថ្នាក់ភូមិ ។ ជារឿយៗ សាលាឃុំ នៅឆ្ងាយពីភូមិ ហើយស្ត្រីទៅជួបក្រុមប្រឹក្សាឃុំដើម្បីអោយគេដោះស្រាយបញ្ហា ដែលមិនអាចដោះស្រាយនៅថ្នាក់សហគមន៍បាន ។ ការយល់ឃើញ មានការផ្លាស់ប្តូរយ៉ាងច្រើន : ចំពោះស្ត្រីមួយចំនួនក្រុមប្រឹក្សាឃុំមានប្រសិទ្ធិភាព នៅក្នុងការដោះស្រាយបញ្ហារបស់សហគមន៍ ។ ស្ត្រីខ្លះទៀតលើកឡើងពីបញ្ហា ដែលពាក់ព័ន្ធជាមួយនឹងថ្លៃ សេវារបស់ក្រុមប្រឹក្សាឃុំ ។

**ឥរិយាបថរបស់ស្ត្រី ប្រែប្រួលទៅតាមសមាសភាពរបស់ក្រុមប្រឹក្សាឃុំ** ៖ នៅពេលដែលក្រុមប្រឹក្សាឃុំ មានសមាជិកកាន់តែច្រើននាក់ជាជនជាតិដើមភាគតិច ស្ត្រីកាន់តែច្រើននាក់ផងដែរយល់ឃើញថាក្រុមប្រឹក្សាឃុំនេះ មានប្រសិទ្ធភាព និង អាចជឿទុកចិត្តបាន ។ ក្រុមប្រឹក្សាឃុំដែលសមាជិកភាគច្រើនជាជនជាតិខ្មែរ ត្រូវបានគេចាត់ទុកថាមិនសូវនៅកៀក នឹងសហគមន៍ឡើយ ។

នៅតាមភូមិ ដែលស្ត្រីត្រូវប្រឈមជាមួយនឹងការលក់ដី ឬ ការរំលោភដីធ្លីខុសច្បាប់ ពីសំណាក់ក្រុមហ៊ុនឯកជន ឬ អ្នកមានអំណាច ស្ត្រីជាច្រើននាក់សម្តែងការមិនសប្បាយចិត្តរបស់ខ្លួនជាមួយអាជ្ញាធរមូលដ្ឋាន ហើយជាលទ្ធផលធ្វើអោយពួកគេលែងជឿទុកចិត្តអាជ្ញាធរទាំងនោះ ។

*ឥលូវនេះ យើងមានបញ្ហានៅទីនេះ! ជម្លោះដីធ្លី ជាមួយក្រុមហ៊ុនមួយ ដែលចាប់យកដី ២៥,000 ហិចតា ទើបតែនឹងកើតថ្មីៗនេះ នៅក្នុងខែ មេសា ឆ្នាំ ២00៨។ ពួកគេមកចាប់យកដីតែម្តង ពួកគេមិនបានសុំការអនុញ្ញាតអ្វីឡើយ ពួកគេនឹងធ្វើចំការលើដីនេះ ។ ពួកគេលេងល្បិចជាមួយយើង ពួកគេអោយប្រជាជនចុះហត្ថលេខាលើក្រដាសសស្អាត ដែលតាមពិតទៅជាឯកសារលក់ដីសោះ ។ ក្រុមហ៊ុននិយាយថា "គ្រាន់តែចាំបន្តិចទៅ អ្នកទាំងអស់គ្នានឹងក្លាយជា កម្មកររលើដីនេះមិនខាន ។ ហេតុអ្វីបានជាអ្នកតវ៉ា?" យើងនឹងមិនធ្វើជាកម្មករដាច់ខាត! អាជ្ញាធរស្នើរអោយយើង ព្រមព្រៀង ដោយគ្រួសារនីមួយៗបានដី ១ ហិកតា ប៉ុន្តែ យើងមិនព្រម ដីប៉ុណ្ណោះមិនគ្រប់គ្រាន់ឡើយ យើងមិន អាចចិញ្ចឹមជីវិតជាមួយនឹងដី ១ ហិកតានៅទីនេះឡើយ ។ ចុះកូនៗរបស់យើងបានអី? មានដីច្រើនទៀត នៅឆ្ងាយពី ទីនេះ ហេតុអ្វីបានជាពួកគេមិនទៅយកដីនោះ? គ្រប់ភូមិទាំងអស់ដែលនៅជិតៗនេះ សុទ្ធតែមានបញ្ហានេះ យើង ដឹងថាមានការពាក់ព័ន្ធជាមួយឃុំ ហើយស្រុកក៏ពាក់ព័ន្ធដែរ ។ យើងមិនចង់បន្ទោសពួកគេឡើយ ព្រោះយើងដឹងថាពួកគេរងសំពាធពីថ្នាក់លើពីក្រុមហ៊ុន និងពីអ្នកដែលមានអំណាច ហើយពួកគេមិនហ៊ាននិយាយ ។ ប៉ុន្តែ យើងមិនចង់បានជំរើសផ្សេងទៀតឡើយ ដូច្នេះយើងនឹងតស៊ូទាល់តែយើងស្លាប់ ដើម្បីដីរបស់យើង ដើម្បីអនាគតរបស់ យើង និង ដើម្បីកូនៗរបស់យើង!*

***ស្ត្រីជនជាតិប៊ុណុង រស់នៅក្នុងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី***

នៅតាមសហគមន៍ដទៃទៀត ដែលអាជ្ញាធរមូលដ្ឋានមានឆន្ទៈ ធ្វើសកម្មភាព ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ ផ្តល់ជំនួយ និង ការគាំទ្រដល់ប្រជាពលរដ្ឋ ស្ត្រីមានការយល់ឃើញផ្សេងទៅវិញ ។

*នៅក្នុងភូមិនេះ យើងមានបញ្ហាសន្តិសុខស្បៀង គ្រួសារខ្លះមានអង្ករហូបមិនគ្រប់ វាលស្រែជាច្រើនកន្លែងជុំវិញ ទីនេះឥលូវ ជារបស់គ្រួសារខ្មែរ និង គ្រួសារជនជាតិដើមភាគតិចដែលមានដីច្រើន។ គ្រួសារមួយចង់លក់ដី ដែលខ្លួនមាន ពួកគេមានកូនចំនួន ៩ នាក់ ពួកគេមិនអាចមានអង្ករគ្រប់គ្រាន់អោយកូនទាំងនោះហូបបានឡើយ។ ពួកគេអត់មានអីហូប ពួកគេមិនអាចទ្រាំទ្របានទៀតឡើយ។ ក្រុមប្រឹក្សាឃុំបានចុះមក ហើយប្រាប់ប្រជាជនកុំអោយលក់ដីរបស់ខ្លួន ហើយបានពន្យល់ពីសារៈសំខាន់របស់ដី និងសារៈសំខាន់នៃការធានាដីសហគមន៍អោយនៅជាប់លាប់។ ប៉ុន្តែសម្រាប់គ្រួសារនេះ គ្មានជំរើសអ្វីផ្សេងទៀតឡើយ។ ដូច្នេះ ប្រជាពលរដ្ឋនៅក្នុងភូមិពិភាក្សា គ្នាបន្ទាប់មកពួកគេមកជុំគ្នា ហើយទិញដីនោះ ដើម្បីកុំអោយមនុស្សចំណូលថ្មីមកទិញបាន។ នេះគឺជាករណីតែមួយប៉ុណ្ណោះ ដែលទើបនឹងកើតឡើងថ្មីៗនេះ ដោយសារតែសហគមន៍ និងក្រុមប្រឹក្សាឃុំសុទ្ធតែយល់ពីសារៈ សំខាន់នៃការថែរក្សាដីរបស់យើង និងកុំអោយលក់ដីទៀត។ បើគ្មានការគាំទ្រពីឃុំទេ ដីជាច្រើនកន្លែង នៅទីនេះប្រាកដជាត្រូវបានគេលក់អស់ជាមិនខាន។*

***ស្ត្រីជនជាតិគ្រឹង រស់នៅក្នុងស្រុកអូរជុំ ខេត្តរតនៈគិរី***

## សង្ខេប

- ស្ត្រីជនជាតិដើមភាគតិច ចាត់ទុកក្រុមប្រឹក្សាឃុំថាជារចនាសម្ព័ន្ធមួយ ដែលមានទំនាក់ទំនងជាមួយ និងថ្នាក់លើ ជាជាងជាមួយនឹងសហគមន
- ការយល់ឃើញរបស់ស្ត្រីជនជាតិដើមភាគតិចលើក្រុមប្រឹក្សាឃុំ ប្រែប្រួលទៅតាមសមាសភាពជនជាតិដើមភាគតិចនៅក្នុងក្រុមប្រឹក្សាឃុំ ទីតាំងឃុំនៅជិតភូមិ និងប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាឃុំ
- ពុំមានបញ្ញត្តិច្បាប់ពិសេសណាមួយ ដែលពិចារណាលើវប្បធម៌ចំរុះរបស់ជនជាតិដើមភាគតិចនៅក្នុងទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំឡើយ។

## ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ នៅតាមតំបន់ជនជាតិដើមភាគតិច

នៅតាមខេត្តគោលដៅនៃការសិក្សានេះ ចំនួនតំណាងជាស្ត្រីដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត មានបង្ហាញដោយសង្ខេប នៅក្នុងតារាងខាងក្រោមនេះ។

ស្ត្រី ក្នុងក្រុមប្រឹក្សាឃុំ នៅប៉ែកឥសានរបស់ប្រទេសកម្ពុជា*

| | សរុប | | ស្ត្រី | | | | |
|---|---|---|---|---|---|---|---|
| | ចំនួនឃុំ | សមាជិកក្រុមប្រឹក្សាឃុំ | ស្ត្រីជាប់ឆ្នោត (%) | មេឃុំ | ជំទប់ទី ១ | ជំទប់ទី ២ | សមាជិក |
| មណ្ឌលគិរី | ២១ | ១០៧ | ១៧ (១៥,៩៥) | - | ១ | ៣ | ១៣ |
| រតនៈគិរី | ៤៩ | ២៥៣ | ៣៦ (១៤,២៣) | - | ៤ | ៨ | ២៤ |
| ក្រចេះ | ៤៦ | ២៨២ | ៤៩ (១៧,៣៨) | ៤ | ៥ | ៣ | ៣៧ |
| ស្ទឹងត្រែង | ៣៤ | ១៧៦ | ២៩ (១៦,៤៨) | ២ | ៥ | ២ | ២០ |

*ទិន្នន័យទទួលបានពីរបាយការណ៍របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោះ នៅកម្ពុជា ស្តីពីការបោះឆ្នោតរដ្ឋបាលឆ្នាំ ២០០៧ www.necelect.org.kh

មិនមានព័ត៌មានស្តីពីសមាសភាពស្ត្រីជាតំណាងនៅក្នុងក្រុមប្រឹក្សាឃុំតាមជនជាតិ នោះឡើយ ដោយសារតែលទ្ធផលមិនត្រូវបានគេបូកសរុបបែងចែកទៅតាមក្រុមជនជាតិ។ ទោះបីជាមានការពិបាកនៅក្នុងការស្វែងរកទិន្នន័យដែលអាចជឿជាក់បានក៏ដោយ ក៏អ្នកផ្តល់សំភាសន៏ទាំងអស់ឯកភាពគ្នាថាការបោះឆ្នោតឆ្នាំ ២០០៧ បានធ្វើអោយស្ត្រីជនជាតិដើមភាគតិចជាច្រើននាក់ ចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំ។ និន្នាការនេះរឹតតែស្តែងចេញច្បាស់នៅក្នុងខេត្តរតនៈគិរី ជាងខេត្តមណ្ឌលគិរី។

## តើស្ត្រីនៅក្នុងសហគមន៍ យល់ឃើញយ៉ាងណាចំពោះក្រុមប្រឹក្សាឃុំជាស្ត្រី?

សម្រាប់ស្ត្រីរស់នៅក្នុងសហគមន៏ភាគច្រើន សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី គឺជាអ្នកសម្របសម្រួលមួយនៅពេលដែលស្ត្រី ត្រូវទៅជួបជាមួយនឹងអាជ្ញាធរនៅខាងក្រៅភូមិ។ ស្ត្រីចង់និយាយជាមួយ នឹងស្ត្រីគ្នាឯងជាង ជាមួយបុរស។ សមាជិកក្រុមប្រឹក្សាជាស្ត្រីហាក់បីដូចជា កាត់បន្ថយនូវការបែកបាក់របស់ជនជាតិដែលវាជាការយល់ឃើញរបស់ស្ត្រីនៅពេលដែលពួកគេធ្វើការងារជាមួយនឹងអាជ្ញាធរឃុំ។ ការចង់បានបែបនេះ មិនត្រូវបានសម្តែងចេញឡើយ

*សម្រាប់យើងទាំងអស់គ្នាសំខាន់ណាស់ ដែលមានស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ។ យើងមិនអាចនិយាយដោយសេរី និង ដោយងាយស្រួលជាមួយនឹងបុរសបានឡើយ ប៉ុន្តែយើងអាចប្រាស្រ័យទាក់ទងជាមួយនឹងស្ត្រីបាន។ ហើយស្ត្រីអាចជួយគ្នាបានល្អជាង។*

***សហគមន៍ពូង ក្នុងស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី***

នៅពេលដែលស្ត្រីត្រូវពិគ្រោះយោបល់ ឬទៅជួបជាមួយអាជ្ញាធរប្រពៃណីនៅក្នុងភូមិ។

ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំសម្របសម្រួល ការធ្វើការងារជាមួយនឹងអាជ្ញាធរ។ លើសពីនេះទៅទៀត តំណាងជាស្ត្រីត្រូវបានគេមើលឃើញថា ជាឱកាសមួយដើម្បីបង្កើនលក្ខខណ្ឌទូទៅរបស់ស្ត្រីតាមរយៈការផ្តល់អោយពួកគេនូវ សមត្ថភាព កិត្តិនាម និងឋានៈ ដែលអាចមានឥទ្ធិពលទៅលើឥរិយាបថរបស់បុរសចំពោះស្ត្រី។

## ឆន្ទៈរបស់ស្ត្រីក្នុងសហគមន៍នៅក្នុងការចូលរួមជាមួយនឹងក្រុមប្រឹក្សាឃុំ

នៅពេលសាកសួរថាតើពួកគេចង់ឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតលើកក្រោយដែរឬទេ ស្ត្រីជាច្រើននាក់នៅក្នុងសហគមន៍បង្ហាញពីឆន្ទៈនិងចំណាប់អារម្មណ៍របស់ពួកគេជាពិសេសស្ត្រីដែលមានវ័យក្មេងជាងគេ។ ស្ត្រីមួយចំនួនចាត់ទុកការជាប់ឆ្នោតរបស់ខ្លួន បើអាចគឺជាវិធីមួយដើម្បីធ្វើអោយកាន់តែប្រសើរនូវស្ថានភាពរបស់ស្ត្រីនៅក្នុងសហគមន៍។ ពួកគេភាគច្រើន ហាក់បីដូចជាចាត់ទុកថានេះគឺជាបញ្ហាប្រឈមមួយ ជាឱកាសដើម្បីបង្ហាញពីសមត្ថភាពរបស់ស្ត្រី និង ដើម្បីជំនះលើការរើសអើងនានា។

**ស្ត្រីចំណាស់ៗ គាំទ្រគំនិតរបស់ស្ត្រីដទៃទៀត ដែលចង់ឈរឈ្មោះជាបេក្ខជន។**

នៅពេលដែលស្ត្រីមិនបង្ហាញពី ចំណាប់អារម្មណ៍ឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ មូលហេតុចម្បងគឺដោយសារការអស់សង្ឃឹម ដែលទាក់ទងទៅនឹងការចេះភាសា មិនចេះនិយាយ អាន និង សរសេរភាសាខ្មែរ។

*ខ្ញុំចង់ជាប់ឆ្នោត ធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ ស្ត្រីដទៃទៀតក៏ចង់បានអញ្ចឹងដែរ។ ជាការល្អប្រសិនបើស្ត្រីជាប់ឆ្នោត ស្ត្រីក៏អាចគ្រប់គ្រងដូចបុរសដែរ ហើយអាចធ្វើការងារខ្លះបានល្អជាងទៀតផង។ លើសពីនេះ ប្រសិនបើស្ត្រី ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ បុរសនឹងយកចិត្តទុកដាក់ចំពោះ ពួកគេថែមទៀត។*

***សហគមន៍គ្រឹង ក្នុងស្រុកអូរជុំ ខេត្តរតនៈគិរី***

## សង្ខេប

- ស្ត្រីជនជាតិដើមភាគតិច ចាត់ទុកសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ជាកត្តាសម្របសម្រួលមួយនៅពេលដែលពួកគេធ្វើការងារជាមួយអាជ្ញាធរ
- សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ត្រូវបានគេយល់ឃើញថាមានសមត្ថភាព និង មានប្រសិទ្ធភាពជាងនៅក្បែរជាមួយនឹងសហគមន៍ជាង និង មិនសូវប្រព្រឹត្តអំពើពុករលួយ
- ស្ត្រីនៅក្នុងសហគមន៍មានការចាប់អារម្មណ៍ក្នុងការឈរឈ្មោះជាបេក្ខជន និងគិតថាការចូលរួមរបស់ពួកគេនៅក្នុងក្រុមប្រឹក្សាឃុំអាចជួយលើកតម្កើងឋានៈរបស់ពួកគេបាន។

## បទពិសោធន៍របស់ស្ត្រីជនជាតិដើមភាគតិច ដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ

ស្ត្រីជនជាតិដើមភាគតិច ភាគច្រើនដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ មានអាយុនៅក្មេង ដោយសារ ស្ត្រីវ័យកណ្តាល និងចំណាស់ជួបបញ្ហាពិបាក ព្រោះមិនចេះភាសា។ ស្ត្រីជាច្រើនបានចូលរួមនៅក្នុងការងារ សហគមន៍។ ស្ត្រីមួយចំនួនជាជនបង្គោល យេនឌ័រ ដែលតែងតាំងដោយនាយកដ្ឋានមូលដ្ឋានរបស់ក្រសួង កិច្ចការនារី។ ខ្លះទៀត ធ្វើសកម្មភាពនៅក្នុងភូមិ ដោយមិនមានអណត្តិការងារច្បាស់លាស់ ប៉ុន្តែមានឈ្មោះល្បី និងទទួលបានការគោរព ពីប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ស្ត្រីមួយចំនួនបាន និងកំពុងចូលរួមនៅក្នុង សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ភូមិ ហើយបន្ទាប់មកត្រូវបានគេតែងតាំងជាបេក្ខជន។ នៅក្នុងករណីមួយចំនួន គណបក្សនយោបាយជ្រើសរើសបេក្ខជនស្ត្រីដោយផ្អែកលើការចេះភាសាខ្មែរ ហើយនៅក្នុង ករណីដទៃទៀត គណបក្សនយោបាយផ្អែកលើប្រជាប្រិយភាពរបស់ស្ត្រីនៅក្នុងសហគមន៍ និងលើជំនាញដែល ពួកគេមាន។

យោងទៅតាមច្បាប់របស់ប្រទេសកម្ពុជា បេក្ខជនឈរឈ្មោះ នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ ត្រូវតែងតាំង ដោយគណបក្សនយោបាយ ហើយត្រូវមានឈ្មោះនៅក្នុងបញ្ជីរបស់គណបក្ស។ ដូច្នេះដំណើរការជ្រើសរើសទាំងមូល និងការរៀបចំលេខរៀង ក្នុងចំណោមបេក្ខជនដទៃទៀត គឺមានសារៈសំខាន់ណាស់ ដើម្បីអោយស្ត្រីបានទទួលជោគជ័យ។ នៅក្នុងប្រព័ន្ធជាក់ស្តែង មានតែអ្នកដែលមានលេខរៀងនៅខាងលើគេក្នុងបញ្ជីឈ្មោះតែប៉ុណ្ណោះ ដែលមានឱកាសជាប់ឆ្នោតបាន។

*ជាការពិតណាស់ទីតាំងឈ្មោះរបស់អ្នកនៅក្នុងបញ្ជីឈ្មោះមានសារៈសំខាន់ណាស់ ពីព្រោះបើអ្នកមិនឋិត នៅទីតាំងល្អទេ អ្នកមិនអាចឈ្នះឆ្នោតបានទេ។ អ្នកត្រូវមានឈ្មោះឱ្យបានខាងលើគេ។*

***សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តរតនៈគិរី***

*គណៈបក្សនយោបាយត្រូវដាក់ឈ្មោះបេក្ខនារីនៅខាងលើនៃបញ្ជីបេក្ខជន បើសិនជានៅខាងក្រោមគេនោះគឺគ្មានសង្ឃឹមឈ្នះ ឆ្នោតនោះទេ។*

***សមាជិកក្រុមប្រឹក្សាឃុំ***
***នៅក្នុងខេត្តមណ្ឌលគិរី***

គ្មានស្ត្រីណាម្នាក់ជាប់ឆ្នោតជាមេឃុំ នៅតាមខេត្តដែលមានជនជាតិដើមភាគតិចរស់នៅឡើយ គឺខេត្តមណ្ឌលគិរី និង ខេត្តរតនៈគិរី។ មានជំទប់ទីមួយជាស្ត្រីម្នាក់ និង ជំទប់ទីពីរជាស្ត្រី ៤ នាក់ នៅក្នុងខេត្តមណ្ឌលគិរី ប៉ុន្តែយើងមិនអាចដឹង ពីជាតិសាសន៍របស់ពួកគេបាន។ នៅក្នុងខេត្តរតនៈគិរី ស្ត្រី ៤ នាក់ជាជំទប់ទី ១ និង ៨ នាក់ជាជំទប់ទី ២ ហើយ ពួកគេគឺ ជាជនជាតិដើមភាគតិច។ នៅក្នុងខេត្តក្រចេះ មានស្ត្រី ៤ នាក់ ដែលជាមេឃុំ និងជំទប់ទី ១ ចំនួន ៥ នាក់ មិនមែនជាជន ជាតិដើមភាគតិចឡើយ។ នៅក្នុងខេត្តស្ទឹងត្រែង យើងមិនអាចបញ្ជាក់ពីចំនួនស្ត្រីជនជាតិដើមភាគតិច ដែលមានតួនាទី ជាមេឃុំ ជំទប់ទីមួយ និងជំទប់ទីពីរបានឡើយ។

*ខ្ញុំជាប់ឆ្នោតនៅក្នុងឆ្នាំ ២០០៧។ ខ្ញុំជាស្ត្រីតែម្នាក់គត់ដែលជាប់ឆ្នោត ដោយសារតែប្រជាពលរដ្ឋនៅក្នុងសហគមន៍ ជឿទុកចិត្តខ្ញុំ និងស្គាល់ខ្ញុំច្បាស់។ ខ្ញុំធ្វើអ្វីៗគ្រប់បែបយ៉ាងតែឯង ខ្ញុំចុះឈ្មោះជាបេក្ខជនដោយគណបក្ស ហើយ ប្រជាជនបោះឆ្នោតអោយខ្ញុំ។ ខ្ញុំមានការគាំទ្រពីអ្នកភូមិ។ ដើម្បីទទួលបានជោគជ័យ អ្នកត្រូវពូកែនិយាយ បើមិនដូច្នោះទេ ប្រជាពលរដ្ឋនឹងមិនចាប់អារម្មណ៍ចំពោះអ្នកឡើយ ហើយប្តីរបស់អ្នកត្រូវតែគាំទ្រអ្នក ព្រោះប្រសិនបើប្តីមិនព្រមទេ អ្នកនឹងមានបញ្ហាជាច្រើននៅក្នុងផ្ទះ។ ប្តីខ្លះ ខ្លាចស្ត្រីគ្មានសមត្ថភាពធ្វើការងារ ហើយទទួលការមាក់ងាយពីមនុស្សដទៃ... ប្តីរបស់ខ្ញុំមានមោទនភាពចំពោះការងាររបស់ខ្ញុំ ហើយនេះមានប្រយោជន៍សម្រាប់ខ្ញុំ។*

*ខ្ញុំអត់មានបញ្ហាច្រើនជាមួយភាសាទេ ព្រោះយើងជួយគ្នាទៅវិញទៅមកនៅក្នុងឃុំ ខ្ញុំរៀបចំការងាររបស់ខ្ញុំជាភាសាព្នង បន្ទាប់មកយើងបកប្រែជាមួយគ្នាជាភាសាខ្មែរ។*

***សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តមណ្ឌលគិរី***

*ខ្ញុំធ្លាប់ចូលរួម នៅក្នុងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងសហគមន៍នេះគឺជាបទពិសោធន៍ចំបងរបស់ខ្ញុំ។ ខ្ញុំក្លាយជាកូនកំព្រា នៅពេលដែលខ្ញុំមានអាយុ ៣ ឆ្នាំ ហើយខ្ញុំរៀបការពេលអាយុ ១៥ ឆ្នាំ។ ខ្ញុំរៀនបានតែថ្នាក់ទី ១ ប៉ុណ្ណោះ ពីឆ្នាំ ១៩៨១ ដល់ ១៩៨៣។ ពេលនោះ ខ្ញុំរៀនជាមួយគ្រូនៅក្រោមដើមឈើ ពេលនោះគ្មានសាលារៀនឡើយ ប៉ុន្តែមានគ្រូ ហើយក្មេងៗសុទ្ធតែបានចូលរៀន។ ខ្ញុំត្រូវបានគេជ្រើសរើសអោយធ្វើជាសមាជិករបស់គណៈកម្មាធិការសហគមន៍ ប៉ុន្តែខ្ញុំមានអារម្មណ៍មិនល្អ ដោយសារតែខ្ញុំមិនចេះអាន និងសរសេរ បានល្អ។ ដូច្នេះ ខ្ញុំរៀនដោយខ្លួនឯង ខ្ញុំព្យាយាមបង្កើនចំណេះដឹងរបស់ខ្ញុំ និងរៀនបន្ថែមទៀត ជាពិសេស ដើម្បីចេះអាន និងសរសេរភាសាខ្មែរ។ បន្ទាប់មកខ្ញុំចូលរួមនៅក្នុងសកម្មភាពសហគមន៍ច្រើនថែមទៀត ហើយនៅពេលដែលការបោះឆ្នោតចុងក្រោយមកដល់ ខ្ញុំបានឈរឈ្មោះជាបេក្ខជន ហើយជាប់ឆ្នោត។*

***សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តរតនៈគិរី***

ការធ្លាប់ធ្វើជាសកម្មជន ផ្តល់អោយស្ត្រីនូវបទពិសោធន៍ការងារជាមួយសហគមន៍ យល់ពីសេចក្តីត្រូវការរបស់ពួកគេ បង្កើតទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាពជាមួយនឹងសមាជិករបស់សហគមន៍ និងកសាងបទពិសោធន៍របស់ពួកគេនៅក្នុងការស្វែងរកដំណោះស្រាយ។ ប៉ុន្តែ **សមាសភាពជាជនជាតិដើមភាគតិចនៅក្នុងឃុំ គឺមានភាពពាក់ព័ន្ធខ្លាំង នេះបើតាមការលើកឡើងរបស់ស្ត្រី។** បរិយាកាសដែលមានជនជាតិដើមភាគតិច សម្របសម្រួលអោយមានការប្រាស្រ័យទាក់ទងរវាងស្ត្រីនិងស្ត្រីគ្នាឯង និងកាត់បន្ថយឧបសគ្គដែលស្ត្រីជួបប្រទះ។ តាមពិតទៅស្ត្រីដែលធ្លាប់ជាប់ឆ្នោតទាំង២អណត្តិ បានបង្កើនឱកាសអោយគេទទួលស្គាល់ថាពួកគេ ជាសមាជិកក្រុមប្រឹក្សាឃុំដែលមានសមត្ថភាពនិងការទទួលខុសត្រូវស្មើគ្នា។

ជាការពិតណាស់ ស្ត្រីដែលបានជាប់ឆ្នោតទាំងពីអណត្តិបានបង្កើននូវឱកាសក្នុងការទទួលយកជាសមាជិក

ក្រុមប្រឹក្សាឃុំជាមួយនឹងសមត្ថភាពនិងការទទួលខុសត្រូវស្មើគ្នា។ តួនាទី ដែលស្ត្រីជនជាតិដើមភាគតិចមាននៅក្នុងក្រុមប្រឹក្សាឃុំ មានផ្សេងៗពីគ្នាទៅតាមបទពិសោធន៍របស់ពួកគេបរិបទនៃការបោះឆ្នោតរបស់ពួកគេ ទំនាក់ទំនងរបស់ពួកគេជាមួយសហគមន៍ និងសមាសភាពជាជនជាតិដើមភាគតិចនៅក្នុងក្រុមប្រឹក្សាឃុំ។ កត្តាទាំងអស់នេះ រួមចំណែកកំណត់ពីអំណាច ដែលសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី អាចរក្សាបាន។

*ខ្ញុំកាន់តំណែងនេះ តាំងពីឆ្នាំ ២០០២ មក។ ខ្ញុំចូលរួមនៅក្នុងគ្រប់សកម្មភាពទាំងអស់ មិនត្រឹមតែយេនឌ័រប៉ុណ្ណោះទេ គឺគ្រប់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធជាមួយស្ត្រី។ នៅក្នុងក្រុមប្រឹក្សាឃុំមានការសហការគ្នាល្អ ហើយសមាជិកដទៃទៀតស្តាប់ខ្ញុំ ប៉ុន្តែមិនមែនចេះតែបែបនេះរហូតនោះទេ វាអាស្រ័យច្រើនលើទំនាក់ទំនង។*

*ស្ត្រីត្រូវចេះនិយាយ គាត់ត្រូវតែដឹងពីរបៀបនិយាយទៅកាន់ចាស់ព្រឹទ្ធាចារ្យ របៀបសម្រុះសម្រួលរបៀបដោះស្រាយបញ្ហា ហើយគាត់ត្រូវមានបទពិសោធន៍ និងគតិបណ្ឌិត។ ខ្ញុំទទួលបានការបណ្តុះបណ្តាលពីអង្គការមិនមែន រដ្ឋាភិបាលមួយ។*

*សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តរតនៈគិរី*

*ឥលូវនេះ ក្រុមប្រឹក្សាឃុំមានសមាជិក សុទ្ធតែជាជនជាតិដើមភាគតិច វាគឺជាការងាយស្រួល ដោយសារតែយើងអាចនិយាយជាមួយគ្នា ដោយប្រើភាសារបស់យើង ហើយយើងមានវប្បធម៌ដូចគ្នា។ សមាជិកដទៃទៀតស្តាប់អ្វីដែលខ្ញុំនិយាយ។ ខ្ញុំធ្លាប់បានចូលរួមនៅក្នុងសកម្មភាពសហគមន៍ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ហើយខ្ញុំបានធ្វើការងារជាច្រើននៅក្នុងភូមិ ខ្ញុំនៅតែធ្វើឥលូវនេះ។ ខ្ញុំតែងតែលើកឡើងប្រាប់ពួកគេអំពីអ្វីដែលខ្ញុំដឹងពីកិច្ចប្រជុំ និង សិក្ខាសាលានានា និងអ្វីដែលខ្ញុំរៀនចេះពេលចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះ។*

*សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តរតនៈគិរី*

## សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី មានតួនាទីជា "អ្នកទទួលបន្ទុកផ្នែកយេនឌ័រ"

នៅក្នុងការពិភាក្សាយើងបានរកឃើញថា ជាញឹកញយសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ក៏ដូចជាបុរសយល់ឃើញថា ស្ត្រីមានតួនាទីពាក់ព័ន្ធតែនឹងការងារ "យេនឌ័រ" ប៉ុណ្ណោះ។ ប៉ុន្តែជារឿយៗ សេវាដែលត្រូវបានគេបែងចែកជា "បញ្ហាយេនឌ័រ" គឺជាសេវាសង្គមសំខាន់ៗ ដែលពាក់ព័ន្ធនឹងសុខភាព អនាម័យ ការថែទាំកុមារពិការភាព ការថែទាំមនុស្សចាស់ និងការស្រង់ស្ថិតិ និងទិន្នន័យប្រជាពលរដ្ឋបែងចែកទៅតាមភេទ។ ជំនួសអោយអត្ថន័យថា ជាការប្រឆាំងនឹងការរើសអើងយេនឌ័រ និងការលើកតម្កើងស្ត្រីពាក្យ "យេនឌ័រ" ទៅជាមានន័យថា តម្រូវការសង្គមទៅវិញ។ ការយល់ច្រឡំបែបនេះ គឺអាចបង្កអោយមានបញ្ហាធំដោយសារ "បញ្ហាយេនឌ័រ" ត្រូវបានគេចាត់ទុកថា ជាបញ្ហាតូចតាច នៅក្នុងបរិបទពហុ

ការងាររបស់ឃុំ ដូច្នេះហើយការងារយេនឌ័រ មិនទទួលបានថវិកា ដើម្បីគាំទ្រអោយបានគ្រប់គ្រាន់ទេ។ ដូច្នេះហើយ សេវាផ្សេងៗដែលមានសារៈសំខាន់ សម្រាប់តម្រូវការរួមដែលចាំបាច់ចំពោះសុខុមាលភាពទូទៅ មិនទទួលបានការយកចិត្តទុកដាក់ឡើយ ។

ម្យ៉ាងវិញទៀត គំនិតយេនឌ័រនេះ បានងាកចេញពីខ្លឹមសារសំខាន់របស់វា ដែលសំដៅលើការរើសអើងប្រឆាំង នឹងការត្រួតត្រាលើស្ត្រី រឹតត្បិតនូវការលើកកម្ពស់គោលនយោបាយស្តីពីសិទ្ធិស្ត្រី។

នៅក្នុងករណីជាច្រើន ការស្រង់ស្ថិតិអំពីស្ត្រី និងកុមារនៅក្នុងភូមិ ត្រូវបានគេរៀបរាប់មកថា ជាការងារចម្បងរបស់សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ហើយត្រូវបានគេហៅថា "យេនឌ័រ" ។

*គំនិតពង្រីកការទទួលខុសត្រូវរបស់ស្ត្រី លើបញ្ហាដទៃទៀតលើសពីបញ្ហា យេនឌ័រ គឺជាការមួយល្អ ប៉ុន្តែពួកគេត្រូវមានសមត្ថភាពសិន ។ ស្ត្រីមានការអប់រំទាប ដូច្នេះពួកគេមិនអាចចូលរួមបាន ។ ប្រសិនបើរាជរដ្ឋាភិបាលចង់បង្កើនចំនួនស្ត្រីនៅក្នុងជួរអាជ្ញាធរមូលដ្ឋាន ពួកគេគួរផ្សព្វផ្សាយអំពីកម្មវិធីនេះ និងជូនដំណឹងដល់ គ្រប់គ្នាអោយបានដឹង ដើម្បីអោយស្ត្រីអាចដាក់ពាក្យបាន ។ គណបក្សនីមួយៗ គួរជ្រើសរើសស្ត្រីពី ១០ ទៅ ១៥ នាក់ ហើយបណ្តុះបណ្តាល ដើម្បីអោយពួកគេក្លាយជាប្រជាពលរដ្ឋល្អ ។ ខ្ញុំគាំទ្រកម្មវិធីរបស់រាជរដ្ឋាភិបាល ប៉ុន្តែបុរសៗអាចខឹងនឹងគំនិតនេះ ហើយកម្មវិធីនេះគួរគាំទ្រ និង អប់រំពួកគេផងដែរ ។*

*សមាជិកក្រុមប្រឹក្សាឃុំជាបុរស នៅក្នុងខេត្តមណ្ឌលគិរី*

គំនិតដែលថា ស្ត្រីនៅក្នុងជួរ អាជ្ញាធរមូលដ្ឋានគួរចូលរួមនៅក្នុងគ្រប់បញ្ហាទាំងអស់ ហើយតួនាទីរបស់ពួកគេមិនគួរកំហិតត្រឹមតែ "យេនឌ័រ" នោះ បានទទួលការរិះគន់ពីសមាជិកក្រុមប្រឹក្សាឃុំដែលជាបុរស ។

សមាជិកក្រុមប្រឹក្សាឃុំជាបុរសម្នាក់ នៅក្នុងឃុំមួយដែលគ្មានតំណាងស្ត្រីជាប់ឆ្នោត បានបញ្ចេញនូវទស្សនៈ ថាតួនាទីរបស់ស្ត្រីនៅមានកម្រិតនៅឡើយ....

*ជាការល្អ ប្រសិនបើមានស្ត្រី ព្រោះពួកគេអាចនិយាយ និង ពន្យល់អំពីអ្វី ដែលបុរសមានការខ្វះខាតអៀន ដូចជា អនាម័យ ភាពស្អាត ....*

*សមាជិកក្រុមប្រឹក្សាឃុំជាបុរស នៅក្នុងខេត្តមណ្ឌលគិរី*

## ការអោយតម្លៃស្ត្រីទាបនៅក្នុងក្រុមប្រឹក្សាឃុំ

ក្នុងករណីមួយចំនួនស្ត្រីដើរតួនាទីជា "អ្នកថែទាំសាលាឃុំ" ឆុងតែ បោសសំអាត និងស្វាគមន៍ភ្ញៀវនៅក្នុងកិច្ចប្រជុំ។ ការអោយតួនាទីស្ត្រីទាប ធ្វើជាអ្នកបម្រើ និងអ្នកទទួលភ្ញៀវ គឺជានិន្នាការមួយដែលកើតមានជាទូទៅ។ មានតែការអត់ធ្មត់ និងសេចក្ដីក្លាហានប៉ុណ្ណោះ ដែលអាចអោយស្ត្រីម្នាក់ៗ បញ្ជាក់ថាខ្លួនឯងជាតំណាងនយោបាយពិតប្រាកដ។ បន្ទាប់ពីជាប់ឆ្នោត មិនមែនស្ត្រីគ្រប់រូបសុទ្ធតែត្រៀមខ្លួនរួចរាល់ ដើម្បីប្រឈមនឹងការងារនេះទេ ដែលការប្រឈមនេះ តម្រូវអោយមានភាពរឹងមាំនិងការប្ដេជ្ញាចិត្តខ្ពស់ទើបអាចធ្វើបាន។

*ខ្ញុំខ្ញុំធ្វើជាជំទប់ទីពីរ តាំងពីឆ្នាំ ២០០៧មកម្ល៉េះ ខ្ញុំត្រូវបានជ្រើសរើសដោយអាជ្ញាធរ ដែលចុះមកក្នុងភូមិ ហើយនិយាយថា ពួកគេត្រូវការស្ត្រីម្នាក់នៅក្នុងបញ្ជី។ អ្នកភូមិជ្រើសយកខ្ញុំ ហើយបន្ទាប់មកពួកគេស្នើ ហើយខ្ញុំយល់ព្រម។ ប៉ុន្តែ តួនាទីរបស់ខ្ញុំនៅក្នុងក្រុមប្រឹក្សាឃុំ គ្មានអ្វីពាក់ព័ន្ធនឹងការងារឃុំឡើយ។ ខ្ញុំឆុងតែ ដាំទឹក និងទទួលភ្ញៀវពេលមានប្រជុំ។ មេឃុំ និងស្មៀនឃុំ គឺជាអ្នកធ្វើការសំរេចចិត្តគ្រប់បែបយ៉ាង។ ស្មៀនរៀបចំថវិការបស់ឃុំ ខ្ញុំអត់ចេះអ្វីទាំងអស់អំពីលុយកាក់ អំពីការធ្វើផែនការ ឬ អំពីអ្វីផ្សេងទៀត។ យើងធ្វើតែតាមការសម្រេចរបស់មេឃុំ និង ស្មៀនឃុំតែប៉ុណ្ណោះ។ ខ្ញុំមិនដឹងថាតើមានកម្មវិធីអ្វីខ្លះនោះទេ ដោយសារតែអ្វីៗគ្រប់បែបយ៉ាងគ្រប់គ្រងដោយស្មៀន គាត់ទទួលលុយ ហើយជាអ្នកគ្រប់គ្រងលុយរបស់ឃុំ។ ខ្ញុំមិនដែលធ្លាប់ឃើញថវិកាបែងចែកសម្រាប់កិច្ចការ ស្ត្រី និង កុមារ។ ខ្ញុំមិនដែលធ្លាប់ពិភាក្សាអំពីគំរោងអ្វីឡើយ។*

***សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តស្ទឹងត្រែង***

## សង្ខេប

- បទពិសោធន៍ធ្វើជាក្រុមប្រឹក្សាឃុំ មានការប្រែប្រួល ទៅតាមកាលៈទេសៈនៃការបោះឆ្នោតរបស់ពួកគេ បទពិសោធន៍ធ្លាប់ធ្វើជាសកម្មជនសហគមន៍ និង កត្តានានាដទៃទៀត
- មាននិន្នាការមួយ គឺអោយសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ធ្វើការងារគ្រប់គ្រងបញ្ហា "យេនឌ័រ"
- ពាក្យ "យេនឌ័រ" ហាក់បីដូចជាគ្របដណ្ដប់លើសេវាទូទៅ ដូចជា សុខភាព អនាម័យ ការថែទាំកុមារ ប៉ុន្តែ មិនឆ្លុះបញ្ចាំងតម្រូវការ ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងការរើងអើងយេនឌ័រ
- ជារឿយៗ "ការងារយេនឌ័រ" មានអាទិភាពទាបជាងបញ្ហាដទៃទៀត ហើយទទួលបានថវិកាតិចតួច ដូច្នេះហើយ មិនបានគិតគូរដល់សេវាសង្គមសំខាន់ៗ
- សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ត្រូវតស៊ូ ដើម្បីបញ្ជាក់ពីតួនាទីរបស់ពួកគេ ហើយនៅក្នុងករណីខ្លះពួកគេទទួលរងការអោយតម្លៃទាប និង ការមិនអោយតម្លៃ

## ឧបសគ្គរារាំងស្ត្រីជនជាតិដើមភាគតិចមិនអោយចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំ

### ឧបសគ្គដែលមើលឃើញដោយអ្នកពាក់ព័ន្ធ

តំណាងអង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរបស់មន្ទីរកិច្ចការនារី និងអ្នកតបសំភាសន៍ភាគច្រើនលើកឡើងថា កង្វះខាត **ការអប់រំ** គឺជាឧបសគ្គចម្បងតែមួយគត់ដែលរារាំងស្ត្រីជនជាតិដើមភាគតិចមិនអោយចូលរួមជាមួយនឹងក្រុមប្រឹក្សាឃុំ ។ មានការបរិយាយតិចតួចទៅលើការពិតដែលថាសម្រាប់ស្ត្រីជនជាតិដើមភាគតិច ភាសាខ្មែរគឺជាភាសាទី ២ ហើយភាសាទី ១ របស់ពួកគេមិនត្រូវបានគេសរសេរនោះឡើយ ។ មានអ្នកដែលមានការពាក់ព័ន្ធតិចតួចណាស់ ដែលធ្លាប់បានធ្វើការអង្កេត ឬការស្រាវជ្រាវក្នុងគោលបំណងស្វែងយល់អំពីការយល់ឃើញផ្ទាល់ខ្លួនរបស់ស្ត្រីជនជាតិដើមភាគតិច អំពីតម្រូវការរបស់ពួកគេផ្នែកការគាំទ្រ ដើម្បីអោយមានការចូលរួមនៅក្នុងនយោបាយ ។

គម្លាតអក្ខរភាព មិនពាក់ព័ន្ធជាមួយនឹងការរើសអើងយេនឌ័រឡើយ ។ **កង្វះខាតមន្ត្រីជាស្ត្រី**កាន់តួនាទីគ្រប់គ្រងក្នុងកម្មវិធីយេនឌ័ររបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារតាមតំបន់ជនជាតិដើមភាគតិច អាចជាបច្ច័យលុបបំបាត់ការរើសអើងយេនឌ័រ ចេញពីឧបករណ៍ទ្រឹស្តីដែលតម្រង់ទិសដៅការងាររបស់អង្គការទាំងនោះ ។[២]

ដូច្នេះ ដោយសារតែការមិនចេះអក្សរខ្មែរ ស្ត្រីជនជាតិដើមភាគតិចទៅជាគ្មាន ការអប់រំ ខ្វះខាតជំនាញ និងសមត្ថភាព ហើយនេះបើកផ្លូវអោយមាន "កម្មវិធីបណ្តុះបណ្តាលជាច្រើន" ដែលខកខានមិនបានផ្តោតលើចំនុចសំខាន់ ដែលស្ត្រីជនជាតិដើមភាគតិចត្រូវការនោះគឺ**ការចេះអក្សរខ្មែរ**។

*ភាគច្រើន ពឹងផ្អែកលើគណបក្ស តើពួកគេពិតជាគាំទ្រអោយ ស្ត្រីចូលរួមនៅក្នុងការបោះឆ្នោតដោយរបៀបណា តាមរយៈបញ្ជីឈ្មោះ និង តាមរយៈគោលនយោបាយរបស់ពួកគេ ។គណបក្សជាច្រើននិយាយអំពីយេនឌ័រ តែតាមពិតទៅ ពួកគេមិនបានគាំទ្រការចូលរួមរបស់ស្ត្រីពិតប្រាកដនោះទេ ។ នៅពេលដែលនៅក្នុងឃុំមួយ សូម្បីតែអ្នកទទួលបន្ទុកយេនឌ័រក៏ជាប្រុស ដែរនោះ តើវាអាចសាកសមជាមួយនឹងការផ្តល់អំណាចដល់ ស្ត្រី ដោយរបៀបណា?*

*ប្រសិនបើគណបក្សនយោបាយ ចង់គាំទ្រស្ត្រី ពួកគេត្រូវអោយ ស្ត្រីចូលរួម ពួកគេត្រូវដាក់ស្ត្រីនៅលេខរៀងលើគេក្នុងបញ្ជី ឈ្មោះ ជួយស្ត្រីក្នុងយុទ្ធនាការឃោសនា និង ផ្តល់គ្រប់អ្វីៗ ដែលស្ត្រីត្រូវការដើម្បីបានតួនាទីនយោបាយ ។ អ្វីដែលកើត ឡើងនោះគឺថា ស្ត្រីនៅតាមតំបន់ជនជាតិដើមភាគតិច បង្កើនសមត្ថភាពរបស់ពួកគេ ដោយធ្វើជាសកម្មជននៅក្នុងសហគមន៍របស់ពួកគេ ហើយធ្វើដូច្នេះមិនប្រាកដជាធ្វើអោយពួកគេក្លាយ ជាបេក្ខជនល្អ សម្រាប់គណបក្សនយោបាយ នោះទេ ...*

***អង្គការមិនមែនរដ្ឋាភិបាល ក្នុងខេត្តមណ្ឌលគិរី***

២. តាមពិតទៅ នៅពេលពិភាក្សាអំពី "គម្រោងយេនឌ័រ" ជាមួយនឹងបុគ្គលិកភេទប្រុសរបស់អង្គការមិនមែនរដ្ឋាភិបាល ស្ត្រីដែលមានមុខតំណែងទាបជាង ជាអ្នកលើកតែ និង ទឹកមកអោយយើង ដែលនេះជាការស្តែងចេញយ៉ាងច្បាស់លាស់ ដោយខ្លួនឯង ។

នៅក្នុងបរិបទនេះ ឧបសគ្គដែលរារាំងការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច ហាក់បីដូចជាមាននៅគ្រប់ទីកន្លែង ហើយថែមទាំងលើសពីស្ថានភាពពិតទៀតផង ។ ឧទាហរណ៍ នៅក្នុងខេត្តមណ្ឌលគិរី អ្នកដែលមានការពាក់ព័ន្ធជាច្រើនបានលើកឡើងពីតម្រូវការអោយសមាជិកក្រុមប្រឹក្សាឃុំយ៉ាហោចណាស់រៀនចប់ត្រឹម "ថ្នាក់ទី ៩" ។ ប៉ុន្តែ ច្បាប់ ដែលគ្រប់គ្រងការបោះឆ្នោតរដ្ឋបាល និងកំណត់ពីលក្ខណៈសម្បត្តិរបស់បេក្ខជនមិនបាន លើកឡើងពីលក្ខខណ្ឌបែបនេះឡើយ ។ បើមានលក្ខខណ្ឌបែបនេះមែន បេក្ខជនជាបុរសជាច្រើននាក់ក៏នឹងមិនអាចកាន់តំណែងបានដែរ ។

មានស្ថាប័នពាក់ព័ន្ធមួយចំនួនតូចប៉ុណ្ណោះ ដែលបានផ្តល់ការវិភាគមួយអោយយើង ដោយមើលរំលងភាពមិនចេះអក្សររបស់ស្ត្រី និងផ្តល់នូវទស្សនៈវិស័យស៊ីជំរៅជាង ។

សម្រាប់អ្នកដែលមានការពាក់ព័ន្ធដទៃទៀតភាពក្រីក្រ និង កង្វះខាតមធ្យោបាយ គឺជាឧបសគ្គយ៉ាងចម្បង ។ តាមពិតទៅយើងអាចសង្កេតឃើញ នៅពេលយើងចុះសិក្សាផ្ទាល់គ្រប់សមាជិកក្រុមប្រឹក្សាឃុំទាំងអស់សុទ្ធតែមានម៉ូតូជិះ ដែលនេះហួសពីកម្រិតសេដ្ឋកិច្ចរបស់គ្រួសារជនជាតិដើមភាគតិចជាច្រើន ។

ការមានមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ មិនបានរ៉ាប់រងសូម្បីតែលើចំណាយតិចតួចបំផុត ដែលពាក់ព័ន្ធជាមួយនឹងការបំពេញភារកិច្ចរបស់ពួកគេ ។

> *ឥលូវនេះ យើងមិនមានបញ្ហា នៅក្នុងការលើកទឹកចិត្តអោយស្ត្រីចូលរួមនោះទេ ពួកគេសកម្មជាងមុន យើងឃើញ មានស្ត្រីច្រើនជាងបុរស ចូលរួមនៅក្នុងកិច្ចប្រជុំ ។ យើងឃើញថា ស្ត្រីមានឆន្ទៈការពារធនធានរបស់ពួកគេជាង ពួកគេប្រឆាំងនឹងសំពាធ ហើយពួកគេមិនចង់លក់ដីរបស់ពួកគេឡើយ ។ បុរស គឺជាអ្នកដែលចង់លក់ គឺជាអ្នកដែលចង់ទិញនេះ ទិញនោះ ជាអ្នកដែលលង់នៅក្នុងជីវិតទំនើប ។ យើងចាំបាច់ត្រូវស្វែងយល់បន្ថែមទៀតអំពីអ្វីដែលកំពុងកើតមានឡើង ព្រោះវាមានសារៈសំខាន់ចំពោះការងាររបស់យើងនិងចំពោះសហគមន៍ ។*
>
> ***អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងខេត្តរតនៈគិរី***

អ្នកដែលមានការពាក់ព័ន្ធខ្លះ ទទួលស្គាល់ថា ឥរិយាបថរបស់ស្ត្រីជនជាតិដើមភាគតិច ពាក់ព័ន្ធជាមួយនឹងការចូលរួមនៅក្នុងរចនាសម្ព័ន្ធសង្គមកំពុងមានការផ្លាស់ប្តូរ ។ ស្ត្រីមាននិន្នាការចូលរួមនៅក្នុងកិច្ចប្រជុំមានសកម្មភាពខ្លាំងក្លាជាងមុន និងបញ្ចេញគំនិតច្រើនជាងមុន ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននេះ គឺជាទិដ្ឋភាពដ៏សំខាន់មួយ ហើយនៅក្នុងការពិភាក្សារបស់យើង ពួកគេមានចំណាប់អារម្មណ៍ដោយសុទ្ធចិត្តចង់ស្វែងយល់ពីដំណើរការនានា ដែលពាក់ព័ន្ធជាមួយនឹងតួនាទីយេនឌ័រ ដែលពួកគេសង្កេតឃើញនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ។

## សង្ខេប

- ជារឿយៗ បុរេនិច្ឆ័យ និងការលំអៀង ធ្វើអោយមានការយល់ខុសថា ស្ត្រីជនជាតិដើមភាគតិច ល្ងង់ខ្លៅ មិនមានសមត្ថភាព និង មិនមានជំនាញ
- ជារឿយៗ ភាពមិនចេះអក្សរខ្មែរ ធ្វើអោយមានការភ័ន្តច្រឡំ និងត្រូវបានគេចាត់ទុកថាជាការខ្វះ

ខាតជំនាញ ជាទូទៅ

- ជារឿយៗ ស្ត្រីជនជាតិដើមភាគតិច គឺជាក្រុមគោលដៅរបស់កម្មវិធីអប់រំនានា ប៉ុន្តែ កម្រជាគោលដៅរបស់កម្មវិធី ដែលទទួលស្គាល់ចំណេះដឹង និងជំនាញរបស់ពួកគេ
- ការរើសអើងយេនឌ័រ មិនត្រូវបានគេទទួលស្គាល់ និង យកមកធ្វើការពិចារណាឡើយ
- បើតាមអ្នកដែលមានការពាក់ព័ន្ធមួយចំនួន ភាពក្រីក្រ កង្វះខាតឆន្ទៈរបស់គណបក្សនយោបាយសុទ្ធតែជាឧបសគ្គខ្លះៗ ក្នុងចំណោមឧបសគ្គនានា ដែលស្ត្រីកំពុងប្រឈម
- ចំពោះអ្នកដែលមានការពាក់ព័ន្ធខ្លះ ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច នៅក្នុងកិច្ចការនយោបាយគឺមានការកើនឡើង ហើយអង្គការមិនមែនរដ្ឋាភិបាលគួរតែគាំទ្រនិន្នាការនេះ។

## ឧបសគ្គដែលមើលឃើញដោយស្ត្រីក្នុងសហគមន៍

ការពិភាក្សាជាមួយស្ត្រី នៅក្នុងសហគមន៍ ស្តែងចេញអោយឃើញថា **ពួកគេមិនមានអារម្មណ៍ថាខ្លួនឯងមិនមានសមត្ថភាពគ្រប់គ្រាន់** ដើម្បីបំពេញការទទួលខុសត្រូវរបស់មុខតំណែងនោះឡើយបើទោះបីជាមានការព្រួយបារម្ភ ជាទូទៅអំពីការចេះភាសាខ្មែរ ដែលជាភាសាទី២សម្រាប់ពួកគេក៏ដោយ ក៏ពួកគេមិនមានអារម្មណ៍ថាខ្លួនមិនសូវមានសមត្ថភាពកាន់តួនាទីជាអាជ្ញាធរនោះដែរ។

ស្ត្រីជាច្រើននាក់បានចាត់ទុកកង្វះខាតសិទ្ធិ និងអំណាចរបស់ពួកគេ គឺជាឧបសគ្គចម្បងជាងគេដែលរារាំងមិនអោយពួកគេចូលរួមក្នុងជីវិតនយោបាយអោយបានពេញលេញ។ ការតែងតែខ្វះពេលវេលាដោយសារតែការបែងចែកកិច្ចការ និងការងារមិនស្មើគ្នារវាងស្ត្រី និងបុរស មិនបានផ្តល់ឱកាសអោយស្ត្រីទទួលបានទូវលក្ខណៈសម្បត្តិបឋមមួយចំនួន ដើម្បីឈរឈ្មោះជាបេក្ខជនដូចជា រៀនអាន និងសរសេរភាសាខ្មែរជាដើមនោះទេ។ មិនមែនស្ត្រីទេ គឺបុរសដែលត្រូវទទួលការអប់រំបន្ថែមដើម្បីផ្តល់ឱកាសអោយស្ត្រីបានចូលរួមនៅក្នុងកិច្ចការនយោបាយក្នុងមូលដ្ឋាន!

> *ខ្ញុំចង់ឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតលើកក្រោយ និងធ្វើការងារអោយដូចបុរស។ យើងមិនត្រូវមានតែបុរសកាន់អំណាចនោះទេ ព្រោះពួកគេប្រើប្រាស់តួនាទីនេះប្រឆាំងនឹងស្ត្រី។ ស្ត្រីក៏ល្អដូចជាបុរសដែរ។ បញ្ហាគឺនៅត្រង់ថា នៅពេលពួកគេរៀបចំកិច្ចប្រជុំបោះឆ្នោតនៅក្នុងភូមិ ពួកគេហៅតែបុរសតែប៉ុណ្ណោះ។ បញ្ហាចម្បងគឺការអប់រំរបស់បុរស បុរសគួរទទួលបានការអប់រំដើម្បីជួយស្ត្រី និងសម្រាលបន្ទុកការងារផ្ទះ និងធ្វើការងារដើម្បីជួយជីវិតរស់នៅ ។ល។*
>
> *ស្ត្រីជនជាតិលន់ រស់នៅក្នុងស្រុកតាវែង ខេត្តរតនៈគិរី*

បើទោះបីជាការចូលរួមនៅថ្នាក់ភូមិហាក់បីដូចជា មិនជាបញ្ហាម្រាប់ស្ត្រីជាច្រើននាក់ក៏ដោយ ការចូលរួមនៅក្នុងសកម្មភាពខាងក្រៅភូមិ ហាក់បីដូចជាបង្កអោយមានបញ្ហាច្រើន។ ចំពោះស្ត្រីមួយចំនួនការលំបាកគឺនៅត្រង់ថា ពួកគេមានឧបសគ្គច្រើនជាងមួយ ដែលត្រូវជំនះឧបសគ្គមួយគឺ យេនឌ័រ និងឧបសគ្គមួយទៀត គឺជនជាតិ។ ជាមួយនឹងកំណើនប្រជាជនចំណាកស្រុកជនជាតិ

ខ្មែរនៅក្នុងតំបន់នេះដែលជារឿយៗ ស្ថានភាពគ្របដណ្តប់ផ្នែកសង្គម និងសេដ្ឋកិច្ចជាងគំរូបតិយាបថរបស់ជនជាតិខ្មែរកំពុងក្លាយជាប្រភពថេរនៃការប្រៀបធៀប និងការខកចិត្ត ។

នៅតាមសហគមន៍ជាច្រើន ស្រ្តីត្អូញត្អែរអំពីការដែលគេប្រជុំមិនហៅពួកគេអោយចូលរួម ហើយមានតែបុរសប៉ុណ្ណោះដែលគេជ្រើសរើសអោយធ្វើជាបេក្ខជន ។ ដូច្នេះហើយបានជាគ្មានស្រ្តីណាម្នាក់ជាប់ឆ្នោតសោះនៅក្នុងសហគមន៍ទាំងនេះ ។ ស្រ្តីជនជាតិដើមភាគតិចចេះនិយាយភាសាខ្មែរតិចជាងបុរសជនជាតិដើមភាគតិច ហើយក៏មិនមានឱកាសដើម្បីបំពេញកង្វះខាតនេះផងដែរ ។

**បញ្ហាមិនចេះអក្សរខ្មែរត្រូវរៀបរាប់ជារួមអោយបានច្បាស់** ពាក់ព័ន្ធជាមួយនឹងជីវិតរបស់ស្រ្តីជនជាតិដើមភាគតិច និងបញ្ហាដែលពួកគេជួបប្រទះ ដូចដែលពួកគេបានលើកឡើង ។ស្រ្តីមិនមានពេលរៀនភាសាខ្មែរ និងគ្មានពេលគិតអំពីខ្លួនឯងដូចជាសំរាក និងកំសាន្តនោះទេ ។

*តើត្រូវធ្វើដូចម្តេច ដើម្បីអោយមានស្រ្តីកាន់តែច្រើននៅក្នុងក្រុមប្រឹក្សាឃុំ? ដំបូងរដ្ឋាភិបាលត្រូវគាំទ្រសិទ្ធិរបស់ស្រ្តី ព្រោះការអប់រំតែមួយគត់ មិនអាចផ្លាស់ប្តូរស្ថានភាពរបស់ស្រ្តីបានឡើយ ។ បុរស និង ស្រ្តី ត្រូវស្មើភាពគ្នា នេះគឺជាច្បាប់ត្រឹមត្រូវសំរាប់អាជ្ញាធរ ។ ហើយស្វាមីគួររៀនធ្វើជាមេផ្ទះផងដែររៀនធ្វើម្ហូប បោកគក់ មើលកូន ។ល។ និង ។ល។ យើងនឹងរីករាយគ្រប់គ្រង សហគមន៍ យើងអាចធ្វើបាន!*

*ស្រ្តីជនជាតិទំពួន រស់នៅស្រុករៀនសែ*
*ខេត្តរតនៈគីរី*

*គេមិនហៅយើងទៅប្រជុំសម្រាប់ការបោះឆ្នោតឡើយ ប៉ុន្តែបើគេបានអញ្ជើញយើងវិញ យើងមិនគិតថាយើង បានត្រៀមខ្លួនរួចឡើយ យើងគិតថា យើងមិនអាចចូលរួម និង ធ្វើជាបេក្ខជនដែលសាកសមនោះទេ ។ យើងមានកូន ដែលត្រូវមើលថែ តើយើងអាចទៅប្រជុំដោយមានកូនស្ពាយពីក្រោយជាមួយយ៉ាងដូចម្តេច? ប្រជាជនខ្មែរមិនមាន កូនដាក់ពីក្រោយឡើយ នៅពេលដែលពួកគេចូលរួមក្នុងកិច្ចប្រជុំយើងមានការខ្មាសអៀន យើងចង់ធ្វើដូចជនជាតិ ខ្មែរអញ្ចឹងដែរ ។*

*ស្រ្តីជនជាតិព្នង រស់នៅអូរាំង ខេត្តមណ្ឌលគីរី*

## សង្ខេប

- ស្ត្រីជនជាតិដើមភាគតិច មិនគិតថាខ្លួនមិនមានសមត្ថភាព ដើម្បីធ្វើជាសមាជិកក្រុមប្រឹក្សាឃុំនោះទេ
- ពួកគេចាត់ទុក ការរើសអើងដែលពាក់ព័ន្ធជាមួយយេនឌ័រ ថាជាឧបសគ្គចម្បង ចំពោះការចូលរួមរបស់ពួកគេនៅក្នុងនយោបាយ
- លក្ខខណ្ឌរបស់ពួកគេជាស្ត្រី និង ការបែងចែកការងារមិនស្មើភាពគ្នារវាងបុរស និងស្ត្រី កំពុងបង្អាក់វឌ្ឍនៈភាពរបស់ពួកគេ
- ស្ត្រីជនជាតិដើមភាគតិច ត្រូវជំនះឧបសគ្គ របាំងយេនឌ័រ ជនជាតិ និងសង្គមជាច្រើន។

## ឧបសគ្គដែលមើលឃើញដោយក្រុមប្រឹក្សាឃុំជាស្ត្រី

ស្ត្រីជាប់ឆ្នោតហើយដែលកំពុងបម្រើការងារនៅក្នុងក្រុមប្រឹក្សាឃុំបានបង្ហាញពីឧបសគ្គជាច្រើនថែមទៀត។

*ខ្ញុំមានចំការស្វាយចន្ទី ប៉ុន្តែប្តីរបស់ខ្ញុំជាអ្នកមើល។ ប្រសិនបើប្តីរបស់ខ្ញុំមិនសហការនិងជួយខ្ញុំទេ ហើយប្រសិនបើខ្ញុំត្រូវទៅចំការរាល់ថ្ងៃ ដើម្បីចិញ្ចឹមជីវិត តើខ្ញុំអាចធ្វើការងារនៅក្នុងក្រុមប្រឹក្សាឃុំបានយ៉ាងដូចម្តេច? តើខ្ញុំអាចចូលរួមក្នុងកិច្ចប្រជុំសិក្ខាសាលា ឬ ចុះទៅភូមិដោយរបៀបណា?*

*សមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្តរតនៈគីរី*

*សម្រាប់ខ្ញុំ តាមពិតឧបសគ្គចម្បងៗ ដែលរារាំងមិនអោយស្ត្រីចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំ គឺភាពចេះអក្សរ ប៉ុន្តែ រួមផ្សំជាមួយនឹងប្តីរបស់ពួកគេផងដែរ។ ប្តីត្រូវឯកភាព និងសហការ ហើយការអប់រំរបស់ពួកគេក៏មានសារៈសំខាន់ផងដែរ ព្រោះប្រសិនបើប្តីមិនយល់ពីភាពពាក់ព័ន្ធរបស់ការងារនេះ នោះស្ត្រីនឹងជួបការលំបាកខ្លាំងណាស់។ ស្ត្រីត្រូវមានទំនុកចិត្ត និងត្រូវមានពេលទំនេរខ្លះ ប្រសិនបើពួកគេធ្វើស្រែចំការ នោះពួកគេគ្មានពេលវេលានោះទេ។ គណបក្សនយោបាយ ដែលរៀបចំបញ្ជីឈ្មោះ ក៏ដើរតួសំខាន់ផងដែរ ព្រោះពួកគេអាចគាំទ្រស្ត្រី។ប៉ុន្តែ អ្វីដែលសំខាន់បំផុតនោះគឺ ឆន្ទៈ ការប្តេជ្ញាចិត្តធ្វើការងារបម្រើសហគមន៍ ទឹកចិត្តខ្ពស់ដើម្បីគាំទ្រសហគមន៍ នេះគឺជាកត្តាសំខាន់ជាងគេបំផុតដែលអាចជំនះឧបសគ្គនានាបាន។*

*សមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្តរតនៈគីរី*

ការគាំទ្ររបស់ស្វាមី ត្រូវបានស្ត្រីជាប់ឆ្នោតទាំងអស់លើកឡើងថា ជាកត្តាមួយដែលអាចធ្វើឱ្យពួកគេបាត់បង់តំណែង ប្រសិនបើគ្មានការគាំទ្រទេនោះ ។ **ស្ត្រីដែលសកម្មក្នុងនយោបាយត្រូវធ្វើការងារឆ្ងាយពីផ្ទះ មិនអាចធ្វើការគ្រប់ការងារផ្ទះទាំងអស់បានទេ ហើយត្រូវតែមានការចរចារគ្នា** បើមិនដូច្នោះទេវាអាចធ្វើឱ្យជម្លោះកើតមានបាន ។ ដូចដែលស្ត្រីមួយចំនួនបានលើកឡើង មិនមែនគ្រប់បុរសទាំងអស់សុទ្ធតែទទួលយកបាននោះទេ ហើយការយល់ដឹងរបស់ស្វាមីគឺមានសារៈសំខាន់ណាស់ ។ ស្ត្រីមួយចំនួនបាននិយាយថាប្តីចាំបាច់ត្រូវទទួលបានការអប់រំដើម្បីយល់ដឹងអំពីតួនាទីថ្មីរបស់ស្ត្រី ។

ស្ត្រីជនជាតិដើមភាគតិចអាចឈរឈ្មោះបោះឆ្នោត និងធ្វើការងារជាសមាជិកក្រុមប្រឹក្សាឃុំបាន តែនៅពេលដែលជីវភាពរស់នៅរបស់ពួកគេមានភាពប្រសើរជាប់លាប់ ហើយបន្ទុកការងាររបស់ពួកគេថយចុះប៉ុណ្ណោះ ។ **ភាពក្រីក្រ គឺជាកត្តាមួយដែលកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតនយោបាយ ។ គណបក្សនយោបាយដើរតួនាទីសំខាន់:** ពួកគេអាច ឬមិនអាចគាំទ្រ ពួកគេអាចដាក់ស្ត្រីក្នុងបញ្ជីឈ្មោះនៅលេខរៀងដែលសម្រួលការបោះឆ្នោតរបស់ពួកគេ ពួកគេអាចជួយស្ត្រីនៅក្នុងយុទ្ធនាការបោះឆ្នោត និងផ្តល់ការគាំទ្រក្រោយពេលដែលស្ត្រីជាប់ឆ្នោត ។

ប៉ុន្តែ ស្ត្រីដែលជាប់ឆ្នោត បានគូសបញ្ជាក់លើគំនិតដែលថា **ការប្តេជ្ញាចិត្តធ្វើការងារ ដើម្បីសុខុមាលភាពរបស់សហគមន៍** គឺជាកត្តាសំខាន់ជាងគេតែមួយគត់ ។ ស្ត្រីត្រូវតែត្រៀមខ្លួនរួចរាល់ ដើម្បីលះបង់ពេលវេលា និងកាត់បន្ថយជីវិតឯកជនរបស់ពួកគេនៅពេលបម្រើការងារជាសមាជិកក្រុមប្រឹក្សាឃុំ ។ ស្ត្រីមួយចំនួនចាត់ទុក **ភាពក្លាហាន** ជាលក្ខណៈសម្បត្តិដ៏សំខាន់មួយ ព្រោះការងារនេះតម្រូវឱ្យមានការឈរនៅពីមុខមនុស្សជាច្រើននាក់ ហើយនៅក្នុងករណីភាគច្រើនពីមុខមនុស្សប្រុសដើម្បីប្រឈមនឹងស្ថានភាពប្រឈមមុខដាក់គ្នា និងធ្វើដំណើរភាគច្រើនតែឯងលើផ្លូវដែលពិបាកខ្លាំង ។

## សង្ខេប

- សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីជនជាតិដើមភាគតិច រកឃើញឧបសគ្គជាច្រើនដែលរារាំងការចូលរួមរបស់ស្ត្រី
- ស្វាមីត្រូវយល់ និងគាំទ្រការងាររបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ
- ស្ត្រី ដែលឈរឈ្មោះជាបេក្ខជន មិនអាចជាអ្នកក្របានឡើយ ពួកគេត្រូវធ្វើដំណើរ ពួកគេមមាញឹក ពួកគេមិនអាចធ្វើការងារជាប់លាប់នៅក្នុងស្រែចំការរបស់ពួកគេឡើយ ពួកគេគួរមានសន្តិសុខផ្នែកសេដ្ឋកិច្ច ។
- ការគាំទ្ររបស់គណបក្សនយោបាយ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ភាពជោគជ័យ
- ចាំបាច់ត្រូវមានការប្តេជ្ញាចិត្ត និងការលះបង់ខ្ពស់ ដែលនេះអាចជាកត្តាកម្រិតមួយ
- ស្ត្រីចាំបាច់ត្រូវក្លាហាន ហ៊ាននិយាយ និងត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមនឹងការជំទាស់ពីក្រុមប្រឹក្សាដែលមានសមាជិកភាគច្រើនជាបុរស ។

## ឧបសគ្គដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច-សង្គម និងការផ្លាស់ប្តូរវប្បធម៌

### ការងាររបស់ស្ត្រី

*"ឥលូវនេះ ស្ត្រីជាអ្នកធ្វើការងារទាំងអស់យើងធ្វើការយ៉ាងច្រើនជាងមុន ហើយធ្វើដោយគ្មានបុរសជួយ! តើប្រុសៗធ្វើអ្វីខ្លះទៅ? ពួកគេផឹកស្រា! ពួកគេជិះម៉ូតូដើរលេង! ភាពទំនើបនិយម បានកែប្រែការងាររបស់បុរស ពួកគេលែងផលិតឧបករណ៍ប្រើប្រាស់ ឬជួសជុលផ្ទះដូចមុនទៀតហើយ ពួកគេមានការងារ ដែលត្រូវធ្វើតិចជាងមុន ពួកគេមិនសូវចូលព្រៃ ពួកគេអត់ទៅរកឈើ ឬកាប់ឫស្សី ដូចមុនទៀតឡើយ ។ភាគច្រើនពួកគេទៅរកស៊ី ប្រសិនបើពួកគេចេះរកស៊ី បើមិនដូច្នោះទេ ពួកគេជាអ្នកចាយលុយ ។"*

***ស្ត្រីជនជាតិចារ៉ាយ រស់នៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនៈគីរី***

ស្ត្រីនៅក្នុងគ្រប់សហគមន៍ ដែលយើងបានចុះទៅឯកភាពព្រមគ្នាថា: មានការផ្លាស់ប្តូរនៅក្នុងរបៀបបែងចែក ការងាររវាងបុរសនិងស្ត្រី។ បន្ទុកការងាររបស់ពួកគេបានកើនឡើង ពេលវេលាសម្រាប់លំហែរ និងសំរាកមានការថយចុះ ហើយពួកគេឃើញខ្លួនឯងជាប់នៅក្នុងស្ថានភាពមួយដែលគេត្រូវទទួលខុសត្រូវលើការរកទទួលទានប្រចាំថ្ងៃ។ នៅក្នុងទីផ្សារសេដ្ឋកិច្ច ជាការពិតការងាររបស់ស្ត្រី បានបាត់បង់តម្លៃ ព្រោះគេមើលឃើញថា មិនមែនជាប្រភពនៃចំណូល។ ប៉ុន្តែក្រុមគ្រួសារនៅតែពឹងផ្អែកលើការងារដែលស្ត្រីធ្វើនៅក្នុងកសិដ្ឋានគ្រួសារដដែល ជាហេតុធ្វើឱ្យក្រុមហ៊ុននានា និងកសិដ្ឋានធំៗអាចជួលកម្មករឱ្យធ្វើការក្នុងតម្លៃឈ្នួលទាបបំផុត ដោយសារតែការចិញ្ចឹមជីវិតរបស់កម្មករទាំងនោះត្រូវបានផ្តល់ដោយស្ត្រីជាកសិករ ដែលស្ត្រីធ្វើការងារនេះតែឯង។

កត្តាដទៃទៀត ចូលរួមចំណែកបង្កើនការងារអោយស្ត្រី និងបន្ថយគុណភាពនៃជីវិតរបស់ពួកគេ។ កត្តាដំបូងគេ គឺការបាត់បង់ដែនជំរកធម្មជាតិ តាមតំបន់ជនជាតិដើមភាគតិច។

*"នៅជិតភូមិលែងមានព្រៃដូចមុនទៀតហើយ ។ គេបានអោយក្រុមហ៊ុនមួយមកកាប់ដើមឈើ ។ យើងមិនអាចទៅបេះបន្លែដែលយើងធ្លាប់បេះកាលពីមុនទៀតឡើយ ឥលូវនេះយើងមានព្យុះធំៗ ដោយសារតែកាលពីមុនយើងមានព្រៃការពារភូមិមិនអោយត្រូវខ្យល់បក់បោកមកលើខ្លាំង យើងជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ រៀងរាល់ពេលវាហាក់បីដូចជាអាកាសធាតុកាន់តែឆ្កួតទៅៗ ។ យើងអត់មានឈើយកមកសាងសង់ ឬជួសជុលផ្ទះ យើងត្រូវដើររាប់សិបគីឡូម៉ែត្រ ដើម្បីប្រមូលអូសយកមកចំអិនអាហារ នេះជាការងារមួយនឿយហត់ខ្លាំងណាស់ ។ យើងមិនអាចរករុក្ខជាតិមកធ្វើជាឱសថបាន ដូចជា ឱសថសម្រាប់ជំងឺពាក់ព័ន្ធនឹងឈាម រកលែងមានទៀតហើយ ។ គ្មានសត្វព្រៃអោយយើងបរបាញ់ទៀតទេ ហើយសូម្បីតែត្រីនៅក្នុងទន្លេក៏មានចំនួនតិចជាងមុនដែរ ។ ដូច្នេះ ជីវិតកាន់តែយ៉ាប់យឺនទៅៗ ។ ក្រុមហ៊ុនកាប់ដើមឈើហើយក៏ចេញទៅអស់ ។ "*

***ស្ត្រីជនជាតិទំពួន រស់នៅក្នុងស្រុកវឿនសៃ ខេត្តរតនៈគីរី***

## ជីវិតគ្រួសារ

ជម្លោះ នៅក្នុងគ្រួសារកាន់តែមានការកើនឡើង ហើយជម្លោះជាច្រើនកើតឡើងដោយសារតែបុរសចង់ទិញនេះចង់ទិញនោះ ដូចជា ចង់លក់ដី ដើម្បីបានលុយជាដើម ។ លើសពីនេះទៅទៀត ជម្លោះមានទំនាក់ទំនងជាមួយនឹងកំណើននៃភាពមិនអាចជឿជាក់លើបុរស លើការចែករំលែកការងារ និងការទទួលខុសត្រូវនៅក្នុងគ្រួសារ ។ បុរសងាយស្រួលលង់នឹងគុណតម្លៃថ្មីៗ ដែលសេដ្ឋកិច្ចទីផ្សារសេរីនាំចូលមកក្នុងសហគមន៍ ។ ត្រូវនិយាយថា **ភាពទំនើបចូលមកក្នុងសង្គមរបស់ជនជាតិដើមភាគតិច ដោយនាំមកជាមួយនូវភាពបិតុនិយម (បិតាធិបតេយ្យខ្ពស់។** ជីវិតសង្គមមានទ្រង់ទ្រាយទៅតាមតម្រូវការ ការកំសាន្តរបស់បុរស ដូចជា ខារ៉ាអូខេ ហើយការរកស៊ីផ្លូវភេទកាន់តែមានច្រើនឡើងៗនៅក្នុងតំបន់នេះ ។

*ហេតុអ្វីបានជាបុរសៗផឹកច្រើនជាងមុន? ដោយសារឥលូវនេះ ពួកគេមានលុយ! ពួកអ្នកមានចូលចិត្តផឹកព្រោះពួកគេមានលុយច្រើន ហើយអ្នកក្រផឹកទាល់តែអស់លុយបន្តិចបន្តួចដែលពួកគេមាន ឬសូម្បីតែពួកគេអត់លុយ ។ ពួកគេចង់សប្បាយ ហើយប្រសិនបើពួកគេដឹងថាប្រពន្ធខ្លួនឯងមានលុយ ពួកគេសុំហើយសុំទៀតទាល់តែបានលុយយកទៅផឹក ។ កាលពីមុនពួកគេផឹកតែស្រាពាងប៉ុណ្ណោះ ឥលូវនេះពួកគេផឹកស្រាសនៅខាងក្រៅភូមិ ហើយផឹកស្រាបៀរ ទៀតផង ។*

*ស្ត្រីជនជាតិចារ៉ាយ រស់នៅក្នុងស្រុកអូយ៉ាដាវ ខេត្តរតនៈគិរី*

ការទទួលទានស្រា គឺជាធាតុដ៏សំខាន់មួយនៃការប្រាស្រ័យទាក់ទងគ្នា របស់សហគមន៍ជនជាតិដើមភាគតិច ។ ឥលូវនេះ គេផឹកស្រានៅខាងក្រៅសហគមន៍ តាមហាង បារ ខារ៉ាអូខេ ដែលទើបមានថ្មីៗនេះ ហើយមានតែបុរសប៉ុណ្ណោះ ដែលទៅតាមកន្លែងទាំងនេះ ។

ការអភិវឌ្ឍន៍សេដ្ឋកិច្ចបច្ចុប្បន្ន ផ្តោតសំខាន់លើ **ការប្រកួតប្រជែង បុគ្គលនិយម និងការបង្កើនទ្រព្យ។** មិនត្រឹមតែការងារមានប្រយោជន៍ ដែលស្ត្រីធ្វើប៉ុណ្ណោះទេដែលបាត់បង់តម្លៃ សូម្បីតែការងារក្នុងគ្រួសារ ដូចជា មើលថែកូន ប្តី ចាស់ជរា អ្នកដែលមានជំងឺ ក៏បាត់បង់តម្លៃផងដែរ ។

**ប្រសិនបើបំលាស់ប្តូរទាំងនេះ ត្រឹមតែផ្តល់ប្រយោជន៍អោយបុរសៗ តែក្នុងរយៈពេលខ្លី ផ្តល់អោយពួកគេនូវរង្វាន់ដែលមើលឃើញភ្លាមៗ នៅក្នុងរយៈពេលវែងទៅមុខទៀត បំលាស់ប្តូរទាំងនេះនឹងធ្វើអោយអន្តរាយដល់សុខុមាលភាពរបស់ស្ត្រីផង និងរបស់បុរសផងជាមិនខាន។**

## សង្ខេប

- បុរសហាក់ដូចជាងាយលង់នឹងអ្វី ដែលផ្តល់អោយដោយសេដ្ឋកិច្ចទីផ្សារ និង បរិស្ថានសង្គម ដែលមានវប្បធម៌លំអៀងទៅរកបុរស
- ការមិនសប្បាយចិត្ត ជារឿយៗ សម្តែងចេញតាមរយៈឥរិយាបថបង្ខិតបង្ខំ ដូចជា ការប្រើបំពានគ្រឿងស្រវឹង ដោយសារជីវិតសង្គម និងជីវិតផ្ទាល់ខ្លួន ដែលមានចក្ខុវិស័យថ្មី លំអៀងទៅខាងបុរស ការប្រកាន់គំនិតរើសអើង កំពុងជំនួសតួនាទីវិជ្ជមានរបស់បុរស ។

## ជីវិតសង្គម

ការផ្លាស់ប្តូរពីការផលិតទុកសម្រាប់ចិញ្ចឹមជីវិត ទៅជាសេដ្ឋកិច្ចដែលគ្មានព័ត៌មាន និងគ្មាននិយ័តកម្មត្រឹមត្រូវ បង្កអោយមានផលប៉ះពាល់ដល់មូលដ្ឋាននៃជីវិតសេដ្ឋកិច្ច និងសង្គមរបស់សហគមន៍ជនជាតិដើមភាគតិច ។

*"កាលពីមុន យើងមានសាមគ្គីភាពល្អ តែឥលូវនេះ អ្វីៗគ្រប់បែបយ៉ាង គឺសុទ្ធតែត្រូវការលុយ មនុស្សខ្វល់តែពីសាច់ញាតិជិតរបស់ខ្លួន កាលពីមុនពេលដែលគេត្រលប់ពីបរបាញ់សត្វក្នុងព្រៃវិញ ពួកគេហូបរួមជាមួយគ្នា ។ ឥលូវនេះ ពួកគេកាត់សាច់តែមួយចំណែកតូច ហើយនៅសល់យកទៅលក់នៅក្នុងទីប្រជុំជន ។"*

***ស្ត្រីជនជាតិគ្រឹង នៅស្រុកអូរជុំ ខេត្តរតនៈគីរី***

សហគមន៍រស់នៅក្រោមភាពតានតឹងមានស្ត្រីជាច្រើននាក់ត្អូញត្អែរ អំពីកង្វះខាតសាមគ្គីភាព ការបែកបាក់នៅក្នុងសហគមន៍ និងកំណើននៃភាពខុសគ្នារវាងអ្នកមាន និងអ្នកក្រ ។

ការមកដល់របស់អ្នកចំណូលថ្មីជាច្រើននាក់ពីបណ្តាខេត្តនានារបស់ ប្រទេសកម្ពុជាកំពុងបង្កើតអោយមានប្រភពបញ្ហាថ្មីៗសម្រាប់ស្ត្រី ។ ការរៀបអាពាហ៍ពិពាហ៍ចម្រុះមានការកើនឡើង ហើយបញ្ហាដែលពាក់ព័ន្ធជាមួយនឹងការរស់នៅរួមគ្នា និងការរស់នៅជិតគ្នារបស់ក្រុម ដែលមានវប្បធម៌ផ្សេងគ្នា ក៏មានការកើនឡើងផងដែរ ។

## សង្ខេប

- គុណតម្លៃថ្មីៗ ដែលនាំចូលដោយសេដ្ឋកិច្ចទីផ្សារ និងការទិញលក់ដីធ្លី និងធនធាននានា កំពុងធ្វើអោយបែកបាក់ទំនាក់ទំនង នៅក្នុងសហគមន៍
- សាមគ្គីភាពមានការថយចុះ ក្នុងពេលដែលភាពខុសប្លែកគ្នានៅក្នុងសង្គមមានការកើនឡើង
- ការមកដល់នៃអ្នកចំណូលថ្មីជាច្រើននាក់ ចូលរួមចំណែកធ្វើអោយចុះខ្សោយនូវអត្តសញ្ញាណរបស់សហគមន៍

## អំពើហិង្សាលើស្ត្រី

អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគ្រប់អ្នកដែលមានការពាក់ព័ន្ធទាំងអស់លើកឡើងថា ជាបញ្ហាចម្បងមួយ ដែលស្ត្រីរស់នៅតាមតំបន់ជនជាតិដើមភាគតិចជួបប្រទះ ។ ប៉ុន្តែនៅពេលដែលយើងសាកសួរស្ត្រីនៅក្នុងសហគមន៍ និងសមាជិកក្រុមប្រឹក្សាឃុំ ដើម្បីដឹងលម្អិតថែមទៀតពីអំពើហិង្សានេះ យើងមិនអាចបញ្ជាក់បានអំពីទស្សនះ ដែលបានលើកឡើងខាងលើនេះថាមានកំរិតណានោះទេ ។

គំនិត ដែលជឿថាមានការរីករាលដាលនូវអំពើហិង្សាក្នុងគ្រួសារ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ហាក់បីដូចជាកើតឡើងចេញពី **ផ្នត់គំនិតមួយទៅលើជនជាតិដើមភាគតិច ដែលជារឿយៗត្រូវបានគេចាត់ទុកថាជាសហគមន៍ដែលមានបញ្ហា បណ្តាលមកពីភាពក្រីក្រ និងគ្មានការអភិវឌ្ឍន៍។** តាមពិតទៅ នៅក្នុងចំណោមជនជាតិដើមភាគតិច កម្រនឹងមានអំពើហិង្សាលើស្ត្រីណាស់ ហើយពួកគេមិនដែលធ្លាប់ដឹងពីការរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទលើ កុមារី និងកុមារទូទៅឡើយ ។ ទំនៀមទម្លាប់ជាច្បាប់មានប្រសិទ្ធភាព នៅក្នុងការហាមឃាត់មិនអោយមានអំពើទាំងនេះកើតឡើង ។

*"ឥលូវនេះ មានអំពើហិង្សាច្រើននៅក្នុងសហគមន៍ ដោយសារតែបុរសចង់បានអំណាច ចង់គ្រប់គ្រងលើអ្នកដទៃ ។ ពួកគេមានកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេ គ្រួសារក្រីក្រ ខ្វះការគោរពចំពោះស្ត្រី គ្មានសមត្ថភាពធ្វើការសម្រុះសម្រួល ហើយការប្រើប្រាស់ជាតិស្រវឹងមានការកើនឡើង ។*

*អំពើហិង្សាក្នុងគ្រួសារ ទៅជាគ្រប់គ្រងលែងបាន នៅពេលដែលមានអ្នកមកពីស្រុកផ្សេងមករៀបការជាមួយនឹងស្រីជនជាតិដើមភាគតិច ។ អ្នក ( មិនមែនជាជនជាតិដើម) ទាំងនោះមិនចេះអត់អោន ពួកគេមិនពឹងផ្អែកលើអាជ្ញាធរប្រពៃណី ។*

*ប្រព័ន្ធប្រពៃណី មានភាពពាក់ព័ន្ធយ៉ាងខ្លាំង នៅក្នុងការដោះស្រាយបញ្ហាទាំងនេះ ។ មានការពាក់ព័ន្ធពីចាស់ព្រឹទ្ធាចារ្យ ដំបូងពួកគេព្រមានអ្នកដែលបានប្រព្រឹត្តខុស បន្ទាប់មក ពួកគេព្រមានជាលើកទីពីរ និងលើកទីបី ហើយចុងក្រោយ ពួកគេកំណត់ថ្លៃដែលត្រូវបង់ ។ ប្រសិនបើប្តីប្រពន្ធអាចសម្រុះសម្រួលគ្នាបាន គេរៀបចំអោយ មានជាពិធីមួយដោយ បូជាសត្វមួយចំនួនហើយអ្នកដែលប្រព្រឹត្តខុសត្រូវសុំខមាលទោសនៅចំពោះមុខសហគមន៍ ហើយអ្នកទាំងពីរនាក់ អាចត្រូវរ៉ូវគ្នាវិញ ។ ប៉ុន្តែ ជាមួយនឹងជនស្រុកក្រៅដែលមានវប្បធម៌ផ្សេង គេមិនអាចធ្វើបែបនេះបានឡើយ ហើយសូម្បីតែការព្រមានក៏មិនមានប្រសិទ្ធិភាពដែរ ។ ដូច្នេះហើយបានជាបញ្ហាមិនអាចគ្រប់គ្រងបាន ។*

***មន្ត្រីមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី***

ទោះបីយ៉ាងណា បំលាស់ប្តូរមួយចំនួនដែលកើតមាននៅក្នុងសហគមន៍ គឺជាការចង្អុលបង្ហាញពីស្ថានភាពមួយ ដែលកំពុងធ្លាក់ចុះដុនដាបផ្នែកជីវិតសង្គម ការបាត់បង់តម្លៃរបស់ស្ត្រី និងជម្លោះដែលពាក់ព័ន្ធជាមួយយេនឌ័រ ។ ហេតុនេះហើយ អំពើហិង្សាលើស្ត្រី កាន់តែមានបញ្ហាច្រើនជាងមុន ។ មន្ត្រីអភិវឌ្ឍន៍ជាច្រើននាក់ លើកឡើងថា "ការអប់រំ" គឺជាសកម្មភាពចម្បងជាងគេ ដែលត្រូវផ្តល់ទៅអោយសហគមន៍ ប៉ុន្តែនៅមានការខ្វះខាត លើការវិភាគ និងការយល់ដឹង អំពីភាពបត់បែនរបស់យេនឌ័រនៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងអំពីរបៀប ដែលការផ្លាស់ប្តូរទាំងនេះអាចមានឥទ្ធិពលផ្សេងគ្នាលើស្ត្រី និងបុរស ។

## សង្ខេប

- អ្នកធ្វើការងារអភិវឌ្ឍន៍ជាច្រើន ចាត់ទុកអំពើហិង្សាលើស្ត្រី នៅតាមសហគមន៍ជនជាតិដើមភាគតិច ថាជាលទ្ធផលធម្មជាតិ នៃភាពក្រីក្រ និង កង្វះខាតការអភិវឌ្ឍន៍
- មានអ្នកធ្វើការងារអភិវឌ្ឍន៍តែមួយចំនួនតូចប៉ុណ្ណោះ ដែលភ្ជាប់ទំនាក់ទំនងនៃការកើនឡើងនូវជម្លោះទាំងនេះ ជាមួយនឹងការផ្លាស់ប្តូរទំនាក់ទំនងសង្គម និងយេនឌ័រ ដែលកំពុងកើតមាន
- ដូច្នេះហើយ បានជាមានការខ្វះខាតយុទ្ធសាស្ត្រជាក់លាក់ ដើម្បីដោះស្រាយកំណើនអំពើហិង្សាទាំងនេះ ។

### កង្វះខាតសេវាកម្ម

ស្ត្រីជនជាតិដើមភាគតិច កំពុងរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារតែកង្វះខាតសេវាជាមូលដ្ឋាននានា ដូចជា ការអប់រំ មូលដ្ឋានសុខាភិបាលសមស្រប ការដឹកជញ្ជូន និង សេវាសង្គមដទៃទៀត ។ ខណៈពេលដែលសាលារៀនត្រូវបានសាងសង់រួចរាល់ មានការខ្វះខាតធនធានមនុស្ស ដោយសារតែជារឿយៗ គ្រូមិនមកធ្វើការ ឬ ពួកគេមកមិនទៀងទាត់ ហើយមិនធានាអោយមានការបង្កើតកម្មវិធីអប់រំដែលត្រឹមត្រូវ ។ ស្ថានភាពនេះហាក់បីដូចជាកើតមានច្រើនកន្លែង ដូច្នេះហើយបានជាយើងទទួលបានចម្លើយដូចៗគ្នា ចំពោះសំនួររបស់យើង ដែលសួរអំពីការអប់រំ ។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួន កំពុងអនុវត្តកម្មវិធីអប់រំ ដោយប្រើកម្មវិធីសិក្សាដែលមានពីរភាសា ប៉ុន្តែសកម្មភាពរបស់ពួកគេនៅមិនទាន់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងអស់នោះឡើយ **ហើយតាមភូមិជាច្រើននៅមានការខ្វះខាតសេវាអប់រំជាមូលដ្ឋាន។**

នៅតាមភូមិមួយចំនួន មានថ្នាក់អក្ខរកម្ម ដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែ មិនមានកម្មវិធី សាធារណៈ ដែលអាចជឿទុកចិត្តបាន ដើម្បីគាំទ្រដល់អ្នកដែលចង់រៀនអាន និងសរសេរភាសាខ្មែរ ។ នេះគឺជាកត្តាសំខាន់ណាស់ ជាពិសេសសម្រាប់ស្ត្រីដែលមានឱកាសចូលរួមក្នុងសង្គមតិចតួចនៅក្រៅភូមិរបស់ពួកគេ ដូច្នេះពួកគេមានឱកាសតិចតួចក្នុងការរៀនភាសាខ្មែរ ។

ជារឿយៗសេវាសុខភាពមានតម្លៃថ្លៃពេក ឬ មិនមានប្រសិទ្ធភាពដោយសារតែតម្លៃ

> *យើងមានសាលារៀន ប៉ុន្តែ គ្រូអត់មក ឬ មកនៅម៉ោង ៩ តែប៉ុន្មានដងប៉ុណ្ណោះ ដូច្នេះក្មេងៗត្រលប់ទៅផ្ទះវិញ ឬ ទុកចោលដោយគ្មានការមើលការខុសត្រូវ ។*
>
> ***ស្ត្រីជនជាតិក្រឹង រស់នៅក្នុងស្រុកអូជុំ ខេត្តរតនៈគិរី***

> *យើងចង់បានមណ្ឌលសុខភាពល្អជាងពេលនេះ ព្រោះឥលូវនេះ ប្រសិនអ្នកគ្មានលុយ ពួកគេមិនព្យាបាលអ្នកឡើយ ហើយពួកគេនិយាយតែភាសាឡាវប៉ុណ្ណោះ ។ ពេទ្យ ភាគច្រើនជាបុរស ដូច្នេះវាជាការពិបាកសម្រាប់យើង ។*
>
> ***ស្ត្រីជនជាតិទំពួន នៅវឿនសៃ ខេត្តរតនៈគិរី***

ឬ ដោយសារមិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ស្ត្រីជនជាតិដើមភាគតិចបាន។

ការផ្តល់សេវាជាមូលដ្ឋានដទៃទៀត ដូចជា ទឹកស្អាត អនាម័យ ការថែទាំកុមារ ការដឹកជញ្ជូន នៅតែមានមិនគ្រប់គ្រាន់។ នេះបង្កើតអោយមានស្ថានភាពមួយ ដែលដែនដីរបស់ជនជាតិដើមភាគតិច ត្រូវគេទាញយកប្រយោជន៍ពីធនធានធម្មជាតិ គ្មានការអភិវឌ្ឍន៍ផ្នែកសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់អត្ថប្រយោជន៍ទៅអោយសហគមន៍។

*យើងមានបញ្ហាជាមួយនឹងការអភិវឌ្ឍន៍នៅទីនេះ។ នៅទីនេះ ពុំមានការអភិវឌ្ឍន៍ឡើយ។ តើផ្លូវល្អសម្រាប់ប្រជាពលរដ្ឋនៅឯណា មិនមែនសម្រាប់ក្រុមហ៊ុន ឬ អ្នកទិញនោះទេ? តើឯណាទៅទីផ្សារ ដែលអាចទិញ និង លក់ផលិតផលរបស់ជនជាតិដើមភាគតិចបាន? ឯណាទៅមធ្យោបាយដឹកជញ្ជូនដែលមានតម្លៃថោកសម្រាប់ដឹក ផលិតផលពីតំបន់ដាច់ស្រយាល? អ្នកណាជាអ្នកត្រួតពិនិត្យតម្លៃ និង បញ្ឈប់ការបំប៉ោង ឬ ការបន្ថោកតម្លៃ? ឯណាទៅសេវាផ្សព្វផ្សាយ ការឧបត្ថម្ភទុន និងការគាំទ្រសម្រាប់អ្នកផលិតតូចតាច? ឯណាទៅរោងចក្រសម្រាប់ កែច្នៃវត្ថុធាតុដើមរបស់យើង?*
*ផ្លែខ្នុរ ជ្រុះដោយមិនបានលក់យកកម្រៃ ប្រជាជនមិនដឹងពីរបៀបឆ្លាស់ដំណាំដាំដុះរបស់ពួកគេ ដូចជា សណ្តែកសៀង ឬ ដំឡូងមី អោយទទួលបានផលល្អបំផុត យើងគ្មានផ្សារសម្រាប់លក់ គ្មានមធ្យោបាយដឹកជញ្ជូនសម្រាប់ដឹកផលិតផល តម្លៃធ្លាក់ចុះដោយសារតែកង្វះខាតមធ្យោបាយដឹកជញ្ជូន ដែលមានតម្លៃថោក ការបំប៉ោង និងបន្ថោកតម្លៃមានពោរពាស!*
*កាលពីមុន ប្រជាជនមានព្រៃឈើ ត្រី សាច់ មនុស្សតិច ម្ហូបអាហារគ្រប់គ្រាន់ គ្មានបញ្ហាធំៗ មនុស្សកាន់តែច្រើន ដោយសារគ្មានការត្រួតពិនិត្យលំហូរប្រជាជនចំណាកស្រុក ធនធានទឹក ត្រី បរបាញ់សត្វ ត្រូវបានគេទាញយក ប្រយោជន៍ហួសកម្រិត ហើយមានអាជីវកម្មថ្មីៗ ដូចជា ការរុករករ៉ែ ជាដើម!*
*ដូច្នេះ តើប្រជាជនអាចរស់ដោយរបៀបណា? ជាការធម្មតា ដែលប្រជាជនមានបញ្ហាច្រើន ហើយស្ត្រីក៏មានបញ្ហាច្រើនដែរ!*

***សកម្មជនជនជាតិដើមភាគតិច នៅបានលុង ខេត្តរតនៈគីរី***

## សង្ខេប

- សហគមន៍ជនជាតិដើមភាគតិច រងផលប៉ះពាល់ ដោយសារការផ្លាស់ប្តូរឆាប់រហ័សនៃសេដ្ឋកិច្ច វប្បធម៌ និង សង្គម
- ទំនើបកម្ម ហូរចូលមកក្នុងសហគមន៍ ដោយផ្តោតខ្លាំងលើគុណតម្លៃដែលពាក់ព័ន្ធជាមួយលុយកាក់ បង្ខំអោយសហគមន៍ ផ្លាស់ពីការធ្វើកសិកម្មប្រកបដោយនិរន្តរភាព មកជាការផលិតទៅតាមតម្រូវការលើទីផ្សារវិញ
- ខ្វះខាតការផ្តោតលើសេវាសង្គម កំពុងប៉ះពាល់ជាអវិជ្ជមានមកលើស្ត្រី និង ធ្វើអោយអន្តរាយដល់ ភាពជឿនលឿន និងសុខុមាលភាពរបស់ពួកគេ។

# ស្ត្រីនៅក្នុងនយោបាយៈ កម្លាំងចលករដែលធ្វើឱ្យមានការផ្លាស់ប្តូរ

## សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីៈ ជាការធានាអោយមានអភិបាលកិច្ចល្អមែនទេ?

ស្ត្រីជនជាតិដើមភាគតិច ដែលជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ ស្រដៀងគ្នាជាមួយនឹងស្ត្រីដទៃទៀត នៅក្នុងសហគមន៍ដែរ បានបញ្ចេញនូវគំនិតថា អាជ្ញាធរមូលដ្ឋានជាស្ត្រីបង្ហាញការប្តេជ្ញាចិត្ត និងសុច្ចរិតភាពខ្ពស់។ ស្ត្រី មួយចំនួនបានលើកឡើងថា ស្ត្រីអាចតទល់ជាមួយនឹងអំពើពុករលួយ អាចការពារផលប្រយោជន៍របស់សហគមន៍ និង អាចការពារបរិស្ថានបានល្អជាងបុរស ។

*ស្ត្រីមិនងាយប្រព្រឹត្តអំពើពុករលួយ មានប្រសិទ្ធភាពជាង និងមានការប្តេជ្ញាចិត្តខ្ពស់ជាង ។ ស្ត្រីក្នុងក្រុមប្រឹក្សាឃុំ គឺ ជាអ្នកដែលខំប្រឹងប្រែងធ្វើការងារខ្លាំង និងអាចជឿទុកចិត្តបាន ។*

*សមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្តរតនៈគិរី*

*នៅពេលមានស្ត្រីកាន់តែច្រើននាក់ ធ្វើជាអាជ្ញាធរមូលដ្ឋាន វានឹងរឹតតែប្រសើរ សម្រាប់ការការពារធនធានធម្មជាតិ ។ ស្ត្រីមានការប្តេជ្ញាចិត្តខ្ពស់ មិនងាយបោកប្រាស់ និងអាចប្រឆាំងនឹងការលក់ដីខ្លាំងក្លាជាង ។ នៅពេលដែលខ្ញុំបំពេញការងារ ខ្ញុំទៅវាស់វែង និងផ្ទៀងផ្ទាត់ ដើម្បីអោយដឹងថាការលក់នេះស្របច្បាប់ ឬអត់ ។ ប៉ុន្តែខ្ញុំខ្លាចមាន ការលក់ដីមិនស្របច្បាប់កើតឡើង ដោយសារការសូកប៉ាន់ ហើយការងារខ្លះគេយកទៅចុះហត្ថលេខានៅផ្ទះ! ជាមួយខ្ញុំ គេមិនអាចលក់ដី ដោយការសូកប៉ាន់បានងាយស្រួលនោះទេ ។ ពួកគេមិនអាចមកជួបខ្ញុំពេលយប់ព្រលប់ ហើយអោយខ្ញុំផឹកស្រវឹង ឬ ហៅខ្ញុំទៅក្រុងផឹកក្នុងខារ៉ាអូខេនោះទេ ។ ស្ត្រីប្រឆាំងនឹងអំពើពុករលួយ នេះគឺជាការពិត ។*

*សមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្តមណ្ឌលគិរី*

នេះឆ្លុះបញ្ចាំងពីគំនិត ដែលលើកឡើងដោយស្ត្រីក្នុងសហគមន៍ អំពីស្ត្រីផ្តល់តម្លៃដល់ការការពារធនធាន និងជីវភាពរបស់ប្រជាពលរដ្ឋ និងអំពីបុរស ដែលងាយលង់នឹងផលប្រយោជន៍ពីសេដ្ឋកិច្ចទីផ្សារ ។ កិច្ចការអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ និងស្ពាន គឺជាការងាររបស់បុរស ហើយសុខុមាលភាព សេវាសង្គម ការអប់រំ សុខភាព ការថែទាំកុមារ គឺជាការងាររបស់ស្ត្រី ។

សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីខ្លះ អះអាងថាខ្លួន មានការប្តេជ្ញាចិត្ត និង ឆន្ទៈខ្ពស់ ក្នុងការបម្រើសហគមន៍ និង នៅក្នុងការស្វែងរកដំណោះស្រាយ ចំពោះបញ្ហាដែលប្រជាជនមាន ។ ពួកគេផ្តោតសំខាន់លើទំនាក់ទំនងរវាងសមាជិកក្រុម ប្រឹក្សាឃុំជាស្ត្រី និងសហគមន៍ម្ចាស់ឆ្នោត ដែលបង្កើតឡើងដោយការងារពីមុនរបស់ពួកគេ ជាសកម្មជនសង្គម និងជាអ្នកចងក្រងសហគមន៍ ។

*ស្ត្រី ដែលធ្វើការងារជាមួយក្រុមប្រឹក្សាឃុំ មានទឹកចិត្តរឹងមាំ គាំទ្រដល់សហគមន៍ ។ ជាធម្មតា ពួកគេធ្លាប់ធ្វើការងារក្នុង សហគមន៍ពីមុនមក នៅក្នុងភូមិរបស់ពួកគេ ។ ពួកគេមាន ការព្រួយបារម្ភអំពីបញ្ហារបស់ស្ត្រី ពួកគេចង់ដោះស្រាយបញ្ហាទាំងនោះ ។*

*សមាជិកក្រុមប្រឹក្សាឃុំ ក្នុងខេត្តរតនៈគិរី*

តាមសំដីរបស់អ្នកដែលមានការពាក់ព័ន្ធខ្លះ សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ផ្តោតការយកចិត្តទុកដាក់ច្រើនជាងលើបញ្ហាសង្គម ដែលកើតមានឡើងនៅក្នុងសហគមន៍ និងផ្តល់អត្ថប្រយោជន៍ ទៅអោយអ្នកភូមិមានប្រសិទ្ធភាពជាង ។ ដោយបែងចែកជាផ្នែកយេនឌ័រ កិច្ចការសង្គមសំខាន់ៗ បង្កើតនូវលក្ខខណ្ឌសម្រាប់ការផ្ទេរការទទួលខុសត្រូវអោយបានច្រើន នៅគ្រប់កម្រិតទាំងអស់ក្នុងសង្គមពីបុរស រួមទាំងអ្នកបង្កើតគោលនយោបាយ ។

*ស្ត្រីនៅកៀកនឹងសហគមន៍ជាង មានការព្រួយបារម្ភជាងបុរស និងមិនសូវធ្វើអ្វីដែលខុសឆ្គង ជាទូទៅពួកគេធ្វើការងារច្រើន ជាង និងល្អជាងបុរស ។ នៅពេលដែលមានស្ត្រីម្នាក់ ស្ត្រីដទៃ ទៀតនៅក្នុងសហគមន៍កាន់តែហ៊ាននិយាយ ពួកគេចាប់ផ្តើម និយាយពីបញ្ហាប្រាប់អ្នកដឹកនាំជាស្ត្រីរូបនេះ និងចាប់ផ្តើមអោយគាត់ដោះស្រាយបញ្ហាទាំងនេះ និង ឆ្លើយតបទៅនឹងតម្រូវ ការរបស់ពួកគេ ។ ដូចជា ការមានទឹកស្អាតប្រើប្រាស់ប្រសិន បើមានតែបុរសជាអ្នកទទួលខុសត្រូវ ពួកគេមិនខ្វល់ ពួកគេជិះម៉ូតូទៅងូតទឹកទន្លេ ប៉ុន្តែសម្រាប់ស្ត្រីទឹកស្អាតគឺសំខាន់ខ្លាំងណាស់ ពួកគេសំអាតឧបករណ៍ប្រើប្រាស់ ងូតទឹកអោយកូន បោកសំលៀកបំពាក់ ដងទឹកទុកផឹក ហើយពួកគេដឹងពីកម្រិតអនាម័យអាស្រ័យទៅតាមប្រភពទឹកស្អាត ។ ស្ត្រីម្នាក់នៅក្នុងក្រុមប្រឹក្សាឃុំតស៊ូមតិ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ!*

*មន្ទីរកិច្ចការនារី ខេត្តរតនៈគិរី*

## ការផ្លាស់ប្តូរនយោបាយ

នៅក្នុងខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី ពុំមានស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំណាម្នាក់មានតួនាទី ដឹកនាំការងារនៅក្នុងជួរអាជ្ញាធរមូលដ្ឋានឡើយ ខណៈពេលដែលនៅក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង យើងជួបជាមួយនឹង **ប្រធាន ឬអនុប្រធានក្រុមប្រឹក្សាឃុំជាស្ត្រី** ដែលមានការទទួលខុសត្រូវ និងអំណាចពិតប្រាកដ ។

បើតាមការលើកឡើងរបស់ស្ត្រី នៅក្នុងខេត្តស្ទឹងត្រែង និងក្រចេះ សហគមន៍ទាំងពីរ ដែលបានលើកឡើងពីឧទាហរណ៍ ស្តីពីអភិបាលកិច្ចល្អនៅថ្នាក់ខេត្ត យើងបានកំណត់នូវលក្ខណៈនៃរបៀបធ្វើនយោបាយរបស់ស្ត្រីដូចខាងក្រោមនេះ

- មានការទទួលខុសត្រូវចំពោះសហគមន៍
- ភាពជាអ្នកដឹកនាំរួម ផ្អែកទៅតាមការពិគ្រោះយោបល់ និងការពិភាក្សា
- តម្លាភាព
- ផ្តោតលើបញ្ហា ការស្នើសុំ និងសេចក្តីត្រូវការរបស់សហគមន៍ ព្រមទាំងមានការប្តេជ្ញាចិត្តនៅក្នុងការដោះស្រាយបញ្ហារបស់ប្រជាជន
- ផ្តោតលើបញ្ហារបស់ស្ត្រី និងមានការប្តេជ្ញាចិត្តយ៉ាងសកម្ម ដើម្បីបង្កើនស្ថានភាពរបស់ស្ត្រី[៣]

ការបោះឆ្នោត ជ្រើសរើសស្ត្រីឱ្យធ្វើជាមេឃុំ មិនមែនជាព្រឹត្តិការណ៍ ដែលកើតឡើងដោយឯកឯងនោះទេ ប៉ុន្តែជា**គំនិតផ្តួចផ្តើមរួមរបស់ស្ត្រី** ដែលធ្វើឱ្យមានស្ត្រីជាច្រើននាក់បានចូលរួមនៅក្នុងសកម្មភាពរបស់សហគមន៍ និងក្នុងចំណោមអាជ្ញាធរមូលដ្ឋាននៅច្រើនលំដាប់ថ្នាក់ ដូចជាមេភូមិ មេភូមិរង មេឃុំរង និងសមាជិកឃុំ ។ ពុំមានជំហានណាមួយក្នុងចំណោមជំហានទាំងនេះងាយស្រួលនោះទេ ។

*"នៅទីនេះ ស្ត្រីគឺជាមេភូមិ មេឃុំ និងមេឃុំរង ។ សហគមន៍គាំទ្រពួកគេ ព្រោះពួកគេមានសមត្ថភាព ព្រោះពួកគេ សុទ្ធតែជាអ្នកឧស្សាហ៍ធ្វើការងារ ព្រោះពួកគេសាមញ្ញ ហើយតែងចេះដាក់ខ្លួនព្រមទាំងស្នើអោយអ្នកភូមិកែតម្រូវពួកគេ ប្រសិនបើពួកគេធ្វើអ្វីខុស ។ ស្ត្រីធ្វើជាអាជ្ញាធរនៅក្បែរជាងជាមួយនឹងប្រជាពលរដ្ឋ មានការចូលរួមជាង ស្តាប់ច្រើនជាង និងនៅខាងប្រជាពលរដ្ឋជាង ។ ដំបូង ពួកគេមានគណនេយ្យភាព ចំពោះសហគមន៍! ហើយពួកគេស្តាប់បញ្ហាដែល អ្នកភូមិលើកឡើង និងអាចពាំនាំបញ្ហានេះទៅថ្នាក់លើ ។ យើងមិនមែនធ្វើការងារនេះដើម្បីលុយឡើយ ។ មេឃុំទទួលបានប្រាក់ខែ ២៥ ដុល្លាក្នុងមួយខែ សម្រាប់ការងារជាច្រើនដែលពួកគេធ្វើនៅផ្ទះ ពេលឈប់សំរាកក៏ដោយមានមនុស្សមករកពួកគេជារៀងរាល់ថ្ងៃ ទាំងនៅពេលយប់ ។ ខ្ញុំត្រូវខិតខំធ្វើការ!ខ្ញុំពេញចិត្តនឹងធ្វើការងារនេះ ។"*

***មេឃុំ ក្នុងខេត្តក្រចេះ***

សហគមន៍ទាំងនេះនៅក្នុង ខេត្តស្ទឹងត្រែង និងក្រចេះ គឺជាសហគមន៍ជនជាតិខ្មែរ ហើយច្បាស់ណាស់នេះគឺ ជាកត្តាសម្រួលមួយដោយសារតែស្ថានភាពនៅក្នុងឃុំរបស់ពួកគេមិនអាចយកទៅប្រៀបធៀបជាមួយស្ថានភាពបញ្ហាដែលកំពុងកើតមាននៅក្នុងសង្គមរបស់ជនជាតិដើមភាគតិច ។ បើទោះបីជាមានភាពខុសប្លែកគ្នាទាំងនេះក៏ដោយ យើងយល់ថាបទពិសោធនរបស់ពួកគេមានភាពពាក់ព័ន្ធគ្នា និងអាចជាប្រភពនៃការលើកទឹកចិត្តសម្រាប់សហគមន៍ដទៃទៀត ។

៣. ការរកឃើញនេះស៊ីគ្នាទៅនឹងការសិក្សាប្រៀបធៀបមួយនៅតំបន់អាស៊ីប៉ាស៊ីហ្វិច Jean Drage for UNESCAP (២០០១)

*ដើម្បីលើកទឹកចិត្ត អោយស្ត្រីក្លាយជាអ្នកតំណាង និងអាចចូលរួមនៅក្នុងនយោបាយបាន អ្នកគួរផ្តល់ឱកាសអោយស្ត្រីបានធ្វើការ ស្ត្រីត្រូវចូលរួមនៅក្នុងក្រុមសន្សំ នៅក្នុងការងារ ពួកគេត្រូវតែមានឱកាសក្នុងការងារ ព្រោះពួកគេពូកែធ្វើការងារជាងបុរស! ត្រូវបង្កើតបណ្តាញ ហើយស្ត្រីត្រូវមានបទពិសោធន៍រួមគ្នានៅក្នុងសកម្មភាពនានា នៅថ្នាក់ភូមិ ពួកគេត្រូវមានឱកាសនិយាយ ធ្វើការប្រាស្រ័យទាក់ទង និងធ្វើការរួមគ្នា ។ នៅទីនេះ ស្ត្រីធ្វើការជាក្រុមតាមភូមិនីមួយៗ នៅក្នុងវិស័យអភិវឌ្ឍន៍ភូមិ យើងជ្រើសរើសស្ត្រីអោយធ្វើការងារ ។ នេះគឺជារបៀប ដែលយើង កសាងការចូលរួមរបស់ស្ត្រី និងរបៀបដែលយើងទទួលបានលទ្ធផលទាំងនេះ ។*

*ក្រុមស្ត្រី ក្នុងខេត្តស្ទឹងត្រែង*

ស្ត្រីចាត់ទុកតួនាទីរបស់ពួកគេថាជាអ្នកផ្តល់សេវាទៅឱ្យសហគមន៍ ជាជាងជាអ្នកដែលដឹកនាំអំណាច ។ ទំនួលខុសត្រូវចំពោះសហគមន៍ គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការអនុវត្តការងាររបស់ពួកគេ ។ ដោយឈរនៅខាងប្រជាពលរដ្ឋ និងស្តាប់អំពីអ្វីដែលពួកគេត្រូវការ ស្ត្រីមានសមត្ថភាពធ្វើការងារជាមួយប្រជាពលរដ្ឋ ឆ្លើយតបចំពោះបញ្ហារបស់ពួកគេ និងស្វែងរកដំណោះស្រាយដើម្បីសុខុមាលភាពរបស់សហគមន៍ ។

ដូចគ្នានឹងស្ត្រីជនជាតិដើមភាគតិចដែរ ការប្រឆាំងនឹងអំពើពុករលួយត្រូវបានកំណត់ថា ជាលក្ខណៈមួយរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ។ ដោយមានការគាំទ្រពីសហគមន៍និងធ្វើការសហការគ្នាយ៉ាងជិតស្និទជាមួយនឹងអ្នកភូមិ គឺដើម្បីឱ្យស្ត្រីទាំងនេះកាន់តែអាចធានាបាននូវការប្រឆាំងនឹង សំពាធនៃអំពើពុករលួយ និងសំពាធនានា ដែលមានគោលបំណងធ្វើឱ្យទម្រង់អភិបាលកិច្ច ងាកចេញពីគោលបំណង និងកាតព្វកិច្ចចម្បងរបស់វា ។

បញ្ហាការរើសអើងប្រឆាំងនឹងស្ត្រី និងភាពចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ គឺជាចំនុចស្នូលរបស់វិធីនេះ ។ យើងមានការចាប់អារម្មណ៏យ៉ាងខ្លាំង ដែលបានដឹងពីស្ត្រីទាំងនេះ អំពីដំណើរការដែលអាចឱ្យពួកគេទទួលបាននូវការជឿទុកចិត្តពីសហគមន៍ និងអំណាច ដើម្បីធ្វើជាតំណាងសហគមន៍ ។ **វាគឺជាដំណើរការផ្តល់អំណាចទៅឱ្យស្ត្រី ដែលអាចសម្រេចបានដោយការប្តេជ្ញាចិត្តឋិតថេរក្នុងរយៈពេលវែង ដែលចុងក្រោយបាន ពង្រឹងសហគមន៍ទាំងមូល គឺទាំងស្ត្រី ទាំងបុរស។**

ដំណើរការ ដែលស្ត្រីទាំងនេះរៀបរាប់ឡើងនេះ គឺផ្អែកលើភាពចាំបាច់ ដើម្បីដោះស្រាយភាពរើសអើង និងទទួលបាននូវសេចក្តីថ្លៃថ្នូរឡើងវិញ ។ ដំបូង ស្ត្រីត្រូវទទួលបាននូវតម្លៃផ្ទាល់ខ្លួន និងមោទនភាពឡើងវិញ និងដឹង “**ថាតើស្ត្រីសំខាន់ប៉ុណ្ណា**” ដើម្បីលុបបំបាត់គំនិតចេញដែលថា ស្ត្រីមិនសូវមានសមត្ថភាព មិនសូវមានការអប់រំ មិនសូវពូកែ ...។ ទីពីរ ពួកគេទាំងអស់គ្នាត្រូវបង្ហាញ និង ពិភាក្សា រួមគ្នាអំពីមូលហេតុ ដែលធ្វើឱ្យមានការរើសអើង ដែលនេះជាដំណើរការមួយដែលជួយពួកគេឱ្យលែងគិតថាខ្លួនឯងជាអ្នកមានកំហុសទៀត ។

ដូចដែលស្ត្រីបានលើកឡើង បង្កើនការយល់ដឹងមិនមែនមានន័យថាជាយុទ្ធសាស្ត្រប្រឈមមុខគ្នានោះទេ ផ្ទុយទៅវិញវាជួយស្វែងរកយុទ្ធសាស្ត្រ ដែលយុត្តិធម៌ និងមានប្រសិទ្ធភាព។ ដំណើរផ្លូវនេះពោរពេញទៅដោយឧបសគ្គ ព្រោះការចូលរួមរបស់ស្ត្រីក្នុងនយោបាយ កាន់តួនាទីជាអ្នកធ្វើការសម្រេចចិត្ត គឺនៅតែត្រូវបានគេចាត់ទុកថា ជាករណីលើកលែង ហើយនៅក្នុងករណីជាច្រើនមានទាំងការប្រឆាំងគំនិតនេះទៅវិញ។

*សកម្មភាពដំបូង គួរផ្តោតលើស្ត្រី ថាតើស្ត្រីមានសារៈសំខាន់យ៉ាងណា! ដើម្បីអោយពួកគេហ៊ាននិយាយ មានទំនុកចិត្ត និងចូលរួម។ ស្ត្រីមានបញ្ហាជាច្រើននៅក្នុងភូមិនៅទីនេះ។ ពួកគេមិនចូល រួមនៅក្នុងជីវិតសាធារណៈ និងនយោបាយនោះទេ។ ប្រពៃណីនិយាយថាស្ត្រីមិនគួរចូលរួមឡើយ។ ប៉ុន្តែឥលូវនេះ យើងចូលរួម ស្ត្រីក៏អាចកសាងជាតិបានដែរ។ ស្ត្រីអាចរៀន និងចង់ឈានជើងចេញពីប្រពៃណីមួយចំនួន ពួកគេចង់ធ្វើការងារដូចបុរស និងជាមួយបុរស! តើយើងចាកចេញដោយរបៀបណា? យើងព្យាយាមកសាងសមត្ថភាពរបស់យើងនៅក្នុងការងារ យើងបញ្ចុះបញ្ចូលពួកគេ យើងអត់ធ្មត់ច្រើន យើងធ្វើការងារច្រើននៅក្នុងសហគមន៍ នៅក្នុងឃុំ និងនៅក្នុងផ្ទះផងដែរ។ មានការងារជាច្រើន ជួនកាលច្រើនពេក! យើងកសាងសមត្ថភាព ហើយយើងកសាងសាមគ្គីភាព រវាងគ្នានិងគ្នា។ យើងបណ្តុះបណ្តាលខ្លួនយើង ដើម្បីអោយយើងអាចបញ្ចុះបញ្ចូលស្វាមី អោយមានការទទួលខុសត្រូវបន្ថែមទៀត។*

***ស្ត្រី ក្នុងខេត្តក្រចេះ***

*ខ្ញុំដឹងថា នៅតាមក្រុមប្រឹក្សាឃុំមួយចំនួន សមាជិកជាស្ត្រីជាអ្នកដាំទឹក និងទទួលភ្ញៀវ ឬរៀបចំម្ហូបសម្រាប់ការប្រជុំ។ នេះគឺមិនល្អឡើយ វាមិនអាចមានដំណើរការបានឡើយ!!! នៅទីនេះមិនមែនដូច្នេះឡើយ ខ្ញុំមានអំណាចសម្រាប់អ្វីៗគ្រប់បែបយ៉ាង ជាអំណាចពិតប្រាកដ។ នេះគឺជាអណត្តិទី ២ របស់ខ្ញុំ។ ខ្ញុំកាន់តំណែងនេះតាំងពីឆ្នាំ ២០០២ មក ហើយទទួលបន្ទុកកិច្ចការនារី តាំងពីឆ្នាំ ១៩៨២ មក។ ស្ត្រីបានក្លាយជាបុគ្គលយ៉ាងសំខាន់នៅក្នុងឃុំ ព្រោះយើងបង្កើតក្រុមស្ត្រីនៅតាមភូមិនីមួយៗ ហើយបន្ទាប់មកជាបណ្តាញស្ត្រី ហេតុដូច្នេះហើយសកម្មភាពរបស់ស្ត្រីមានការដុះដាលឡើង។ ខ្ញុំតែងតែព្យាយាមលើកទឹកចិត្តស្ត្រី និងផ្តល់ការងារ និងសកម្មភាពអោយពួកគេធ្វើ។ ដើម្បីអោយស្ត្រីមានតួនាទី នៅថ្នាក់សហគមន៍ ពួកគេត្រូវទទួលបានការលើកទឹកចិត្តអោយធ្វើសកម្មភាព បើមិនដូច្នេះទេពួកគេនៅជាប់តែនៅ ក្នុងផ្ទះ ក្នុងចង្ក្រានតែប៉ុណ្ណោះ។ ពីដំបូង ខ្ញុំធ្វើតែអ្វីដែលថ្នាក់លើអោយខ្ញុំធ្វើតែប៉ុណ្ណោះ ប៉ុន្តែឥលូវនេះ ខ្ញុំមានគំនិត និងការផ្តួចផ្តើមដោយខ្លួនឯង។*

***មេឃុំ នៅក្នុងខេត្តស្ទឹងត្រែង***

## ការធ្វើឱ្យកាន់តែប្រសើរនូវស្ថានភាពរបស់ស្ត្រី៖ ឧទាហរណ៍ ពីការប្រឆាំងនឹងអំពើហិង្សាលើស្ត្រី

ឥទ្ធិពលមួយដែលនាំឱ្យមានចំនួនស្ត្រីកើនឡើង នៅក្នុងជួរអាជ្ញាធរមូលដ្ឋាន និងបង្កើនឋានៈរបស់ពួកគេគឺ ជាបញ្ហារបស់ស្ត្រីដូចជា អំពើហិង្សាលើពួកគេជាដើម ទទួលបាននូវការយកចិត្តទុកដាក់ជាសំខាន់ និងមានការដោះស្រាយយ៉ាងហ្មត់ចត់។ មិនត្រឹមតែមានការចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហា ដូចជាលែងឱ្យមាននិទណ្ឌភាពសម្រាប់អ្នកប្រព្រឹត្តខុសទៀតប៉ុណ្ណោះទេ វត្តមានរបស់ស្ត្រីនៅគ្រប់កម្រិតតួនាទី ដែលមានការទទួលខុសត្រូវទាំងអស់ គឺដើម្បីធ្វើឱ្យកាន់តែប្រសើរនូវស្ថានភាពរបស់ស្ត្រី សម្របសម្រួលឱ្យស្ត្រីមានសកម្មភាព និងរួមចំណែកកាត់បន្ថយភាពអត់ឱនទោស ចំពោះសកម្មភាពទាំងនេះ។ **បន្តិចម្តងៗតួនាទីបុរស ស្ត្រីចាប់ផ្តើមជាថ្មី ដែលជំនួសពីវប្បធម៌ត្រួតត្រា និងហិង្សា ដោយវប្បធម៌សាមគ្គីភាព ភាពស្មើគ្នា និង ការគោរពគ្នាទៅវិញទៅមកវិញ។**

*"ឥលូវនេះ អំពើហិង្សាក្នុងគ្រួសារមិនមែនជាបញ្ហាធំឡើយ ។ កាលពីមុន មានបុរសយ៉ាងហោចណាស់ ៥០% ដែលផឹកស្រវឹង និង បង្កជម្លោះជាមួយប្រពន្ធ ប៉ុន្តែឥលូវនេះ នៅមានគ្រួសារតែមួយចំនួនតូចប៉ុណ្ណោះ ។ អ្នកដែលចចេសរឹងរូសខ្លាំង នៅតែផឹក ប៉ុន្តែមានតិចតួចប៉ុណ្ណោះ តែ១ ឬ២គ្រួសារទេ ។ យើងអប់រំពួកគេនៅក្នុងការប្រជុំ ហើយជួនកាល យើងទៅជួបគ្រួសារដោយផ្ទាល់នៅផ្ទះរបស់ពួកគេ ហើយនិយាយជាមួយពួកគេ ។ ប៉ុន្តែនៅពេលដែលមានអំពើហិង្សាក្នុងគ្រួសារកើតមានឡើង យើងរាយការណ៍ទៅនគរបាលភ្លាមហើយចាត់វិធានការភ្លាមៗដែរ ។ យើងមិនបណ្តោយឱ្យ អំពើបែបនេះចប់ទៅដោយគ្មានការដាក់ទោសនោះទេ ហើយយើងធ្វើសកម្មភាពលឿន ។ នេះគឺជាចំនុចសំខាន់ខ្លាំងណាស់ ចាត់វិធានការ និងអនុវត្តវិធានការភ្លាម ។ ទាំងនេះបានធ្វើឱ្យស្ថានភាពមានការផ្លាស់ប្តូរ ។ ក្រៅពីនេះនៅមានការអប់រំ ឧទាហរណ៍ៈ គ្រួសាររបស់យើងព្យាយាមធ្វើជាគំរូល្អឱ្យអ្នកដទៃទៀតធ្វើតាម ព្រោះយើងមិនមានជម្លោះខ្លាំងក្លា ហើយយើងអាចដោះស្រាយបញ្ហាប្តីប្រពន្ធដោយសន្តិវិធីបាន ។ ប្តីរបស់ខ្ញុំផ្តល់ការគាំទ្រយ៉ាងច្រើន នៅពេលដែលខ្ញុំមានការងារច្រើនដែលត្រូវធ្វើគាត់ធ្វើការងារនៅផ្ទះ ។ នៅទីនេះ បុរសយល់អំពីយេនឌ័រ ពួកគេលែងនិយាយមិនល្អអំពីបុរស ដែលជួយស្ត្រីទៀតហើយ ។ ពួកគេមិនគិតដូចមុនឡើយ ដែលថាបុរសដែលធ្វើការងារផ្ទះ គឺមិនមែនជាបុរសពិតប្រាកដនោះទេ...."*

*សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តស្ទឹងត្រែង*

*"នៅទីនេះ បញ្ហារបស់ស្ត្រី ត្រូវបានដោះស្រាយយ៉ាងហ្មត់ចត់ ។ កាលពីមុន យើងមានអំពើហិង្សាក្នុងគ្រួសារជាច្រើន ។ ឥលូវនេះ ករណីអំពើហិង្សាក្នុងគ្រួសារ ត្រូវបានរាយការណ៍ភ្លាមៗទៅកាន់អាជ្ញាធរ និងនគរបាល ហើយអ្នកប្រព្រឹត្តខុសត្រូវចាប់ខ្លួន និងទទួលទោសចំពោះមុខច្បាប់ ។ មេភូមិម្នាក់នៅក្នុងឃុំនេះគឺជាស្ត្រី ហើយនៅក្នុងភូមិ មួយទៀត មានស្ត្រីធ្វើជាមេភូមិរង ហើយមេឃុំ គឺជាស្ត្រី ដូច្នេះ នៅទីនេះពុំមានអាជ្ញាធរណាម្នាក់នឹងលើកលែង ឬ អធ្យាស្រ័យ អោយបទល្មើសអំពើហិង្សាក្នុងគ្រួសារឡើយ ។ ឥលូវនេះ យើងមានករណីបែបនេះតិចជាងមុន ។ ប្រជាពលរដ្ឋគិតគូរប្រុងប្រយ័ត្ន មុននឹងធ្វើកំហុសបែបនេះ! កាលពីមុន មានអំពើហិង្សាច្រើន មានរហូតដល់ យ៉ាងហោចណាស់ក្នុងគ្រួសារចំនួន ៤០% ហើយស្ត្រីកម្រនឹងរាយការណ៍ពីករណីអំពើហិង្សានេះណាស់ ។ ពួកគេ មិនហ៊ាននិយាយ និងមិនហ៊ានប្តឹង ហើយគ្មាននរណាម្នាក់ធ្វើសកម្មភាពឡើយ ។ ឥលូវនេះ អំពើហិង្សាមានការថយចុះ ហើយបុរសក៏មានការផ្លាស់ប្តូរផងដែរ ពួកគេដឹងពីតួនាទីយេនឌ័រផ្សេងៗ ។*

*សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងខេត្តក្រចេះ*

## សង្ខេប

- ផ្អែកតាមស្ត្រីសហគមន៍ជាច្រើននាក់ ក្រុមប្រឹក្សាឃុំ និងមន្ត្រីរាជការយល់ថា ស្ត្រីប្រើប្រាស់អំណាចធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងនយោបាយ
- ពួកគេមានទំនួលត្រូវចំពោះសហគមន៍ ជាងចំពោះថ្នាក់លើរបស់ពួកគេ មានតម្លាភាពជាង និងមិនសូវពុករលួយ
- ពួកគេពឹងផ្អែកលើការធ្វើការរួមគ្នា ការពិភាក្សា ការពិគ្រោះយោបល់ ជាងការដឹកនាំឯកឯងជាបុគ្គល
- ពួកគេមានការប្តេជ្ញាចិត្ត និងផ្តោត លើសុខុមាលភាពរបស់សហគមន៍
- ពួកគេព្យាយាមយ៉ាងសកម្ម ដើម្បីធ្វើឱ្យសកម្មភាពរបស់ស្ត្រីមានភាពប្រសើរឡើង និងធ្វើការប្រឆាំង នឹងការរើសអើង ។
- ពួកគេអាចសម្រេចបាននូវលទ្ធផលសំខាន់ នៅក្នុងការដោះស្រាយបញ្ហាសង្គម ដូចជាអំពើហិង្សាលើស្ត្រីជាដើម ដែលនេះធ្វើឱ្យមានភាពប្រសើរជាទូទៅនូវគុណភាពនៃជីវិតសង្គម នៅក្នុងសហគមន៍

ស្ត្រីជនជាតិដើមភាគតិច កំពុងប្រឈមមុខជាមួយនឹងស្ថានភាពមួយ ដែលកំពុងតែមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅមកលើសហគមន៍របស់ពួកគេ របៀបរស់នៅរបស់ពួកគេ និងឋានៈរបស់ពួកគេក្នុងនាមជាស្ត្រី។ ការផ្លាស់ប្តូរពីទិដ្ឋភាពយេនឌ័រ ដែលកើតមានលើទឹកដីរបស់ជនជាតិដើមភាគតិច បានស្តែងចេញតាមរយៈការសម្តែងមតិរបស់ស្ត្រី។ មិនត្រឹមតែការងាររបស់ពួកគេប៉ុណ្ណោះទេដែលមានការផ្លាស់ប្តូរ សូម្បីតែបន្ទុកការងាររបស់ពួកគេក៏មានការកើនឡើងផងដែរ ហើយពួកគេក៏បាត់បង់នូវគុណតម្លៃ នៅក្នុងសេដ្ឋកិច្ចទីផ្សារ ដែលឱ្យតម្លៃទឹកប្រាក់ជាងអ្វីៗដទៃទៀតនោះផងដែរ។

ដូច្នេះហើយស្ត្រីជនជាតិដើមភាគតិច :

- កំពុងបាត់បង់ឋានៈ ចំណេះដឹង និងការគោរព
- តួនាទីដែលពួកគេមានតាំងពីបុរាណមក ដូចជា អ្នកមើលជំងឺ និងមេសាសនាជាដើម ត្រូវបានកាត់បន្ថយ
- ផ្នែកសំខាន់ៗនៃអត្តសញ្ញាណរបស់ពួកគេ ត្រូវបានបាត់បង់ដោយសារតែការបំផ្លិចបំផ្លាញធនធានធម្មជាតិ

គម្រោងអភិវឌ្ឍន៍ដែលកំពុងអនុវត្តបច្ចុប្បន្ន ដោយផ្តោតលើការប្រកួតប្រជែង ការរកចំណេញជាសាច់ប្រាក់លឿនៗ បុគ្គលនិយម និងការកេងប្រវ័ញ្ចធនធានកំពុងដើរផ្ទុយនឹងការធ្វើឱ្យប្រសើរនូវស្ថានភាពរបស់ស្ត្រីជនជាតិដើមភាគតិច និងការរស់នៅប្រកបដោយភាពសុខដុមរមនា ក្នុងសហគមន៍ទាំងមូលរបស់ពួកគេ។

ការបាត់បង់បន្តិចម្តងៗនូវឋានៈរបស់ស្ត្រី **គឺជាបច្ច័យធ្វើឱ្យថយចុះនូវការចូលរួមរបស់ពួកគេនៅក្នុងអាជ្ញាធរប្រពៃណីគេ។** ប្រព័ន្ធអភិបាលកិច្ចជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាគ្រឹះនៃសង្គមរបស់ពួកគេ និងហាក់បីដូចជារចនាសម្ព័ន្ធតែមួយគត់ ដែលអាចនាំសហគមន៍ទាំងនេះឱ្យឆ្លងផុតវិបត្តិទាំងឡាយ ដែលកើតមានឡើងជាក់ស្តែងបាន។

ដំណើរការវិមជ្ឈការនៅក្នុងតំបន់ជនជាតិដើមភាគតិច កំពុងបង្កើតឱ្យមានសំនួរជាច្រើនអំពីតួនាទីរបស់ដំណើរការនេះ នៅក្នុងការជំរុញឱ្យមានសមាហរណកម្មក្រុមជនជាតិដើមភាគតិច។ កង្វះខាតការចង្អុលបង្ហាញឱ្យបានច្បាស់លាស់ ដើម្បីណែនាំពីការប្រាស្រ័យទាក់ទងរវាងអាជ្ញាធរប្រពៃណី ជាមួយនឹងអាជ្ញាធរមូលដ្ឋានផ្លូវការ គឺជាឧទាហរណ៍មួយនៃភាពមិនច្បាស់លាស់នេះ ក៏ដូចជាបញ្ហាភាសាទាំងមូលហេតុ អ្វីបានជាភាសាខ្មែរជាភាសាតែមួយសម្រាប់ការងារ? ហេតុអ្វីបានជាគេមិនប្រើ ២ ភាសា?

៤. ផលប៉ះពាល់នៃគំរូអភិវឌ្ឍន៍ធំៗ មកលើជនជាតិដើមភាគតិច សូមមើលសារសម្រាប់ទិវាជនជាតិដើមពិភពលោកអន្តរជាតិ ៨ សីហា ២០០៨ ផ្តល់ដោយ Victoria Tauli-Corpuz ប្រធានវេទិកាអចិន្ត្រៃយ៍របស់សហប្រជាជាតិស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច www.un.org/esa/socdev/unpfii/

ជាមួយនឹងការបោះឆ្នោតក្នុងឆ្នាំ ២០០៧ ស្ត្រីរាប់ពាន់នាក់ បានចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំ ប៉ុន្តែ ក្នុងខណៈពេលដែលលទ្ធផលជាចំនួនមានច្រើនគួរឱ្យកត់សម្គាល់ ការចូលរួមប្រកបដោយគុណភាពរបស់ពួក គេនៅតែចោទជាបញ្ហា។ នៅតាមតំបន់ជនជាតិដើមភាគតិច ស្ត្រីត្រូវប្រឈមនឹងឧបសគ្គជាច្រើន ដែលត្រូវយកមកធ្វើការពិចារណា ដើម្បីឱ្យពួកគេក្លាយជាសមាជិកពេញលេញរបស់ក្រុមប្រឹក្សាឃុំ ។

ស្ត្រីជាច្រើននាក់ ដែលជាប់ឆ្នោតក្នុងក្រុមប្រឹក្សាឃុំ ធ្វើតែកិច្ចការដែលពាក់ព័ន្ធជាមួយនឹង "យេនឌ័រ" តែប៉ុណ្ណោះ និងនៅឃ្លាតពីការសម្រេចចិត្ត និងសកម្មភាពដទៃទៀត ។ "**ទស្សនៈវិស័យយេនឌ័រ**" **ពិតប្រាកដគឺរួមបញ្ចូលកិច្ចការសង្គមសំខាន់ៗ** ដែលគួរជាការព្រួយបារម្ភចម្បងជាងគេ នៅក្នុងអភិបាលមូលដ្ឋាន ដូចជា សុខភាព អនាម័យ ការថែទាំកុមារជាដើម ។ ដោយចាត់ទុកថាជាបញ្ហា យេនឌ័រ ជារឿយៗកិច្ចការទាំងនេះមានថវិកាមិនគ្រប់គ្រាន់ ។ ក្នុងពេលជាមួយគ្នា **ការរើសអើងយេនឌ័រ** ដែលជាបញ្ហាចម្បងដែលស្ត្រីកំពុងប្រឈម **មិនត្រូវបានគេដោះស្រាយឱ្យមានប្រសិទ្ធភាពនោះទេ។**



ស្ត្រីជនជាតិដើមភាគតិចចូលរួមសិក្ខាសាលាក្នុងខេត្តក្រចេះ

ស្ត្រីជនជាតិដើមភាគតិច ចាត់ទុកការចូលរួមរបស់ពួកគេនៅក្នុងអាជ្ញាធរមូលដ្ឋាន ថាមានសារៈសំខាន់យ៉ាងខ្លាំង។ ឈរលើទស្សនៈនេះ ស្ត្រីធ្វើការងារក្នុងភិបាលកិច្ចមូលដ្ឋានកាន់តែច្រើននឹងនាំឱ្យមានការផ្លាស់ប្តូរមួយចំនួន ដើម្បីធ្វើឱ្យមានតុល្យភាពនៃអំណាចរវាងស្ត្រី និងបុរស និងបង្កើនឱ្យមានសមធម៌។

យ៉ាងណាមិញ បទពិសោធន៍របស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំបង្ហាញថា ការជាប់ឆ្នោតមិនមែនជាការធានាឱ្យមានអំណាចនោះទេ ស្ត្រីត្រូវតែតស៊ូនៅក្នុងក្រុមប្រឹក្សា ដើម្បីទទួលបានអំណាច និងការគោរពបន្ថែម បើមិនដូច្នោះទេពួកគេងាយនឹងត្រូវបានគេអត់អើពើ។ បើតាមការលើកឡើងរបស់ស្ត្រីជាក្រុមប្រឹក្សា និងស្ត្រីក្នុងសហគមន៍ ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីដោះស្រាយបញ្ហានៅកៀកនឹងសហគមន៍ ជាងអ្នកនៅថ្នាក់លើ មិនសូវប្រព្រឹត្តអំពើពុករលួយ និងមិនសូវចាប់អារម្មណ៍ចំពោះផល ប្រយោជន៍ផ្ទាល់ខ្លួន។

ពាក់ព័ន្ធជាមួយនឹងឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងក្រុមប្រឹក្សាឃុំវិញ ការប្រកាន់គំនិតខុសនិងការលំអៀងនៅតែមានច្រើន ជាពិសេសក្នុងចំណោមអ្នកដែលមានការពាក់ព័ន្ធ។ កង្វះខាតការចេះភាសាខ្មែរត្រូវបានគេចាត់ទុកថាជាកង្វះខាត "ការអប់រំ"។ ពុំមានការទទួលស្គាល់សមត្ថភាព និងជំនាញរបស់ស្ត្រីជនជាតិដើមភាគតិច ដូចជា ជាអ្នកធ្វើការងារសិប្បកម្ម អ្នកកសិកម្ម ជាអ្នកប្រមូលផលិតផលធម្មជាតិ ជាចាស់ព្រឹទ្ធាចារ្យ ជាអ្នកមើលជំងឺ ជាអ្នកប្រារព្ធពិធីសាសនា ជាសិល្បៈករ ជាអ្នកសន្សំសំចៃ និងជាអ្នកបញ្ជូនវប្បធម៌នោះទេ។

**ស្ត្រីជនជាតិដើមភាគតិចមានការនិយាយស្តីច្រើននៅក្នុងការវិភាគរបស់គេៈ** ពួកគេគិតគូរពីកត្តាផ្សេងៗគ្នាជាច្រើន ប៉ុន្តែចាត់ទុកការរើសអើងយេនឌ័រ និងការគ្របដណ្តប់របស់បុរស ថាជាឧបសគ្គធំជាងគេ។ ការមិនចេះភាសាខ្មែរ បានកម្រិតការចូលរួមរបស់ពួកគេ ប៉ុន្តែពួកគេមិនគិតថាខ្លួនឯងមិនអាចបំពេញតួនាទីជាក្រុមប្រឹក្សានោះទេ។

ស្ត្រី ដែលមានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ ក្នុងខេត្តក្រចេះ និងស្ទឹងត្រែង លើកឡើងថា នៅពេលដែលស្ត្រីមានអំណាចគ្រប់គ្រាន់ពួកគេមានឥទ្ធិពលយ៉ាងខ្លាំងមកលើរបៀបគ្រប់គ្រង។ វិធីសាស្ត្រយេនឌ័រពិតប្រាកដ សំដៅដោះស្រាយបញ្ហាអសមធម៌ឡើងវិញ គឺជាឧបករណ៍ដ៏មានអានុភាពមួយ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ ថ្នាក់មូលដ្ឋានពិតប្រាកដដែលផ្តល់អត្ថប្រយោជន៍ទៅឱ្យសហគមន៍ទាំងមូល។ នៅក្នុងករណីជាច្រើន របៀបធ្វើនយោបាយបែបនេះ គឺស្រដៀងគ្នាជាមួយនឹងអ្វីដែលជនជាតិដើមភាគតិចលើកឡើងថាជាប្រព័ន្ធអភិបាលកិច្ចល្អជាងគេរបស់ពួកគេ និងជាមូលដ្ឋានបទពិសោធន៍មួយដ៏ល្អ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រី និងបុរសជនជាតិដើមភាគតិច នៅក្នុងការងារគ្រប់គ្រង អភិរក្ស និងផ្តល់ថាមពលឡើងវិញទៅឱ្យសហគមន៍របស់ពួកគេ។

## កម្រិតសហគមន៍

### ១. ចាប់ផ្តើមពីចំណេះដឹង ការយល់ដឹង និងតម្រូវការរបស់ស្ត្រីជនជាតិដើមភាគតិច

ចាំបាច់ត្រូវមានការទទួលស្គាល់ យល់ដឹង និងឱ្យតម្លៃអំពីសមត្ថភាពរបស់ជនជាតិដើមភាគតិច។ **គម្រោងនានា ដែលមានគោលបំណងគាំទ្រការចូលរួម ការផ្តល់អំណាច និងការចូលរួមរបស់ពួកគេនៅក្នុងកិច្ចការនយោបាយ គួរចាប់ផ្តើមដោយស្តាប់ពីអ្វីដែលស្ត្រីដឹង** អ្វីដែលពួកគេបានយល់ និងអ្វីដែលបទពិសោធន៍បានបង្រៀន ពួកគេមូលហេតុដែលពួកគេទទួលស្គាល់ និងរបៀបដោះស្រាយបញ្ហាដែលពួកគេគិតឃើញ។

### ២. ការរៀនសូត្រ

តើស្ត្រីជនជាតិដើមភាគតិចចង់រៀនចេះអ្វីខ្លះ? និង តើវាសមស្របជាមួយនឹងរបៀបវារៈរបស់ពួកគេ ដែលចង់លុបបំបាត់ភាពរើសអើង ចង់បានអំណាចថែមទៀត និងចង់ការពារសហគមន៍របស់ពួកគេដោយរបៀបណា? ទាំងនេះសុទ្ធតែជាប្រភេទសំនួរដែលត្រូវពិភាក្សា មុនពេលចូលរួមនៅក្នុងសកម្មភាពបណ្តុះបណ្តាលនានា ដែលចង់ "ផ្តល់អំណាច" ទៅឱ្យស្ត្រីជនជាតិដើមភាគតិច។

**ការចេះអក្សរខ្មែរចំពោះមនុស្សពេញវ័យ គឺពិតជាបញ្ហាមួយដ៏សំខាន់ សម្រាប់ស្ត្រីជនជាតិដើមភាគតិច។** កម្មវិធីអក្ខរកម្មមួយចំនួនតូចដែលមាននៅមូលដ្ឋាន មិនបានពិចារណាលើឧបសគ្គជាក់លាក់ដែលស្ត្រីជនជាតិដើមភាគតិចជួបប្រទះនោះឡើយ។ កម្មវិធីបែបនេះគួរជាកម្មវិធីដែលមានតម្លៃសមស្រប រៀបចំឡើងនៅជុំវិញតម្រូវការរបស់ស្ត្រី និងដោយមានការចចារជាមួយពួកគេ។ កម្មវិធីអប់រំតាមវិទ្យុដោយប្រើវិទ្យុដែលស៊ីថ្មតិច អាចប្រើប្រាស់សម្រាប់ការរៀនសូត្រពីចម្ងាយ នៅពេលដែលស្ត្រីជនជាតិដើមភាគតិចជាច្រើននាក់ផ្លាស់ប្តូរលំនៅដ្ឋានរបស់ពួកគេនៅរដូវភ្លៀងធ្លាក់។ អាចតំលើងម៉ាស៊ីនភ្លើងដើរដោយថាមពលពន្លឺព្រះអាទិត្យតូចមួយនៅក្នុងភូមិ និងនៅតាមស្រែចំការ ដើម្បីឱ្យមានភ្លើងប្រើនៅពេលល្ងាច ពេលដែលស្ត្រីជួបជុំគ្នាដើម្បីរៀនសូត្រ និងត្រូវការថាមពលសម្រាប់វិទ្យុរបស់ពួកគេ។ គេក៏គួរពិភាក្សាអំពីខ្លឹមសារនៃការ បណ្តុះបណ្តាលជាមួយនឹងស្ត្រីផងដែរ។ គួរប្រមូល និងវិភាគលើឧទាហរណ៍ពីប្រទេសដទៃទៀត ដែលបានបង្កើតកម្មវិធីរៀនសូត្រពីចម្ងាយផ្តោតគោលដៅលើជនជាតិដើមភាគតិច។

### ៣. ផ្តល់នូវទស្សនៈវិស័យយេនឌ័ររបស់ជនជាតិដើមភាគតិចមួយដែលពិតប្រាកដ

បុរេវិនិច្ឆ័យច្រើន ធ្វើឱ្យមានការយល់ឃើញថាស្ត្រីជនជាតិដើមភាគតិច ទទួលរងការរើសអើងក្នុងកម្រិតមួយខ្ពស់នៅក្នុងសហគមន៍របស់ពួកគេ។ ជារឿយៗ ការយល់ឃើញរបស់អ្នកខាងក្រៅអាគខានមិនបាន

ពិចារណាលើទិដ្ឋភាពឋានៈរបស់ស្ត្រីជនជាតិដើមភាគតិច ដែលពួកគេតែងតែចង់បាននូវការទទួលស្គាល់ និងការគោរពក្នុងសង្គមនោះទេ។ ចំពោះក្រុមស្រាវជ្រាវ គួរមានអ្នកស្រាវជ្រាវជាស្ត្រីជនជាតិដើមភាគតិច ដើម្បីធានាថា ការវិភាគលើទំនាក់ទំនងយេនឌ័រ នៅក្នុងសង្គមរបស់ពួកគេកុំឱ្យមានភាពលំអៀង។ គួរបើកឱកាសឱ្យពួកគេចូលរួមនៅក្នុងការងារនេះ ដូចជាការស្រាវជ្រាវបែបសកម្មភាព អាហារូបករណ៍សម្រាប់ការស្រាវជ្រាវ និងការស្រាវជ្រាវរួមជាដើម។ និស្សិតស្រី ដែលជាជនជាតិដើមភាគតិចគួរទទួលបានការគាំទ្រ និងឱកាសដូចជា លទ្ធភាពប្រើប្រាស់មណ្ឌលសិក្សាអំពីជនជាតិដើមភាគតិចជាដើម។

## ៤. ផ្សារភ្ជាប់យេនឌ័រ ជាមួយនឹងសេចក្តីត្រូវការរបស់ជនជាតិដើមភាគតិច

ប្រសិនបើនិន្នាការនៃការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងការរំលោភដីធ្លីនៅតែបន្តមានទៀត មិនយូរមិនឆាប់ នឹងនៅសល់សហគមន៍ជនជាតិដើមភាគតិចតែមួយចំនួនតូចតែប៉ុណ្ណោះ។ ដូចដែលបានបង្ហាញនៅក្នុងការសិក្សានេះ ការអភិវឌ្ឍន៍នាពេលបច្ចុប្បន្នកំពុងបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានមួយដល់ស្ត្រីជនជាតិដើមភាគតិច។ បញ្ហាយេនឌ័រគួរត្រូវបានគេមើលឃើញនៅក្នុងបរិបទរួមនេះ។ ម្យ៉ាងវិញទៀត ការមិនសូវមានស្ត្រីចូលរួមនៅក្នុងគម្រោងយេនឌ័រតាមតំបន់ជនជាតិដើមភាគតិច និងការងាកចេញពីគំនិតយេនឌ័រពីការផ្តោតជាចម្បងរបស់វាដែលជាការដោះស្រាយការរើសអើង នឹងមិនទៅចំទិសដៅនៃការលើកកម្ពស់សមធម៌ឡើយ។ គម្រោងធ្វើការងារជាមួយស្ត្រីនៅតាមតំបន់ជនជាតិដើមភាគតិចមិនគួរធ្វើអ្វីដែលធ្លាប់បានធ្វើនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេសឡើយ ព្រោះជនជាតិដើមភាគតិចពិតជាមានបញ្ហាជាក់លាក់របស់ពួកគេ។

កម្មវិធីជាក់លាក់ ដែលអនុវត្តនៅក្នុងតំបន់ជនជាតិដើមភាគតិច គួរបញ្ចូលនូវចក្ខុវិស័យយេនឌ័រពិតប្រាកដមួយ ដើម្បីផ្តល់ការគាំទ្រដល់ស្ត្រីក្នុងសហគមន៍ នៅក្នុងការតស៊ូរបស់ពួកគេ ដើម្បីសមធម៌ភាពជាតំណាងការចូលរួម និងអំណាចច្រើនជាងមុន។

## ៥. របៀបធ្វើការងាររបស់ស្ត្រីជនជាតិដើមភាគតិច

ស្ត្រី និងបុរសជនជាតិដើមភាគតិច មានរបៀបធ្វើការងារផ្សេងពីគ្នាក្នុងការសម្រេចចិត្ត ធ្វើការរួមគ្នា និងដោះស្រាយបញ្ហា។ ជាដំបូង ទីភ្នាក់ងារអភិវឌ្ឍន៍ ដែលប្តេជ្ញាជួយដល់ស្ត្រីជនជាតិដើមភាគតិចសំដៅបង្កើនការចូលរួមនៅក្នុងនយោបាយ និងភាពជាតំណាងរបស់ពួកគេ គួរធ្វើការផ្ទៀងផ្ទាត់ជាមុនសិន ថាតើពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីសំរបទៅតាមគុណតម្លៃទាំងនោះហើយឬនៅ ថាតើរបៀបធ្វើការរបស់ពួកគេស្របគ្នាជាមួយនឹងរបៀបដោះស្រាយបញ្ហារបស់ស្ត្រីជនជាតិដើមភាគតិចដែរឬទេ ថាតើការពិគ្រោះយោបល់ ការពិភាក្សា និងការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ គឺជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តផ្ទៃក្នុងដែរ ឬទេ ថាតើគណនេយ្យភាព ចំពោះមូលដ្ឋានគឺជាកង្វល់ចម្បង ដែលជំរុញឱ្យមានសកម្មភាពដែរឬទេ។

## កម្រិតក្រុមប្រឹក្សាឃុំ

### ១. គាំទ្រស្ត្រីជនជាតិដើមភាគតិចក្នុងក្រុមប្រឹក្សាឃុំ

ស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ នៅតាមតំបន់ជនជាតិដើមភាគតិចត្រូវការការគាំទ្រ ដើម្បីបង្កើនទម្ងន់នយោបាយរបស់ពួកគេ និងជំនះឧបសគ្គនានា ដែលកើតឡើងដោយសារការរើសអើង។ សំខាន់ណាស់ដែលស្ត្រីត្រូវស្វែងរកឱកាសដើម្បីពិភាក្សាបញ្ហាទាំងអស់នេះ និងដើម្បីគិតពីយុទ្ធសាស្ត្រជំនះបញ្ហា និងសម្រេចឱ្យបាននូវការផ្តល់អំណាចពិតប្រាកដ។

**វេទិកា និងការជួបជុំគ្នា** គួរផ្តល់ឱកាសឱ្យស្ត្រីជនជាតិដើមភាគតិចបានពិភាក្សាអំពីបញ្ហារបស់ពួកគេ ចែករំលែកបទពិសោធន៍ និងរិះរកយុទ្ធសាស្ត្រកែលម្អ។ **របៀបវារៈ និងខ្លឹមសាររបស់វេទិកាបែបនេះ គួរពិភាក្សាជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំជាជនជាតិដើមភាគតិច ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការពិតប្រាកដរបស់ពួកគេ និងដើម្បីសម្របទៅតាមអត្តសញ្ញាណរបស់ជនជាតិដើមភាគតិច។** ការផ្លាស់ប្តូរយោបល់គ្នារវាងស្ត្រីជនជាតិដើមភាគតិច និងស្ត្រីមិនមែនជនជាតិដើមភាគតិច នៅក្នុងការចូលរួមក្នុងនយោបាយមានសារៈសំខាន់ខ្លាំងណាស់ ហើយគួរជាដំណើរការរៀនសូត្រពីគ្នាទៅវិញទៅមកជាជាងគ្រាន់តែការបញ្ជ្រាបការអនុវត្ត និងខ្លឹមសារដែលបង្កើតឡើងនៅក្នុងបរិបទខ្មែរ។

### ២. ឱ្យសមាជិកក្រុមប្រឹក្សាឃុំ ជាស្ត្រីជនជាតិដើមភាគតិច ចូលរួមនៅក្នុងការបង្កើនការយល់ដឹង និងការ ផ្សព្វផ្សាយក្នុងសហគមន៍អំពីស្ត្រីនៅក្នុងឆាកនយោបាយ

គួរជំនួសឱ្យការរៀបចំផែនការអន្តរាគមន៍ពីខាងក្រៅ ដោយអ្នកការពាក់ព័ន្ធដែលជាអ្នកមានវប្បធម៌ និងខ្លឹមសារបរទេស និងដែលកម្រសម្របទៅតាមរបៀបធ្វើការងាររបស់ជនជាតិដើមភាគតិច ជាការសំខាន់ដែលត្រូវមានសមាជិកក្រុមប្រឹក្សាឃុំជាជនជាតិដើមភាគតិចចូលរួមនៅក្នុងកិច្ចប្រជុំរបស់សហគមន៍ ដែលពួកគេអាចចែករំលែកបទពិសោធន៍របស់ពួកគេ ពន្យល់ពីតួនាទីរបស់ពួកគេ និងលើកទឹកចិត្តដល់ស្ត្រីឱ្យចូលរួមនៅក្នុងការបោះឆ្នោតនាពេលអនាគត។ កិច្ចប្រជុំនៅក្នុងសហគមន៍ទាំងនេះ អាចជួយរិះរកយុទ្ធសាស្ត្រកាន់តែល្អប្រសើរឡើងដើម្បីបង្កើនការចូលរួមរបស់ស្ត្រី។

### ៣. ពិនិត្យឡើងវិញលើបញ្ហាយេនឌ័រ នៅក្នុងបរិបទរបស់អាជ្ញាធរមូលដ្ឋាន

ចាំបាច់ត្រូវធ្វើការសិក្សាឡើងវិញ លើអត្ថន័យរបស់គោលនយោបាយយេនឌ័រនៅថ្នាក់មូលដ្ឋាន និងញែកការរើសអើងពាក់ព័ន្ធនឹងយេនឌ័រ ឱ្យដាច់ពីបញ្ហាសង្គម និងសេវាកម្មសង្គម។ ភាពវឹកវរនៃដំណើរការវិមជ្ឈការបង្កើតឱ្យមាននូវស្ថានភាពមួយដែលមានភាពបន្ទាន់។

ត្រូវរៀបចំឱ្យមានការពិភាក្សា ការប្រជុំតុមូល និងសិក្ខាសាលា ដើម្បីបញ្ជាក់:

ក. ថាតើតួនាទីរបស់សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រី ត្រូវកម្រិតត្រឹមតែបញ្ហាយេនឌ័រ ឬយ៉ាងណា?

ខ. គោលគំនិតយេនឌ័រ ពាក់ព័ន្ធជាមួយនឹងការរើសអើងយេនឌ័រ ឬគ្រាន់តែជាពាក្យ ដែលគេប្រើសម្រាប់សំដៅលើសេវាសង្គមនានា ដូចជា សុខភាព អនាម័យ ការថែទាំកុមារ ។ល។

ក្រុមប្រឹក្សាឃុំ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់គួរចូលរួមនៅក្នុងការពិភាក្សាទាំងនេះ ហើយការយល់ឃើញរបស់ពួកគេ គួរដាក់បង្ហាញទៅឱ្យអ្នកតាក់តែងគោលនយោបាយបានឃើញ។



ការបង្ហាញមតិរបស់ក្រុមប្រឹក្សាឃុំ
ជនជាតិគ្រឹង នៅសិក្ខាសាលាមួយនៅ
ក្នុងខេត្ត  ក្រចេះ  ជាមួយអ្នកចូលរួម
ជាជនជាតិដើមភាគតិច និង ខ្មែរ



## តម្រិតជាតិ

### ១. តម្រូវការអោយមានការតស៊ូមតិ

ភាពរស់រាន នៃអត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិដើមភាគតិច គឺមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយនឹងសមត្ថភាព ដែលជនជាតិដើមភាគតិចមាន ដើម្បីរក្សាដែនដី និងធនធានរបស់ពួកគេ។ ទាំងអនុសញ្ញាលេខ ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ទាំងសេចក្តីប្រកាសរបស់សហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៦ ជម្រុញ:

*"... ឱ្យមានការទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ដើម្បីមានកម្មសិទ្ធិ និងត្រួតត្រាលើដីធ្លីរបស់ពួកគេ មានកម្មសិទ្ធិ និងគ្រប់គ្រងធនធានធម្មជាតិដែលមាននៅលើដីទាំងនោះ... ដើម្បីធ្វើការសម្រេចចិត្តថាតើការអភិវឌ្ឍន៍របៀបណា ដែលនឹងកើតមាននៅលើទឹកដី និងធនធានរបស់ពួកគេ"។*

ភាពគ្មានសមត្ថភាព ដើម្បីធានាឱ្យជនជាតិដើមភាគតិចមានសិទ្ធិលើទឹកដី និងធនធានរបស់ពួកគេគឺជាសញ្ញាបញ្ជាក់ពីភាពមិនប្រាកដប្រជា នៃការរស់រានជាក្រុមរបស់ពួកគេ ដែលមានអត្តសញ្ញាណវប្បធម៌ដាច់ដោយឡែកទៅថ្ងៃអនាគត។ គេមិនអាចធ្វើការពិចារណាលើទិដ្ឋភាពដោយឡែកនៃជីវិតរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងករណីនេះមានន័យថា ការចូលរួមរបស់ពួកគេនៅក្នុងនយោបាយដោយមិនពិចារណាលើស្ថានភាពជាក់ស្តែង កាលៈទេសៈដែលមានឥទ្ធិពលលើទិដ្ឋភាពនេះ យថាភាព និងភាពបន្ទាន់ដែលស្ត្រីប្រឈមភាពចាំបាច់ ដើម្បីឱ្យមានគោលនយោបាយដើម្បីការពារពួកគេ និងសហគមន៍របស់ពួកគេនោះទេ។

### ២. ស្ត្រីជនជាតិដើមភាគតិចនៅក្នុងនយោបាយ: ការការទទួលយក ឬសមាហរណកម្ម?

គំនិតដែលច្រើនមាននៅក្នុងការយល់ឃើញរបស់អ្នកដែលមានការពាក់ព័ន្ធ គឺ:

- **តើត្រូវ "អប់រំ" ស្ត្រីជនជាតិដើមភាគតិច ដោយរបៀបណា ដើម្បីអោយពួកគេមានភាពស័ក្តិសមទៅនឹងបទដ្ឋាននយោបាយដែលធំជាងគេលើសលប់?**

ប៉ុន្តែ សំនួរដែលត្រូវសួរនោះគឺ:

- **តើបទដ្ឋាននយោបាយ ដែលធំជាងគេលើសលុបនេះ អាចកែសម្រួលដោយរបៀបណា ដើម្បីផ្តល់លទ្ធភាពទៅឱ្យស្ត្រីជនជាតិដើមភាគតិចចូលរួមនៅក្នុងនយោបាយដែរទេ?**

ដំបូងគឺជាបញ្ហាភាសា។ តើវាយុត្តិធម៌ទេ ដែលត្រូវដាក់កម្រិតសិទ្ធិ របស់ប្រជាពលរដ្ឋមួយក្រុមដោយសារតែពួកគេមិនចេះភាសា ដែលមិនមែនជាភាសាផ្ទាល់ខ្លួនរបស់ពួកគេនៅពេលដែលពួកគេមិនមានលទ្ធភាពទទួលបានសេវាអប់រំ?

តើការចេះអក្សរខ្មែរពិតជាលក្ខខណ្ឌមួយដែលត្រូវតែមានមិនអាចខ្វះបានសម្រាប់បេក្ខជនក្រុមប្រឹក្សាឃុំនៅក្នុង ដែនដីរបស់ជនជាតិដើមភាគតិចមែនទេ?

ចុះទិដ្ឋភាពដទៃទៀតនៃជីវិត ដូចជា សង្គម សេដ្ឋកិច្ច និងសាសនាវិញនោះ? ចុះសមាហរណកម្មរបស់អាជ្ញាធរប្រពៃណី ច្បាប់ប្រពៃណី វប្បធម៌ និងទម្លាប់នានាដទៃទៀត ដែលពាក់ព័ន្ធជាមួយនឹងអត្តសញ្ញាណវិញយ៉ាង ណាដែរ?

គួររៀបចំឱ្យមានការពិភាក្សា និងការពិគ្រោះយោបល់ ដែលអ្នកពាក់ព័ន្ធ និងអ្នកតាក់តែងគោលនយោបាយរួមគ្នាជាមួយនឹងក្រុមប្រឹក្សាឃុំដែលជាជនជាតិដើមភាគតិច អាចរិះរកវិធីធ្វើការសន្ទនាគ្នាអំពីបញ្ហាសំខាន់ៗទាំងនេះ។ ដោយសារតែការជជែកវែកញែក និងការពិគ្រោះយោបល់រវាងស្ត្រី និងស្ត្រីជារឿយៗ មានលក្ខណៈបើកចំហ និងមិនសូវប្រឈមមុខគ្នា។ គួររៀបចំឱ្យមានការពិភាក្សាគ្នាអំពីបញ្ហាទាំងនេះ រវាងស្ត្រីជនជាតិដើមភាគតិច និងស្ត្រីដែលមិនមែនជាជនជាតិដើមភាគតិច ដែលចូលរួមនៅក្នុងការងារនយោបាយ។

## ៣. ភាពជាតំណាងរបស់ជនជាតិដើមភាគតិច ក្នុងនយោបាយ: កូតា អាសនៈបម្រុង...

តើជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា នឹងមានភាពជាតំណាងក្នុងនយោបាយដោយរបៀបណា? ចុះស្ត្រីជនជាតិដើមភាគតិចវិញ?

តើប្រព័ន្ធកូតា និង/ឬ អាសនៈបម្រុង ពាក់ព័ន្ធជាមួយនឹងការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងក្រុមប្រឹក្សាឃុំដែរឬទេ? វេទិកាជនជាតិដើមភាគតិច និងអង្គការ ដែលមានសកម្មភាពនៅក្នុងប្រទេសកម្ពុជា អាចធ្វើការវិភាគ និងពិភាក្សាអំពីឱកាសទាំងនេះ។ គួររៀបចំឱ្យមានការផ្លាស់ប្តូរបទពិសោធន៍ជាមួយនឹងក្រុមជនជាតិ និងស្ត្រីពីប្រទេស និងតំបន់ដទៃទៀត ដែលធ្លាប់ប្រើប្រាស់គោលនយោបាយទាំងនេះ ដើម្បីកំណត់ពីឱកាស និងបញ្ហានានាដែលពាក់ព័ន្ធ។

## ៤. តួនាទីរបស់គណបក្សនយោបាយ

ច្បាប់ នៅក្នុងប្រទេសកម្ពុជា មិនអនុញ្ញាតឱ្យបេក្ខជនឈរឈ្មោះបោះឆ្នោត ដោយមិនមានឈ្មោះនៅក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយនោះទេ។ ដូច្នេះគន្លឹះដើម្បីឱ្យស្ត្រី និងជនជាតិដើមភាគតិច បានចូលរួមនៅក្នុងក្រុមប្រឹក្សាឃុំបាន គឺត្រូវមានការគាំទ្រពីគណបក្សនយោបាយ។ គម្រោងដែលមានគោលបំណងបង្កើនការចូលរួមរបស់ស្ត្រីជាបេក្ខជនគួរផ្តោតជាពិសេសលើគណបក្សនយោបាយនៅក្នុងសកម្មភាពតស៊ូមតិរបស់ពួកគេ។

## ៥. ការទទួលស្គាល់ និងការមើលឃើញស្ត្រីជនជាតិដើមភាគតិច

ស្ត្រីជនជាតិដើមភាគតិច ត្រូវការការទទួលស្គាល់ដើម្បីដោះស្រាយពីការគោរពតិចតួចដែលពួកគេបានទទួល និងកង្វះខាតការទទួលស្គាល់ឋានៈ សមត្ថភាព និង តួនាទីរបស់ពួកគេ។

ជាការសំខាន់ណាស់ដែលគេត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ ដើម្បីអបអរពីលក្ខណៈសម្បត្តិនិងចំនុចខ្លាំងដែលស្ត្រីមាន ជាជាងបង្ហាញពីចំនុចខ្សោយរបស់ស្ត្រី។ គួរគាំទ្រ និងរៀបចំឱ្យមានព្រឹត្តិការណ៍ ដែលមានការទទួលស្គាល់ និងការចែករំលែកនូវសិល្បៈ ជំនាញ ចំណេះដឹង និងការតស៊ូរបស់ស្ត្រីជនជាតិដើមភាគតិច។ ប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ និងវិទ្យុជាដើម គួរតែចូលរួមនៅក្នុងយុទ្ធនាការ និងកម្មវិធីនានា ដើម្បីឱ្យស្ត្រីជនជាតិដើមភាគតិចកាន់តែត្រូវគេមើលឃើញ ផ្តល់ឱ្យពួកគេនូវឱកាសបញ្ចេញសំលេង និងលើកកម្ពស់បំណងប្រាថ្នា (របៀបវារៈ) របស់ពួកគេ។

# ឯកសារយោង


## វិធីសាស្ត្រ

- Francis Diana, (២០០៥) ការស្រាវជ្រាវសកម្មភាព: ឆ្លើយតបនឹងជម្លោះ, ACTS Birmigham UK
- Tuhiwai Smith L., (២០០៥) លើមូលដ្ឋានដែលពោរពេញដោយល្បិច (On a Tricky Ground): ស្រាវជ្រាវអំពីជនជាតិដើម នៅក្នុងសម័យកាលនៃភាពមិនប្រាកដប្រជា (Researching the Native in an Age of Uncertainty) សៀវភៅណែនាំអំពីការស្រាវជ្រាវបែបគុណវិស័យ ៨៥-១០៧

## ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា

- Backstrom M., Ironside J., Paterson G., Padwe J., Baird I.G., (២០០៦) ករណីសិក្សាអំពីប្រព័ន្ធច្បាប់ និងការដោះស្រាយជម្លោះជាប្រពៃណីរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី UNDP/ក្រសួងយុត្តិធម៌ កម្មវិធីកែទំរង់ច្បាប់ និង តុលាការ/Action Aid
- Ironside Jeremy & Baird Ian, (២០០៣) ទីរហោឋាន និង ទិដ្ឋភាពវប្បធម៌: ការតាំងទីលំនៅកសិកម្ម និងកម្មសិទ្ធិដីធ្លី និងធនធាននៅក្នុង និងនៅជិតសួនឧទ្យានជាតិវីរៈជ័យ ប៉ែកឥសានរបស់ប្រទេសកម្ពុជា BPAMP មន្ទីរបរិស្ថានខេត្តរតនៈគិរី ប្រទេសកម្ពុជា
- Maffii Margherita (២០០៦) សំលេងរបស់ស្ត្រី: ស្ត្រីជនជាតិដើម និងភាគតិច នៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ភ្នំពេញ
- Ehrentraut Stefan, (២០០៨) ជនជាតិដើមភាគតិច និងវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា លទ្ធផលបឋម www.elgc.org
- Ironside Jeremy (២០០៧) តួនាទីរបស់ស្ត្រី នៅក្នុងប្រព័ន្ធដោះស្រាយជម្លោះជាប្រពៃណី និងនៅក្នុងភាពជាអ្នកដឹកនាំនៅតាមសហគមន៍ជនជាតិដើមភាគតិច ក្នុងខេត្តរតនៈគិរី ប្រទេសកម្ពុជា ការបោះពុម្ពផ្សាយរបស់ Action Aid

## ស្ត្រី និង ការអភិវឌ្ឍន៍ ស្ត្រី និង អភិបាលកិច្ច

- Drage Jean, (២០០១) ស្ត្រី នៅក្នុងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន នៅអាស៊ី និងប៉ាស៊ីហ្វិក ការវិភាគប្រៀបធៀបរវាងប្រទេសទាំង ១៣ គណៈកម្មាការសេដ្ឋកិច្ច និងសង្គមរបស់សហប្រជាជាតិ សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក
- Elson Diane (១៩៩០) ភាពលំអៀងរបស់បុរស នៅក្នុងការអភិវឌ្ឍន៍: ទិដ្ឋភាពទូទៅ នៅក្នុងភាពលំអៀងរបស់បុរស នៅក្នុងការអភិវឌ្ឍន៍ សារព័ត៌មានរបស់សកលវិទ្យាល័យ Manchester ១-១៥
- Htun Mala (២០០៤) តើយេនឌ័រដូចគ្នានឹងជនជាតិ ដែរឬទេ? ភាពជាតំណាងនយោបាយ របស់ក្រុមអត្តសញ្ញាណ ទស្សនៈវិស័យស្តីពីនយោបាយ វ៉ុលទី ២ លេខ ៣ ៤៣៩-៤៥៨

- Sassen Saskia, (១៩៩៩) ទីងងឹត (Blind Spots): ឆ្ពោះទៅរកការវិភាគរបស់សកម្មជនស្ត្រីអំពីសេដ្ឋកិច្ចសកល នាពេលបច្ចុប្បន្ន បទបង្ហាញនៅសាលាសេដ្ឋកិច្ច Centennial ក្រុងឡុង ចក្រភពអង់គ្លេស

## ក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងប្រទេសកម្ពុជា

- Goergen Maraile, (២០០៧) ស្ត្រី នៅក្នុងការបោះឆ្នោតឃុំសង្កាត់លើកទី ២ នៅក្នុងប្រទេសកម្ពុជា ទិន្នន័យ និងការបកស្រាយលទ្ធផល ភ្នំពេញ GTZ
- Kim Ninh & Henke Roger, (២០០៥) ក្រុមប្រឹក្សាឃុំសង្កាត់នៅក្នុងប្រទេសកម្ពុជា ការអង្កេតថ្នាក់ជាតិលើមុខងារ និងការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដោយផ្តោតជាពិសេសលើការដោះស្រាយជម្លោះ មូលនិធិអាស៊ី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (២០០៧) លទ្ធផលជាផ្លូវការ នៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៧ ព្រះរាជាណាចក្រកម្ពុជា www.necelect.org.kh

## ប្រជាជនជនជាតិដើមភាគតិច ស្ត្រីជនជាតិដើមភាគតិច

- Gonzales Patricia & Rodriguez Roberto (១៩៩៨) ភាពជាអ្នកដឹកនាំរបស់ស្ត្រីកំពុងកើតមានឡើងវិញនៅក្នុងប្រទេសឥណ្ឌា ភាពជាអ្នកដឹកនាំស្ត្រីជនជាតិដើម ប្រជាជាតិឥណ្ឌា
- កិច្ចប្រជុំកំពូលរបស់សហប្រជាជាតិ (២០០៧) សេចក្តីសម្រេច ៦១ - ២៩៥ សេចក្តីប្រកាសរបស់ សហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ឯកសាររបស់កិច្ចប្រជុំកំពូល កិច្ចប្រជុំទី ៦១ បន្ថែម ៥៣
- ក្រុមអភិវឌ្ឍន៍របស់សហប្រជាជាតិ (២០០៨) គោលការណ៍ណែនាំអំពីបញ្ហារបស់ជនជាតិដើមភាគតិច ខែ កុម្ភៈ ឆ្នាំ ២០០៨

វិធីសាស្ត្រពិភាក្សានិងសន្ទនាជាលក្ខណៈបើកចំហ បានផ្ទៀងផ្ទាត់ទៅនឹងវិធីសាស្ត្រដែលបានប្រើនៅក្នុងការស្រាវជ្រាវលើកមុនជាមួយស្ត្រីជនជាតិដើមភាគតិចនៅទូទាំងប្រទេសកម្ពុជា (Maffii M., ២០០៦)។ មានគោលការណ៍ណែនាំមួយចំនួនដែលបានបង្កើតឡើងដើម្បីជាផ្លូវតម្រង់ទិសក្នុងពេលសិក្សាស្រាវជ្រាវ (ពិភាក្សា) ដូចជាៈ

- ស្ត្រីដែលចូលរួមក្នុងដំណើរការ បានរួមចំណែកយ៉ាងសកម្មក្នុងការបង្កើតជាចំណេះដឹង និងអត្ថន័យដែលបានកត់ត្រានិងនិយាយប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់។
- ស្ត្រីរួមចំណែកដោយការបង្ហាញពីបទពិសោធន៍ រឿងរ៉ាវផ្សេងៗ អារម្មណ៍ ការព្រួយបារម្ភ ឬទស្សនវិស័យនាពេលអនាគតទៅតាមការចាត់អទិភាពរៀងៗខ្លួន។ សំណួរស្រាវជ្រាវគឺជាផ្នែកមួយ នៃវិធីសាស្ត្រជារួមទូទៅមួយ ដែលមិនឃ្លាតចាកពីបទពិសោធន៍ស្ត្រីជនជាតិដើម និងឆន្ទៈរបស់ពួកគាត់ក្នុងការប្រាស្រ័យទាក់ទងទេ។
- ការអនុវត្តនៃការស្រាវជ្រាវនេះ គឺជាឧបករណ៍មួយសម្រាប់បំណងប្រាថ្នាស្ត្រី ដើម្បីចាកផុតពីការរឹតត្បិតខាងសង្គម និងនយោបាយ និងទទួលបាននូវតម្លៃមួយដែលបានពីការលុបបំបាត់ការរើសអើងយេនឌ័រ និងជនជាតិដើមភាគតិច ដែលបង្កើតដំណើរការរួមមួយកសាងចំណេះដឹងរួមគ្នា។ ការពិភាក្សា និងការសម្ភាសធ្វើឡើងនៅក្នុងភូមិនៅក្នុងសាលាឃុំតាមដែលអាចរកបាននៅក្នុងផ្ទះឯកជន ឬនៅក្រោមដើមឈើ។ ស្ត្រីអ្នកចូលរួមមានអាយុខុសគ្នា និងមានកំរិតទ្រព្យសម្បត្តិខុសគ្នា។ ចំនួនស្ត្រីខុសគ្នាពីក្រុម តូចដែលមានគ្នា ៥-៦នាក់ ទៅក្រុមធំដែលមានគ្នាជិត ១៥នាក់។ មានអ្នកបកប្រែផ្សេងៗគ្នាដែលបានចូលរួមសម្របសម្រួលការពិភាក្សាទាំងនេះ។ ក្រៅពីស្ត្រីនៅក្នុងសហគមន៍ ជនសកម្មផ្សេងទៀតក៏បានរួមចំណែកក្នុងការស្រាវជ្រាវនេះដែរដូចជាៈ ចាស់ទុំនៅក្នុងសហគមន៍ តំណាងមកពីមន្ទីរកិច្ចការនារីខេត្ត សមាជិកក្រុមប្រឹក្សាឃុំជាបុរស តំណាងអង្គការក្រៅរដ្ឋាភិបាល។

យើងដឹងយ៉ាងច្បាស់ថាលទ្ធផលអាចផ្តល់នូវទស្សនៈត្រឹមតែមួយជ្រុងគឺនៅក្នុងស្ថានភាពមួយ និងអាស្រ័យទៅ តាមបរិបទដែលការសិក្សានេះធ្វើឡើង រួមផ្សំនឹងប្រធានវិស័យរបស់អ្នកស្រាវជ្រាវផ្ទាល់និងការបកស្រាយ។

## តារាងឈ្មោះស្រុក ដែលបានចុះធ្វើការពិភាក្សាជាមួយក្រុមស្ត្រី

| ខេត្ត | ស្រុក | ឃុំ | ចំនួនភូមិ | ជនជាតិ |
|---|---|---|---|---|
| មណ្ឌលគិរី | អូររាំង | ដាក់ដាំ | ២ | ពូង |
| | | សែនមនោរម្យ | ២ | ពូង |
| | សែនមនោរម្យ | រមនា | ៣ | ពូង |
| | ពេជ្រាដា | ប៊ូស្រា | ២ | ពូង |
| រតនៈគីរី | អូរជុំ | អូរជុំ | ១ | ទំពួន |
| | | ឡាក់ | ៣ | គ្រឹង |
| | អូរយ៉ាដាវ | ប៉ាតេ | ២ | ចារាយ |
| | បរកែវ | កក់ | ២ | ទំពួន ចារាយ |
| | | ទឹងចាក់ | ១ | ទំពួន |
| | តាវែង | តាវែងលើ | ១ | លុន |
| | | តាវែងក្រោម | ១ | ព្រៅ |
| | វឺនសៃ | កាចុង | ២ | គ្រឹង ទំពួន |
| ស្ទឹងត្រែង | សៀមប៉ាង | សេកុង | ១ | ឡាវ |
| | | សន្តិភាព | ១ | កាវែត |
| | សៀមបូក | កោះស្រឡាយ | ១ | ខ្មែរ |
| ក្រចេះ | ក្រចេះ | ដារ | ១ | ខ្មែរ |
| | ព្រែកប្រសប់ | ជ្រោយបន្ទាយ | ១ | ខ្មែរ |